ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩**

**សវនាការលើកទី៤៣**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc Lavegne)*
លោក ធូ មណី
លោក យូរ ឧត្តារា
លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី
លោកស្រី សែ កុលវុឌ្ឍី
លោក ម៉ាតូ គ្រីស្ពារ
*(Mr. Matteo Crippa)*
កញ្ញា ណាចាក់ វិចស៊ែល
*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក តាន់ សេណារ៉ុង

លោក អានីស អះម៉េត *(Mr. Anees AHMED)*

លោក ពេជ្រ សម្បត្តិ

លោក ហ្សាធិរី ឡាំពែល *(Mr.Zachery LAMPEL)*

**ជនជាប់ចោទ៖**

លោក កាំង ហ្កេក អ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោកស្រី ម៉ារីប៉ូល កានីហ្សារ

*(Mrs.Marie-Paule Canizares)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក គឹម ម៉េងឃី

កញ្ញា ទី ស្រ៊ីនណា

លោក ហុង គឹមសួន

លោក គង់ ពិសី

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ម៉ាទីន ហ្សាកឃ្វីន (ហ្សាកកាំង)

*(Mrs. Martine Jacquin)*

លោក អាឡាំង វ៉ែនណឺ*(Mr. Alain Werner)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ខ្លឹមសម្ព័ន្ធ

# សាក្សី

## លោកស្រី ណាំ ម៉ុន

សួរដោយ ប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ១
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ផ្ដើមពី ....................ទំព័រ ៩
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ....................ទំព័រ ១៣
សួរដោយ លោក តាន់ សេណារ៉ុង ផ្ដើមពី ....................ទំព័រ ២១
សួរដោយ លោក អានីស អះម៉េត ផ្ដើមពី ....................ទំព័រ ២៥
សួរដោយ លោកស្រី ស៊ីលឃី ស្ទួតហ្សិនស្គី ផ្ដើមពី ....................ទំព័រ ២៩
សួរដោយ លោកស្រី ម៉ាទីន ហ្សាកឃ្វីន ផ្ដើមពី ....................ទំព័រ ៣៨
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ បន្តពី....................ទំព័រ ៤៧
សួរដោយ លោក ការ សាវុត្ថ ផ្ដើមពី....................ទំព័រ ៤៨
សួរដោយ លោក ហ្វ្រង់ស្វ័រ រូ ផ្ដើមពី....................ទំព័រ ៥៤

## លោក ម៉ម ណៃ ហៅ ចាន់

សួរដោយ ប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ៦១

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អានីស អះម៉េត | អង់គ្លេស |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ឺន័ | បារាំង |
| លោកស្រី ណាំ ម៉ុន | ខ្មែរ |
| លោក ម៉ម ណៃ | ខ្មែរ |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី (ក្រឡាបញ្ជី) | ខ្មែរ |
| លោក វីលៀម ស្មីត | អង់គ្លេស |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*[អង្គសវនាការចាប់ផ្តើមនៅម៉ោង ០៩:០១:០០ នាទី]*

[០៩:០១:២០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ណាំ ម៉ុន ដែលបានធ្វើសវនាការដេញដោលកាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុនតែដោយនីតិវិធីមិនទាន់ចប់ ថ្ងៃនេះយើងធ្វើបន្តទៀត ។ ហើយមុននឹងផ្តើមនៃការដេញដោលក្រឡាបញ្ជីសវនាការឡើងរាយការណ៍អំពីស្ថានភាពវត្តមាននិងអវត្តមាន ភាគីនិងបុគ្គលដែលត្រូវកោះអញ្ជើញចូលរួមឲ្យមកដំណើរការសវនាការនៅក្នុងថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ភាគីដែលត្រូវរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន ចំណែកតំណាងដើមបណ្តឹងរដ្ឋប្បវេណី ណាំ ម៉ុន ក៏មានវត្តមាននៅក្នុងបន្ទប់សវនាការផងដែរ ហើយសាក្សីK-08 ដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះនឹងអញ្ជើញមកដល់សវនាការនៅម៉ោងដប់ សាក្សីរូបនេះបានធ្វើសម្បថរួចហើយ ។

**សួរដោយប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះគឺកិច្ចពិភាក្សាដេញដោលទៅលើដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ណាំ ម៉ុន ។

**ស៖** ណាំ ម៉ុន យ៉ាងម៉េចទៅព្រឹកនេះអាចមានអារម្មណ៍ល្អ អាចឆ្លើយនឹងសំណួររបស់អង្គជំនុំជម្រះនិងភាគីដែលនឹងដំណើរការរឿងក្តីព្រឹកនេះបានទេ?

**លោកស្រីណាំ ម៉ុន៖**

**ឆ៖** ចាស, បានលោកប្រធាន ។

**ស៖** នៅក្នុងពាក្យបណ្តឹងរបស់លោកស្រី គឺមានសរសេរពាក់ព័ន្ធទៅនឹងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ តើលោកស្រីបានយកមកទេនៅថ្ងៃនេះដើម្បីបង្ហាញដល់អង្គជំនុំជម្រះ?

**ឆ៖** បានយក ។

**ស៖** នេះដែលមន្ត្រីតុលាការផ្តល់ឲ្យអង្គជំនុំជម្រះមិញនេះមែនទេ?

**ឆ៖** *(គ្មានឮសំឡេង)* ។

[០៩:០៥:០៧]

**ស៖** លោកស្រីអាយុពិតប្រាកដ អាយុប៉ុន្មានទៅគិតដល់ឆ្នាំនេះ?

**ឆ៖** អាយុខ្ញុំពិតប្រាកដ៤៨ឆ្នាំ ។

**ស៖** និយាយពីកំណើតឆ្នាំខ្មែរវិញ ឆ្នាំជូត ឆ្លូវ ខាល ថោះ រោង ម្សាញ់ ទាំងដប់ពីរសត្វដែលរាប់តាមក្បួនខាតនៃឆ្នាំកំណើតខ្មែរនោះ តើលោកស្រីមានឆ្នាំកំណើតឆ្នាំរូបអីដែរ?

**ឆ៖** យើងខ្ញុំកើតឆ្នាំជូត ខែមាឃធំ ។

**ស៖** នៅក្នុងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែររបស់លោកស្រី ដែលចេញដោយអភិបាលខ្មែរកំពង់ចាម ឈ្មោះ ឯកឧត្តម ជាង អំ ចុះថ្ងៃទី១០ ខែ១០ ឆ្នាំ២០០០ ហើយមានសុពលភាពរហូតដល់ថ្ងៃទី១០ ខែ១០ ឆ្នាំ២០១០ ។ ហើយអត្តសញ្ញាណបណ្ណនេះមានលេខសម្គាល់គឺ ០៦០០៣៦៧៦៦ ដាក់ថ្ងៃខែឆ្នាំកំណើតហ្នឹងគឺនាម និងគោត្តនាម ណាំ ម៉ុន ថ្ងៃខែឆ្នាំកំណើត ថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៦៨ ។ ហើយដូចគ្នានឹងពាក្យបណ្តឹងរបស់លោកស្រីដែលបានសរសេរជូនមកតុលាការដែរ គឺដាក់ថាលោកស្រីមានថ្ងៃខែឆ្នាំកំណើត ២ កក្កដា ១៩៦៨ ។

បើតាមឯកសារនេះបានសេចក្តីថា ដល់ឆ្នាំ១៩៧៥ លោកស្រីទើបតែមានអាយុ៧ឆ្នាំ ឬ៨ឆ្នាំប៉ុណ្ណោះ ។ តើវាមានហេតុផលយ៉ាងម៉េចទៅ ពីព្រោះកាលពីសវនាការថ្ងៃព្រហស្បតិ៍កន្លងទៅលោកស្រីបាននិយាយថាអាយុលោកស្រីមានអាយុកាលនោះគឺ១៥ឆ្នាំ ហើយបានត្រូវគេជ្រើសរើសធ្វើជាបុគ្គលិកពេទ្យនៃមន្ទីរស-២១? ប៉ុន្តែប្រសិនបើលោកស្រីត្រឹមតែអាយុ ៧ឆ្នាំ ឬ៨ឆ្នាំ ឬយ៉ាងច្រើន៩ឆ្នាំនោះ ប្រហែលជាមិនមានការជ្រើសរើសធ្វើជាបុគ្គលិកពេទ្យបានទេ អាចនឹងអង្គភាពកុមារបាន ប៉ុន្តែអង្គភាពពេទ្យមិនបានទេ? លោកស្រីអាចពន្យល់បាន អំពីភាពខុសគ្នានេះជូនដល់អង្គជំនុំជម្រះបានដែរឬទេ?

**ឆ៖** ខ្ញុំអាចពន្យល់បាន កាលខ្ញុំធ្វើកាតនេះគឺម្តាយមីងរបស់ខ្ញុំដែលគាត់អត់ទាន់ដឹងអាយុឆ្នាំខ្ញុំប៉ុន្មានគឺគាត់ធ្វើ ។ គាត់ទៅនិយាយប្រាប់គេឲ្យគេកត់អ៊ីចឹង គាត់អត់បានសួរខ្ញុំផង ។ បើកំណើតខ្ញុំពិតប្រាកដគឺដូចពាក្យខ្ញុំនិយាយពីមុន ។ ខ្ញុំមានឪពុកម្តាយណាដឹងអាយុខ្ញុំផង មានតែម្តាយមីងហ្នឹងក៏ម្តាយពីឆ្ងាយដែរ គាត់ស្មានដាក់ក្នុងនុ៎ងស្មាន ។

**ស៖** សំណួរមួយទៀត លោកស្រីបានអះអាងថា លោកស្រីធ្វើបុគ្គលិកពេទ្យហើយបុគ្គលិកហ្នឹង មានតែមនុស្សបីនាក់ទេ ហើយកន្លែងការិយាល័យនៃក្រុមពេទ្យនៃមន្ទីរស-២១ នុ៎ង គឺនៅត្រើយម្ខាងនៃ ក្លោងទ្វារចូលទៅក្នុងមន្ទីរស-២១ ។ សំណួរសួរថា តើទីកន្លែងសម្រាប់ក្រុមពេទ្យហ្នឹង ជាសំណង់ចាស់ ឬក៏សំណង់ថ្មី ហើយសំណង់នោះគេសង់អំពីអ្វីដែរ?

[០៩:១១:៣៩]

**ឆ៖** កន្លែងខ្ញុំទាំងបីនាក់នៅនេះគឺខាងក្រោមឈើ ខាងលើថ្ម ផ្ទះ ។

**ស៖** បញ្ជាក់ម្តងទៀត នៅប្រភេទផ្ទះហ្នឹងថាម៉េច និយាយឲ្យច្បាស់លាស់?

**ឆ៖** ដែលផ្លូវផ្ទះដែលខ្ញុំរស់នៅក្រុមខ្ញុំទាំងអស់ ទាំងបីនាក់ហ្នឹង គឺនៅខាងមុខគុកទួលស្លែងនេះ ហើយ ប៉ុន្តែផ្ទះខាងក្រោមគេធ្វើជាឈើ ខាងលើបានថ្ម ។

**ស៖** ចុះទីកន្លែងដែលលោកស្រីរស់នៅដេកនិងរស់នៅប្រចាំថ្ងៃនុ៎ងនៅកន្លែងណា? នៅកន្លែងធ្វើ ការហ្នឹង ឬនៅកន្លែងផ្សេង?

**ឆ៖** ប្រចាំថ្ងៃហ្នឹង ខ្ញុំពេលណាដែលខ្ញុំមកឲ្យថ្នាំដល់ទៅជនរងគ្រោះនុ៎ងទៅ ខ្ញុំបកទៅកន្លែងខ្ញុំ សម្រាកនោះវិញ ខ្ញុំអត់បាននៅជិតដល់តែហ្នឹងទេ ។

**ស៖** សួរថាកន្លែងថា ដេក កន្លែងដេកយប់ កន្លែងសម្រាកហ្នឹង បន្ទាប់ពីធ្វើការងារហ្នឹង លោក ស្រីនៅកន្លែងណា? នៅកន្លែងដែលលោកស្រីអះអាងថាក្រុមពេទ្យធ្វើការងារហ្នឹង ឬក៏មានផ្ទះនៅដោយ ឡែកផ្សេង?

**ឆ៖** ព្រោះយើងខ្ញុំនៅទាំងក្រុមពេទ្យទាំងអស់តែម្តង អត់មាននៅបែកផ្សេងពីពេទ្យ ។ នៅផ្ទះជា មួយគ្នាទាំងអស់ ។

**ស៖** នៅផ្ទះដែលលោកស្រីនិយាយហ្នឹង ឬក៏នៅកន្លែងផ្សេង?

**ឆ៖** នៅផ្ទះដែលខ្ញុំនិយាយហ្នឹងតែម្តង ។

**ស៖** លោកស្រីបញ្ជាក់ម្តងទៀត ថ្ងៃមុនមិនច្បាស់លាស់ថា តើប្រធានក្រុមពេទ្យអង្គាល់ពីលោក ស្រីចូលធ្វើការហ្នឹង ឈ្មោះអ្វីដែរ? ហើយមនុស្សស្រី ឬក៏មនុស្សប្រុស?

**ឆ៖** ប្រធានក្រុមពេទ្យគឺឈ្មោះ មិត្តលន គឺមនុស្សស្រី មួយឈ្មោះ យឹម មនុស្សស្រី រួមទាំងខ្ញុំ បីនាក់ ។

**ស៖** លោកស្រីដឹងថាឈ្មោះ លន និងឈ្មោះ ឃឹម ហ្នឹងសព្វថ្ងៃនៅរស់ទេ? ឬក៏ជោគវាសនាគេយ៉ាងម៉េច?

**ឆ៖** ឈ្មោះ លនៗ គេចាប់ទៅមុនមិត្ត ឃឹម ចាប់មិត្តឃឹម រួចបានចាប់ខ្ញុំទៀត ។ ពេទ្យទាំងបីហ្នឹង គឺរងគ្រោះដូចគ្នា ។

[០៩:១៥:00]

**ស៖** លោកស្រីបញ្ជាក់ម្តងទៀត បញ្ជាក់បន្ថែមទៀតលើចំណុចនៃទីកន្លែងក្បែរផ្ទះពេទ្យ ផ្ទះក្រុមពេទ្យនៅនិងធ្វើការ ដែលលោកស្រីបានលើកឡើងខាងលើនេះ ។ ផ្ទះហ្នឹងបែរមុខទៅខាងណា? ទៅទិសខាងណា?

**ឆ៖** ផ្ទះហ្នឹង បែរមុខទៅត្បូង ។

**ស៖** នៅក្បែរជាប់គ្នានឹងផ្ទះក្រុមពេទ្យហ្នឹង ។ តើមានផ្ទះមានក្រុមខាងណាផ្សេងទៀត គេនៅក្បែរនោះទេ? ក្រុមផ្សេងៗនៃក្រុមដែលធ្វើការនៅមន្ទីរស-២១ ។ តើមានក្រុមផ្សេងទៀត ដែលនៅជិតផ្ទះនោះដែរឬទេ?

**ឆ៖** នៅជិតផ្ទះដែលខ្ញុំសម្រាកនោះ គឺគ្មានទេ នៅក្នុងទាហានគុកអំមិញនេះ មានតែកូនចៅពូខ្ញុំខាងទាហាន ។ ខាងពូខ្ញុំកងពល គាត់យកមកដាក់ជិតកន្លែងខ្ញុំសម្រាកហ្នឹង គឺសម្រាកផ្ទះមួយជិតជាប់គ្នាហ្នឹង ។

**ស៖** ពូរបស់លោកស្រី ដែលថាធ្វើការនៅកងពលហ្នឹង ។ គាត់ឈ្មោះអីទៅ? ហើយគាត់ធ្វើការកងពលលេខប៉ុន្មាន?

**ឆ៖** ពូខ្ញុំឈ្មោះ អឿន ។ មួយទៀត ឈ្មោះ កេត ធ្វើការនៅកងពលទីក្រុងភ្នំពេញ ហើយខ្ញុំមិនដឹងលេខគាត់ ដាក់លេខប៉ុន្មានទេ? ព្រោះខ្ញុំភ្លេចដែរ ។

**ស៖** កម្លាំងរបស់កងពលដែលយកមកដាក់-- មករស់នៅជិតកន្លែងលោកស្រីរស់នៅនិងធ្វើការជាក្រុមពេទ្យហ្នឹង គ្នាមានគ្នាប៉ុន្មាន? ហើយស្លៀកបំពាក់យ៉ាងម៉េច? ហើយមានប្រដាប់អាវុធដែរទេ? មានកាំភ្លើងដែរទេ?

**ឆ៖** គេរស់នៅជិតខ្ញុំហ្នឹង គឺមានអាវុធគ្រប់គ្រាន់ហើយនិងពាក់ខោអាវខ្មៅ ។

**ស៖** មានគ្នាប្រហែលប៉ុន្មាននាក់?

**ឆ៖** ដំបូងគាត់យកមកដាក់សម្រាកនៅហ្នឹងគ្នាប្រហែលជាសាមសិបសែសិបនាក់ដែរ ។ ដល់ចុងក្រោយគាត់ដកទៅខ្លះ នៅសល់តែបួនដប់នាក់ទេ ដែលសម្រាកជិតផ្ទះខ្ញុំនោះ ។

**ស៖** ចុះនៅថ្ងៃដែលគេចាប់ខ្លួនលោកស្រី ។ តើកម្លាំងនោះ នៅទីនោះដដែលដែរឬទេ? កម្លាំងរបស់កងពលរបស់ពូរបស់លោកស្រី ដែលនៅក្បែរលោកស្រីនោះ តើកម្លាំងនោះ នៅទីនោះដែរឬទេ?

[០៩:១៩:៤២]

**ឆ៖** ថ្ងៃដែលគេចាប់យើងខ្ញុំគឺកម្លាំងនោះនៅគ្នាតិចណាស់ ហើយបួនប្រាំនាក់ទេដែលចាំនៅកន្លែងនោះ ។

**ស៖** ឥឡូវនេះ ដល់ដំណាក់កាលនៃនីតិវិធីរៀបចំធ្វើម្តងទៀត ត្រូវឱ្យលោកស្រីពិនិត្យមើលរូបថតនានា ដែលអង្គជំនុំជម្រះប៉ុនប៉ងក្នុងការដាក់បង្ហាញឱ្យលោកស្រីពិនិត្យមើលកាលពីថ្ងៃមុន ប៉ុន្តែដោយមានបញ្ហានៃការរំជួលចិត្តខ្លាំង ហើយម្តងហើយម្តងទៀត អង្គជំនុំជម្រះក៏បានផ្អាកដំណើរការនោះហើយលើកមកបន្តនៅថ្ងៃនេះ ។ តើថ្ងៃនេះអង្គជំនុំជម្រះនឹងដាក់បញ្ហានេះ តើលោកស្រីអាចមានអារម្មណ៍ថានឹងអាចពិនិត្យមើលរូបថតនេះបានដែរទេ? ដើម្បីឱ្យអង្គជំនុំជម្រះនឹងអាចមានលទ្ធភាពក្នុងការពិភាក្សាដេញដោលលើភស្តុតាងនេះ ឱ្យបានស៊ីជម្រៅ ។

**ឆ៖** នាងខ្ញុំអាចពិនិត្យមើលបាន ។

**ស៖** មន្ត្រីខាងផ្នែកសោតទស្សន៍ សូមរៀបរាប់បង្ហាញនូវឯកសារដែលមានលេខចាប់ពីលេខ ERN00274367 និងតាមលំដាប់លេខរៀងរហូតដល់ឯកសារដែលមានលេខ 00274373 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ដោយរូបនីមួយៗដាក់កម្រិតត្រឹមតែសាមសិបវិនាទី ឬក៏មួយនាទី ដើម្បីឱ្យជូនដល់អង្គជំនុំជម្រះ និងដើមបណ្តឹងរដ្ឋប្បវេណីរូបនេះពិនិត្យ ។

លោកស្រី តើពិនិត្យមើលរូបនេះ-- តើរូបជារូបថតរបស់អ្នកណាគេ? ហើយគាត់ឈ្មោះអី? ហើយគាត់ត្រូវម៉េចជាមួយនឹងលោកស្រី?

**ឆ៖** រូបថតនេះហើយ ជារូបថតពុកខ្ញុំ ។ គាត់ឈ្មោះ ប្រាក់ ។

**ស៖** ស្អី ប្រាក់ ទៅ?

**ឆ៖** ឈ្មោះដើមគាត់ ចួន យ៉ន ឈ្មោះបដិវត្តន៍ យៀត ប្រាក់ ។

**ស៖** មន្ត្រីសោតទស្សន៍បន្តទៅរូបមួយទៀត ។ លោកស្រីពិនិត្យរូបថតនេះ តើលោកស្រីស្គាល់ថាជារូបថតអ្នកណាទេ? ហើយគាត់ឈ្មោះអ្វី? សូមប្រាប់ឈ្មោះនោះ ប្រាប់ទាំងត្រកូល ប្រាប់ទាំងឈ្មោះ

ប្រើផ្សេងៗដែលគាត់ធ្លាប់ប្រើផង ប្រសិនបើលោកស្រីស្គាល់?

**ឆ៖** រូបនេះហើយជារូបម្ដាយរបស់ខ្ញុំ ។ គាត់ឈ្មោះ ឃិន តុះ បដិវត្តន៍ឈ្មោះ ឃិន សាន ។

**ស៖** បន្តទៅរូបភាពមួយទៀត ។ ចុះរូបថតនេះ? ម្នាក់នេះ?

**ឆ៖** រូបប្អូនពៅរបស់ខ្ញុំ ។

**ស៖** គាត់ឈ្មោះអ្វីដែរ?

**ឆ៖** យៀត យ៉ន  អ! យៀត យ៉ុន ។

**ស៖** បន្តទៅទៀត ហើយរូបថតមួយទៀត ។ ចុះរូបថតនេះ? រូបថតនេះ រូបថត-- គាត់ឈ្មោះអ្វីដែរ? ហើយគាត់ត្រូវម៉េចជាមួយនឹងលោកស្រី?

**ឆ៖** រូបថតនេះ ជារូបថតប្អូនរបស់ខ្ញុំ ។ អំមិញនោះ រូបថតបងរបស់ខ្ញុំ ។

**ស៖** អំមិញនោះ ថាបងនោះ ។ បងឈ្មោះអ្វីដែរ?

**ឆ៖** ស្ដាប់មិនច្បាស់ ។

**ស៖** និយាយម្ដងទៀត ។ បងអំមិញដែលថារូបអំមិញនោះ ។ ឈប់ ។ ច្រឡំអំមិញហ្នឹង តើបងនោះឈ្មោះអ្វីដែរ? ផ្នែកខាងសោតទស្សន៍ទម្លាក់រូបមកវិញ ។ ម្ដងទៀតនែ៎ តើរូបម្នាក់នេះ លោកស្រីអះអាងថា ពិតជាបងរបស់លោកស្រីអ៊ីចឹង? ហើយគាត់ឈ្មោះអ្វី?

**ឆ៖** រូបថតនេះ ជារូបថតបងរបស់ខ្ញុំ ។ ឈ្មោះ វឿន ។

**ស៖** ចុះម្នាក់នេះ? គាត់ឈ្មោះអ្វីដែរ? ហើយត្រូវម៉េចជាមួយនឹងលោកស្រី? ប្រាប់ត្រកូលផង! ទាំងនាមត្រកូលរបស់គាត់ផងណា?

**ឆ៖** នេះជាប្អូនពៅរបស់ខ្ញុំ ។ ឈ្មោះ យៀត យ៉ុន ។

**ស៖** បន្តទៅរូបមួយទៀត ។ លោកស្រីពិនិត្យមើលរូបនេះមើល តើជារូបថតរបស់អ្នកណាគេ? ហើយអ្នកហ្នឹងឈ្មោះអ្វី? ហើយត្រូវម៉េចជាមួយនឹងលោកស្រី?

[០៩:២៧:០១]

**ឆ៖** រូបថតនេះ គឺរូបថតពុករបស់ខ្ញុំដែលគាត់ជិតស្លាប់ ។

**ស៖** បន្តទៅរូបថតមួយទៀត ។ ចុះរូបនេះ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន ។ ដើម្បីគោលបំណងនៃឲ្យមានប្រតិចារឹកត្រឹមត្រូវនោះ ។ តើអាច

បញ្ជាក់ថាពីលេខ បានទេ? គឺលេខនៅលើរូបថតនីមួយៗដើម្បីឲ្យនៅក្នុងកំណត់ត្រាត្រឹមត្រូវ ហើយទាក់ទងទៅនឹងរូបថតចុងក្រោយមួយ ខ្ញុំពិនិត្យឃើញថា គឺមានអក្សរនៅលើរូបថតនោះ ជាភាសាខ្មែរ ។ខ្ញុំថា តើអាចអានបានដែរឬទេ?

**សួរដោយ ប្រធានអង្គជំនុំ៖**

អ៊ីចឹង បន្តយមករូបមុនវិញ រូប៤៣៧១ ។ ទៀតៗ អូរខេ ។ លោកស្រីអាចអានអក្សរនេះបានទេ? លោកស្រីចេះអក្សរទេ?

**លោកស្រី ណាំ ម៉ុន៖**

ខ្ញុំអត់ចេះទេ ។ អានអត់ដាច់ ។

**ប្រធានអង្គជំនុំ៖**

សែ កុលវុឌ្ឍី អាននូវអក្សរនៅលើរូបថតនេះ ហើយនិងថ្ងៃខែឆ្នាំផង ។

**លោកស្រី សែ កុលវុឌ្ឍី៖**

ចូន យ៉ន ហៅ ប្រាក់ ថ្ងៃទី០៩ ខែ១១ ឆ្នាំ១៩៧៧ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទ, បន្តទៅរូបមួយទៀត ។ រូបនេះ គឺមានលេខERN00274372 ។

រូបថតនេះ ជារូបថតរបស់អ្នកណាគេ? គាត់ឈ្មោះអ្វី? ហើយមានទំនាក់ទំនងយ៉ាងម៉េចជាមួយនឹងលោកស្រី?

[០៩:៣០:០០]

**ឆ៖** រូបនេះ គឺរូបថតបងថ្លៃខ្ញុំ ។ គាត់ឈ្មោះ សុខហេង គាត់ឈ្មោះ ឃុន សុខហេង ។

**ស៖** បងថ្លៃហ្នឹង បានន័យថា ប្តីរបស់គាត់មួយណា? ឈ្មោះអ្វី?

**ឆ៖** ប្តីគាត់ឈ្មោះ នឿន, យៀត នឿន ។

**ស៖** ហើយនៅជំនាន់កម្ពុជាប្រជាធិបតេយ្យហ្នឹង តើលោកស្រីឈ្មោះ សុខហេង ហ្នឹង គាត់ធ្វើការងារអ្វីដែរ? ហើយគាត់នៅអង្គភាពណា?

**ឆ៖** គាត់អត់មានធ្វើអីទេ គាត់មកតាមប្តីគាត់ រួមរស់នៅជាមួយម្តាយខ្ញុំ ។

**ស៖** ផ្នែកមន្ត្រីសោតទស្សន៍ បន្តទៅរូបភាពមួយទៀត ។ រូបនេះដែលមានលេខ ERN បង្វិលៗមក មានលេខ ERN អត់ឃើញ ។ បានៗហើយ ។ រូបភាពនេះគឺមានលេខ ERN 00274373 ។

ចុះរូបម្នាក់នេះ រូបថតម្នាក់នេះ តើគាត់ឈ្មោះអ្វីដែរ? ហើយគាត់ត្រូវយ៉ាងម៉េចជាមួយនឹងលោកស្រី? ហើយកាលពីសម័យកម្ពុជាប្រជាធិបតេយ្យនោះគាត់ធ្វើអ្វីដែរ?

**ឆ៖** រូបម្នាក់នេះ គឺបងប្រុសរបស់ខ្ញុំ ។ កាលពីមុននោះ គាត់ទៅនៅកន្លែងវាលវង់កប៉ាល់បោះជាមួយពូខ្ញុំ ។ ឈ្មោះបង ខឿន, ប្រាក់ ខឿន ។

**ស៖** ពេលមុនអង្គជម្រះបានសួររួចហើយ មន្ត្រីខាងសោតទស្សន៍បង្វែររូបភាពទៅជារូបភាពធម្មតាឡើងវិញ ។

កាលពីថ្ងៃព្រហស្បតិ៍ អង្គជម្រះបានសួរសំណួរជាច្រើនចំពោះលោកស្រីហើយ ។ ឥឡូវនេះ គឺនៅសំណួរសេសសល់មួយចំនួន គឺតើលោកស្រីអាចនិយាយប្រាប់ដល់អង្គសវនាការបានដែរឬទេ អំពីទិដ្ឋភាពផ្សេងទៀតដែលលោកស្រីបានឃើញនៅក្នុងអំឡុងពេលដែលលោកស្រីអះអាងថាបានធ្វើការនៅមន្ទីរសន្តិសុខស-២១ បច្ចុប្បន្នដែលគេស្គាល់ជាទូទៅ ហៅថា គុកទួលស្លែង នោះ ។ តើលោកស្រីបានឃើញទិដ្ឋភាពអ្វីខ្លះ ទាំងនៅខាងក្នុងនៃមន្ទីរតាមអគារនីមួយៗ ទាំងនៅខាងក្រៅនៃអគារ?

**ឆ៖** ពេលយើងខ្ញុំដើរព្យាបាល គឺឃើញតែគេវ៉ៃសួរចម្លើយ វ៉ៃដំនោះគឺរូបភាពក្រៅពីហ្នឹង គឺគ្មានឃើញតែគេវ៉ៃអ្នកទោសសួរចម្លើយ ។

[០៩:៣៤:១១]

**ស៖** លោកស្រីឃើញគេវាយអ្នកទោសដោយផ្ទាល់ទេ ដែលលោកស្រីអះអាងថា គេវាយអ្នកទោសសួរចម្លើយហ្នឹង ឃើញដោយផ្ទាល់ភ្នែកខ្លួនឯងទេ? ហើយប្រសិនបើឃើញ កន្លែងដែលគេសួរចម្លើយហើយវាយអ្នកទោសនោះនៅកន្លែងណា? ហើយលោកស្រីនៅចម្ងាយប៉ុន្មានម៉ែត្រពីកន្លែងដែលគេសួរ?

**ឆ៖** គឺខ្ញុំមិនបានឃើញផ្ទាល់ ឃើញតែរបួសនៅលើដងខ្លួនអ្នករងគ្រោះទាំងអស់ បែកឈាមហូរកក្លិកក្លាក់ ។ គឺវាយ គឺយើងខ្ញុំអត់ឃើញផង ។

**ស៖** លោកស្រីដែលឃើញមនុស្សស្លាប់ទេនៅក្នុងអគារ ដែលលោកស្រីដើរទៅព្យាបាលឲ្យអ្នកទោសដែលលោកស្រីអះអាងថា ដើរទៅព្យាបាលឲ្យអ្នកទោសនោះ?

**ឆ៖** ដើរអត់ដែលឃើញផងរឿងអ្នកស្លាប់។ ឃើញតែអ្នកវេទនាជិតស្លាប់តែម្តង ។ រឿងស្លាប់តែម្តងអត់ឃើញ ។

**ស៖** លោកស្រីដែលឃើញមានកុមារនៅជាប់នៅទីនោះដែរទេ? ហើយគេប្រព្រឹត្តចំពោះកុមារទាំងនោះយ៉ាងដូចម្តេចដែរ?

**ឆ៖** ឯកន្លែងកុមារគឺយើងខ្ញុំអត់បានដឹងថា គេដាក់នៅកន្លែងណាគឺអត់ដឹង គឺខ្ញុំបានមើលតែចាស់ៗនៅអគារនោះតែមួយអគារ អត់មានមើលវែងឆ្ងាយទៅទៀតទេ ។

**ស៖** នៅកន្លែងផ្ទះលោកស្រីដែលលោកស្រីអះអាងថា ជាកន្លែងធ្វើការផង ហើយជាកន្លែងរស់នៅទីនោះផង ។ តើទីនោះគេបានធ្វើអ្វីចាត់ឲ្យលោកស្រីធ្វើអ្វីទេ? ដូចជាការនាំអ្នកទោសយកទៅបូមឈាម បូមយកឈាមសម្រាប់យកទៅផ្គត់ផ្គង់ដល់មន្ទីរពេទ្យនានា ។ តើលោកស្រីបានឃើញអំពីទិដ្ឋភាពនេះដែរឬទេ?

**ឆ៖** អត់ដែលបានឃើញផង គេបូមឈាមបូមអី អត់ដែលបានឃើញទេ ។

**ប្រធានអង្គជំនុំ៖**

ខ្ញុំអស់សំណួរហើយ តើអស់លោក លោកស្រីចៅក្រមនៃអង្គជំនុំជម្រះមានសំណួរអ្វីត្រូវសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរឬទេ? ប្រសិនបើមានសូមអញ្ជើញ ។

សូមអញ្ជើញលោកស្រីចៅក្រម ។

[០៩:៣៧:០៩]

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

សូមអរគុណលោកប្រធាន ។ សូមអរគុណ លោកស្រី ដែលត្រលប់មកវិញនៅថ្ងៃនេះ ។ ហើយយើងដឹងថា វាពិតជាមានការពិបាកណាស់ចំពោះលោកស្រី ហើយវាមានការពិបាកក្នុងការនិយាយអំពីអ្វីដែលបានកើតឡើងចំពោះលោកស្រីទោះបីជាវាកើតរយៈពេលយូរឆ្នាំទៅហើយក៏ដោយ ។

**ស៖** ខ្ញុំសូមធ្វើការបំភ្លឺទៅលើចំណុចមួយចំនួន ដោយសារតែពេលខ្លះខ្ញុំពិបាកយល់ឲ្យបានច្បាស់លាស់នូវអ្វីដែលលោកស្រីបានលើកឡើង ដោយសារតែយើងត្រូវស្តាប់តាមរយៈការបកប្រែ ។

តើលោកស្រីមានអាយុប៉ុន្មានដែរ នៅពេលដែលគេចាត់តាំងលោកស្រីឲ្យធ្វើការងារជាពេទ្យនៅស-២១? តើនៅពេលនោះលោកស្រីមានអាយុប៉ុន្មាន?

**ឆ៖** យើងខ្ញុំនៅ-- គេចាត់តាំងឲ្យខ្ញុំធ្វើពេទ្យនៅស-២១ គឺខ្ញុំបានអាយុ១៥ឆ្នាំ ។

**ស៖** នៅពេលដែលលោកស្រីចាប់ផ្តើមការងារជាពេទ្យ ថាតើលោកស្រីទទួលបានការបង្រៀនយ៉ាងម៉េចខ្លះ?

**ឆ៖** បង្រៀនចែកថ្នាំនៅលើដងខ្លួនអ្នកជំងឺ ខ្ចងអ្នកជំងឺតែប៉ុណ្ណឹង ។

**ស៖** តើលោកស្រីដឹងអំពីប្រភេទថ្នាំ ដែលលោកស្រីត្រូវផ្តល់ឲ្យអ្នកជាប់គុកនៅស-២១ ដែលឬទេ?

**ឆ៖** គឺយើងខ្ញុំព្យាបាល គឺអាចព្យាបាលតែថ្នាំត្រជាក់ ថ្នាំក្តៅ រឿងថ្នាំក្រុំគ្រាគឺគ្មាន ។ គេឲ្យព្យាបាលតែថ្នាំត្រជាក់ទាំងអស់ ។

**ស៖** តើលោកស្រីជាអ្នកសម្រេចថា ត្រូវផ្តល់ថ្នាំប្រភេទណាទៅដល់អ្នកជាប់ឃុំដូចជានៅពេលដែលអ្នកជាប់ឃុំហ្នឹងមានការក្តៅខ្លួនជាដើម តើមែនដែរទេ?

**ឆ៖** កាលយើងខ្ញុំនៅឯធ្វើពេទ្យនោះ គឺថ្នាំគឺសុទ្ធតែថ្នាំសល់ពីដើមមក មានប៉ារ៉ា មានវីតាមីនអ៊ីចឹងទៅ ឲ្យទៅលើអ្នកជំងឺនោះតែម្តង ។ អត់មានថ្នាំក្លែងក្លាយធ្វើឥឡូវ គឺអត់មានទេ កាលខ្ញុំនៅនុំងលេបថ្នាំសល់ពីដើមមក ។

[០៩:៤០:០៩]

**ស៖** តើលោកស្រីដែលអស់ថ្នាំ លែងអាចប្រើប្រាស់ថ្នាំទាំងអស់នោះដែរឬទេ? ដោយសារតែវាអស់ហើយត្រូវប្រើថ្នាំអីផ្សេងដែរឬទេ? ធ្លាប់ដែលអ៊ីចឹងដែរទេ?

**ឆ៖** ខ្ញុំប្រើថ្នាំនោះអស់ទៅ អស់រយៈប្រហែលជាកន្លះខែ គេឲ្យថ្នាំបុកជាឫសឈើយកមកឲ្យខ្ញុំចែកជាម្តង ។ ដល់អស់នោះទៅ គឺគេចាប់ខ្ញុំឃុំឃាំងតែម្តង ។

**ស៖** តើលោកស្រីដឹងថា អ្នកណាជាអ្នកធ្វើថ្នាំឫសឈើហ្នឹងដែរឬទេ? ហើយថ្នាំហ្នឹងគេយកមកពីណាដែរ?

**ឆ៖** ខ្ញុំអត់ដឹងផង ដឹងតែគេយកមកឲ្យព្យាបាលតែម្តង អត់ដឹងអ្នកណាធ្វើៗផង អត់ដឹង ។

**ស៖** លោកស្រីនិយាយថា លោកស្រីធ្វើការនៅក្នុងអគារតែមួយ ។ ថាតើនៅក្នុងអគារនោះមានបុរសដែរឬទេ? ឬក៏មានស្ត្រីដែរ?

**ឆ៖** អគារណាទៅមួយ? អត់ច្បាស់ ។

**ស៖** សូមអភ័យទោស ។ ខ្ញុំហាក់ដូចជាលើកឡើងមិនច្បាស់ ។ នៅក្នុងអគារដែលលោកស្រីធ្វើការជាពេទ្យ ថាមានអ្នកជាប់គុកបុរសនៅក្នុងនោះដែរឬទេ? ឬក៏មានអ្នកជាប់គុកជាស្ត្រីផងដែរ?

**ឆ៖** នៅអគារដែលយើងខ្ញុំអាចដើរព្យាបាលនោះ ស្រីគឺមាន ប្រុសក៏មានដែរ ប៉ុន្តែនៅបន្ទប់ដោយខ្លួន ព្រោះអគារនោះគឺ គេដាក់ថាអគារពិសេស គឺអ្នកកម្មាភិបាលទាំងអស់តែម្តង ទាំងកូន ទាំងប្តី ទាំង

ប្រពន្ធ គ្រាន់តែនៅបន្ទប់ដោយខ្លួន តែប៉ុណ្ណឹង ។

**ស៖** ចាតើគ្រួសារ និងសមាជិកគ្រួសាររបស់លោកស្រីនៅក្នុងអគារ ដែលលោកស្រីដើរធ្វើការងារព្យាបាលនោះដែរឬទេ?

**ឆ៖** គឺឪពុកយើងខ្ញុំ ដែលចាត់ទៅដំបូង គឺដាក់អគារដែលខ្ញុំព្យាបាលហ្នឹង ។ ឯចំណែក ម្ដាយ គឺអត់ដឹងទេ បងប្អូនទាំងអស់ដឹងដាក់អគារមួយណា គឺខ្ញុំអត់បានដឹង ដឹងតែឪពុកទេ ។

**ស៖** ខ្ញុំគិតថាអង្កាល់ពីសប្ដាហ៍មុនលោកស្រីបានជម្រាបខ្ញុំថា លោកស្រីអាចនិយាយជាមួយនឹងឪពុករបស់លោកស្រី ។ តើលោកស្រីនិយាយដូច្នេះដែរឬទេ?

**ឆ៖** ដល់ខ្ញុំដើរព្យាបាលហ្នឹង គឺឪពុកខ្ញុំបានផ្ដែផ្ដាំខ្ញុំថា កុំឲ្យគាត់ស្គាល់គាត់ អាំនៃ ខ្ញុំហ្នឹងស្គាល់គាត់ ប្រយ័ត្នគេយកខ្ញុំវៃចោលទៀត ។ គាត់បានផ្ដាំបានតែប៉ុណ្ណឹង បែកគ្នារហូត ។

**ស៖** ដូច្នេះ វាត្រឹមត្រូវដែរឬទេដែលថា លោកស្រីបានស្ដាប់យ៉ាងប្រុងប្រយ័ត្នគាត់ ហើយលោកស្រីទទួលស្គាល់ថា គាត់ហ្នឹងជាឪពុករបស់លោកស្រី តើត្រឹមត្រូវដែរឬទេ?

[០៩:៤៣:៥១]

**ឆ៖** ចាស, ដល់ស្ដាប់ហើយ គឺខ្ញុំយកតែពាក្យណែនាំរបស់គាត់ មកវែកញែកមើល គាត់ជាឪពុករបស់ខ្ញុំចង់ឲ្យកូនរស់ បានជាគាត់ប្រាប់ខ្ញុំអ៊ីចឹង ។

**ស៖** តើលោកស្រីនៅធ្វើការនៅស-២១នោះរយៈពេលប៉ុន្មានដែរ? តើនៅប៉ុន្មានខែមុនពេលដែលលោកស្រីត្រូវបានគេចាប់ឃុំនោះ?

**ឆ៖** ខ្ញុំធ្វើការនៅនោះតាំងពីឆ្នាំ៧៥ រហូតដល់ឆ្នាំ៧៧ បានគេចាប់ខ្លួនជិតដាច់៧៧ចូល៧៨ គេចាប់ខ្លួនយើងខ្ញុំតែម្ដង ។

**ស៖** តើលោកស្រីដឹងថា ហេតុអ្វីបានជាគេចាប់លោកស្រីដែរឬទេ?

**ឆ៖** យើងខ្ញុំអត់ដឹងមូលហេតុអ្វីដែលគេចាប់ផង ស្រាប់ដល់ទៅសួរគេទៅគេថាមកពីខ្ញុំហ្នឹងជាប់កូនអ្នកក្បត់ កូនខ្មែរក្រហមបានគេចាប់ ។

**ស៖** ក្រោយពេលគេចាប់ខ្លួនលោកស្រី លោកស្រីនិយាយថា គេនាំលោកស្រីទៅគុកមួយផ្សេង តើត្រឹមត្រូវដែរឬទេ?

**ឆ៖** គេចាប់ខ្លួនខ្ញុំទៅ ខ្ញុំរស់នៅគុកទួលស្លែងបានរយៈប្រហែលបីខែ បានគេបញ្ជូនខ្ញុំទៅគុកព្រៃស ឲ្យខ្ញុំជីករណ្ដៅនៅគុកព្រៃសនោះតែម្ដង រួចពីគុកព្រៃសទៅ ឲ្យខ្ញុំទៅដល់គុកព្រៃទទឹងទៀត ។ បានរស់

វៀតណាមចូលគឺខ្ញុំរស់មានជីវិតទល់សព្វថ្ងៃនេះ ។

**ស៖** នៅពេលលោកស្រីផ្តល់ការសម្ភាសន៍ ចង់ក្លាយទៅជាដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីបាននិយាយថា បន្ទាប់ពីគេឃុំនៅព្រៃស គេបានបញ្ជូនលោកស្រីទៅធ្វើនៅ ធ្វើការនៅកងចល័តសម្រាប់រយៈពេលបីខែ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំរួមរស់នៅគុកព្រៃស អស់រយៈប្រាំខែ ទើបបានគេជូនទៅគុកព្រៃទទឹងអស់រយៈបីខែវៀតណាមចូល ។

**ស៖** លោកស្រីក៏បានលើកឡើងថា លោកស្រីជាប់គុកជាមួយនឹងប្អូនប្រុសរបស់លោកស្រីនៅព្រៃឈរ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជាការត្រឹមត្រូវ ។ ខ្ញុំជាប់គុកនៅទីនោះមែនពីរនាក់ប្អូនប្រុស បកពីព្រៃសទៅជួបប្អូនគុកនោះតែម្តង ។

**ស៖** តើប្អូនប្រុសនោះឈ្មោះអ្វីដែរ ដែលគាត់ជាប់ឃុំជាមួយនឹងលោកស្រីនៅពេលនោះ?

**ឆ៖** ប្អូនប្រុសខ្ញុំនោះ ជាប្អូនចិញ្ចឹមទេ ប៉ុន្តែវាឈ្មោះ រុន, រឿន រុន ប្អូនចិញ្ចឹមរបស់ខ្ញុំ ។ ដល់ពេលកាលខ្ញុំប្តឹង ខ្ញុំដាក់ យៀត រុន ប្អូនខ្ញុំ ។

**ស៖** នៅក្នុងចម្លើយដែលលោកស្រីបានប្រាប់នោះ លោកស្រីបានលើកឡើងថា គេដោះលែងលោកស្រីនៅយប់ដែលទ័ពវៀតណាម បានវាយលុកទៅលើព្រៃឈរ តើត្រឹមត្រូវដែរទេ?

**ឆ៖** ត្រឹមត្រូវហើយ អ៊ីចឹងពិតមែន ។

**ស៖** លោកស្រីក៏បានលើកឡើងដែរថា គេរៀបនឹងសម្លាប់លោកស្រីហើយនៅយប់ដែលវៀត-ណាមចូលមកទីនោះ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** នៅយប់ទីនោះគេជិត ពីថ្ងៃនោះ គេប្រុងតែយកខ្ញុំទៅវៃចោលបាត់ទៅហើយ ប៉ុនដល់ពេលយប់ហ្នឹង គឺវៀតណាមចូលមកដល់ទាន់ កុំអីក៏ខ្ញុំស្លាប់ដែរ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកស្រីច្រើនដែលបានជួយផ្តល់ការបំភ្លឺនូវសំណួរមួយចំនួនដែលខ្ញុំមាន ។ ហើយខ្ញុំពិតជា សុំថ្លែងអំណរគុណដល់លោកស្រីណាស់ ដែលមកចូលរួមនៅទីនេះ ហើយជួយយើងខ្ញុំផ្តល់នូវចម្លើយចំពោះសំណួរទាំងឡាយ ។

លោកប្រធាន ខ្ញុំអស់សំណួរហើយ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីមួយនេះ ។ សូមអរគុណ ។

[០៩:៤៩:៣២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សូមអរគុណលោកប្រធាន ។ អរុណសួរស្តីលោកស្រី ខ្ញុំសុំសួរសំណួរមួយចំណួនដើម្បីបំភ្លឺលើចំណុចទាំងឡាយ លោកស្រីបានជម្រាបយើងខ្ញុំថា លោកស្រីមានអាយុ១៥ឆ្នាំនៅពេលដែលលោកស្រីចូលរួមជាពេទ្យនៅស-២១ ។ ប្រសិនខ្ញុំយល់ត្រឹមត្រូវនោះ កាលពីសប្តាហ៍មុនលោកស្រីបានលើកឡើងថា មុនពេលនោះ មុនពេលធ្វើពេទ្យលោកស្រីរស់នៅក្រុងភ្នំពេញជាមួយគ្រួសារ ។ នៅពេលដែលរស់នៅជាមួយគ្រួសារនោះ លោកស្រីបានចូលរួមក្នុងការផ្តល់ការបណ្តុះបណ្តាលខាងវិជ្ជាពេទ្យ ។ តើលោកស្រីបានទទួលការបង្រៀនផ្នែកពេទ្យនៅឆ្នាំ១៩៧៥ដែរឬទេ មុនពេលលោកស្រីចូលរួមជាសមាជិកនៅស-២១?

**ឆ៖** កាលដើមឡើយនោះ ខ្ញុំរួមរស់នៅជាមួយឪពុកម្តាយខ្ញុំនៅឯទីក្រុងភ្នំពេញ ដល់គេជម្លៀសទៅនៅព្រែកក្តាម គឺឪពុកអាចចូលមកវិញ ហើយនៅកន្លះខែក្រោយមកគឺឪពុកខ្ញុំទៅយកខ្ញុំពីព្រែកក្តាមមកដល់នៅទីក្រុងភ្នំពេញវិញ គឺខ្ញុំអាចចូលរៀនពេទ្យ ។ រៀននៅឯទីក្រុងភ្នំពេញនេះតែម្តង ។

**ស៖** ថាតើនៅពេលដែលរៀនពេទ្យនោះ តើវាយ៉ាងម៉េច? តើគេមានថ្នាក់ឲ្យលោកស្រីទៅរៀនដែរឬទេ? ហើយគេបង្រៀនពីអ្វីខ្លះ? ហើយលោកស្រីមានកត់ត្រាដែរឬទេ? តើលោកស្រីបានធ្វើអ្វីខ្លះនៅពេលដែលចូលរួមវគ្គរៀនពេទ្យនោះ?

**ឆ៖** គឺយើងខ្ញុំចូលរៀនពេទ្យនោះ គឺមិនបានចាកត់ត្រាអីទេ ចេះរៀនដើរទៅព្យាបាលគេបន្តិចបន្តួច មិនរៀនជាចំណាប់ចំនួនទៅដូចជាពេទ្យយើងសព្វថ្ងៃ គឺអត់ទេ ពេទ្យខ្ញុំនៅក្មេងណាស់ គេឲ្យតែខ្ញុំឲ្យតែស្គាល់ថ្នាំដើរចែកទៅគេគឺបានតែប៉ុននុ៎ង ។ រយៈតាមពូខ្ញុំ ពូ អឿន នេះតែម្តង គាត់ឲ្យខ្ញុំរៀន ។

**ស៖** ថាតើលោកស្រីស្គាល់ឈ្មោះថ្នាំយ៉ាងម៉េច? តើលោកស្រីមើលឈ្មោះថ្នាំហ្នឹងនៅតាមអក្សរដែលគេសរសេរបញ្ជាក់ ឬយ៉ាងម៉េច?

[០៩:៥២:៤៤]

**ឆ៖** គឺខ្ញុំមើលឈ្មោះថ្នាំនេះដោយសារគេប្រាប់ទេ ។ ខ្ញុំអត់ចេះទេ ។ គេប្រាប់ខ្ញុំថាអានេះមួយត្រូវព្យាបាលរោគនេះ អានេះមួយត្រូវព្យាបាលរោគនោះ គឺខ្ញុំចំណាំទាំងអស់ ។ ឲ្យខ្ញុំចេះ ខ្ញុំអត់ចេះទេ ។

**សៈ** ថាតើថ្នាំហ្នឹងវាមើលទៅរាងយ៉ាងម៉េច? ហើយវាមានទម្រង់យ៉ាងម៉េច? គឺថ្នាំហ្នឹងថ្នាំមកពីប្រទេសខាងលិច លោកខាងលិច ឬក៏ថ្នាំបុរាណ ហើយតើលោកស្រីអាចបែងចែកប្រភេទថ្នាំយ៉ាងម៉េច ថាវាខុសពីថ្នាំមួយទៅថ្នាំមួយ?

**ផៈ** គឺថ្នាំត្រូវជាក់គេប្រាប់មកថាអាស្ពៀរីននេះមួយ ហ្នឹងខ្ញុំអាចចំណាំបាន ។ ថ្នាំវីតាមីន គេប្រាប់ថាថ្នាំវីតាមីន គឺខ្ញុំអាចចំណាំកញ្ចប់នោះបាន ។ មានប្រភេទខុសគ្នា តែប៉ុណ្ណឹង ។

**សៈ** លោកស្រីបានដាក់ពាក្យដើម្បីជាដើមបណ្តឹងរដ្ឋប្បវេណី ពាក្យសុំនេះ មានភ្ជាប់ជាមួយនឹងឯកសារមួយចំនួនដែលឯកសារទាំងអស់នោះ រួមមានរូបថតដែលលោកស្រីត្រូវបានគេបង្ហាញព្រឹកមិញនេះ ។ យើងឃើញមានការកត់សម្គាល់ផ្សេងៗនៅលើរូបភាព រូបថតទាំងអស់នោះ ហើយចំពោះរូបថតដែលខ្ញុំមាននោះ គឺរូបថតដែលមានលេខ ERN ជាភាសាអង់គ្លេស 00274374 ។ លេខ ERN 002743-- *(សុំទាំមួយភ្លែត)* លេខ ERN នោះគឺលេខ 00274367 ដល់លេខ 00274373 ខ្ញុំចង់ដឹងថាតើការសរសេរនៅលើរូបថតនោះ គឺវាស្របទៅនឹងចម្លើយរបស់លោកស្រី ឬក៏យ៉ាងម៉េច? ហើយតើអ្នកណាគេដែលសរសេរលេខ ឬក៏អក្សរសម្គាល់នៅលើរូបថតនោះ?

**ផៈ** រូបថតពាក្យដែលយើងខ្ញុំដាក់ប្តឹង ឬមួយរូបថតអី? អត់ដឹងផង អត់ច្បាស់ ។

**សៈ** ខ្ញុំនិយាយអំពីរូបថតដែលលោកស្រីបានឃើញព្រឹកមិញនេះ ដែលរូបថតទាំងអស់នេះ បានភ្ជាប់ជាមួយនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី រូបថតទាំងអស់នោះមានការសរសេរនៅខាងលើ ហើយនៅលើរូបថតនោះក៏មានស្នាមមេដៃផងដែរ ថាខ្ញុំចង់ដឹងថាតើនរណាគេជួយសរសេរអក្សរទាំងអស់នេះជំនួសលោកស្រី ហើយខ្ញុំចង់ដឹងថាលោកស្រីបានផ្តិតមេដៃនៅលើរូបថតទាំងអស់នោះដែរឬទេ?

**ផៈ** រូបថតទាំងអស់ដែលខ្ញុំដាក់ប្តឹងនោះ គឺយើងខ្ញុំបានផ្តិតមេដៃយកមកជូនតុលាការ ។ សរសេរគេអ្នកជួយ មេធាវីរបស់យើងខ្ញុំអាចជួយសរសេរខ្ញុំ អាចប្រាប់គាត់សរសេរបាន ។

[០៩:៥៧:២០]

**សៈ** ឧទាហរណ៍ថាតើយើងអាចមាន ថាតើអ្វីដែលសរសេរនោះធ្វើយ៉ាងម៉េចបានជាដាក់ថាជាបងស្រី ឬក៏បងប្រុសរបស់លោក? ហើយខ្ញុំឃើញលេខ 00274373 មានសរសេរថា បងប្រុសរបស់លោកស្រីដែលធ្វើការនៅព្រលានយន្តហោះ។ ថាតើលោកស្រីមានការយល់ច្រឡំចំពោះបងប្អូនជីដូនមួយរបស់លោកស្រី និងបងប្រុសរបស់លោកស្រីដែរឬទេ? ហើយដើម្បីភាពងាយស្រួលនោះ ខ្ញុំចង់ឲ្យ

បង្ហាញរូបថតទាំងអស់នេះនៅលើអេក្រង់របស់យើង ដែលមានការសរសេរអ្វីទាំងឡាយនោះនៅលើរូបថតនោះផងដែរនោះ ។

**ឆ៖** យើងខ្ញុំអត់មានយល់ច្រឡំបងប្អូនជីមួយ ឬមួយបងបង្កើត ។ បងជីដូនមួយគឺ-- បងបង្កើតរបស់យើងខ្ញុំដែលធ្វើនៅកន្លែងរថយន្តកប៉ាល់ហោះនោះ គឺបងបង្កើត ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះហើយមេធាវីរបស់លោកស្រីជាអ្នកសរសេរខុស តើយើងអាចបង្ហាញរូបថតលេខ 0027 4373 នៅលើផ្ទាំងអេក្រង់របស់យើងដែរឬទេ?

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍បង្ហាញនូវឯកសាររូបថតដែលមានលេខ ERN 00274373 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ដើម្បីជាការងាយស្រួលក្នុងការដេញដោលនាពេលនេះ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ដូច្នេះហើយ តើយើងអាចបង្ហាញនូវការសរសេរនៅខាងក្រោមរូបថតនេះដែរឬទេ?

ដូច្នេះ អ្វីដែលយើងឃើញនៅទីនេះគឺជារូបថតរបស់ វ៉ាត់ ខឿន ដែលគាត់ជាបងជីដូនមួយរបស់លោកស្រី ។ ហើយដោយសារចំណុចនេះវាធ្វើឲ្យវាមិនស៊ីគ្នានូវអ្វី ដែលលោកស្រីបានប្រាប់យើងពីមុនថាតើនេះជារូបថតរបស់បងជីដូនមួយរបស់លោកស្រី ឬក៏ជារូបថតរបស់បងប្រុសលោកស្រី? ប្រសិនបើលោកស្រីមិនចាំទេ បញ្ជាក់ថាលោកស្រីថាមិនចាំ។

**ឆ៖** គឺកាលពីដើមឡើយដែលខ្ញុំថតដាក់បងជីដូនមួយរបស់ខ្ញុំនេះ គឺខ្ញុំអត់ប៊ានដាក់ថា បងបង្កើតទេ ខ្ញុំខ្លាច ព្រោះបងប្អូនសុទ្ធតែជាប់គុកទាំងអស់គ្នាម្ល៉េះហើយ ខ្ញុំដាក់ជាបងប្អូនជីដូនមួយទៅ ។

[១០:០១:១៧]

**ស៖** ខ្ញុំសុំអត់ទោសដោយសារ ខ្ញុំត្រូវត្រឡប់ទៅរូបថតមួយទៀត តើយើងអាចបង្ហាញរូបថតមួយទៀតដែលមានលេខ 00274371 ។ ហើយជាពិសេសអក្សរដែលនៅខាងក្រោម ដែលដាក់បញ្ចូលទៅជាឯកសារនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយសុំឲ្យមើលអក្សរនេះដែលបញ្ជាក់ថានេះរូបថតរបស់ ចួន យ៉ន ដែលជាបងប្រុសរបស់លោក ប៉ុន្តែតាមដែលខ្ញុំស្តាប់លោកស្រីបញ្ជាក់ពីដើមនោះថាដែលលោកស្រីនិយាយថា ជារូបថតរបស់ឪពុករបស់លោកទេ ។ ហើយខ្ញុំជឿថាពីមុននោះយើងក៏បានអាន នូវអក្សរខ្មែរនៅលើរូបថតនោះដែរ ។ ខ្ញុំមិនបានឃើញ ខ្ញុំមិនអាចអានបានទេ

ប៉ុន្តែយើងនិយាយពីឈ្មោះ យ៉ន ហ្នឹងមានពីរកន្លែងមាន ប្រាក់ យ៉ន ។

អ៊ីចឹងតើលោកស្រីអាចបញ្ជាក់ បន្ថែមបានទេ ថាតើនេះជារូបថតរបស់ឪពុករបស់លោកស្រី ឬក៏ជាបងប្អូនប្រុសរបស់លោកស្រីនោះ?

**ឆ៖** ប្រាក់ផង យ៉នផង គេហៅគាត់សាមញ្ញគាត់ ចួន យ៉ន ដល់ពេលមកអាពតនេះ យៀត ប្រាក់។ នេះជាឪពុករបស់យើងខ្ញុំ ដែលគាត់នៅវេទនានៅក្នុងគុកទួលស្លែងនេះ ។ ហើយអក្សរ និងមុខតួខ្លួន ឪពុករបស់យើងខ្ញុំនេះ គឺអត់មាននៅជាប់នៅក្នុងកញ្ចក់ កន្លែងគេដាក់គាត់អ៊ីចឹងតែម្តង ។

**ស៖** ខ្ញុំព្យាយាមយល់ឲ្យបានច្បាស់នូវចំណុចនេះ ។ អ៊ីចឹង ប្រសិនបើមានអក្សរនៅក្នុងភាសាអង់គ្លេសនៅខាងក្រោមនោះដែលបញ្ជាក់ថា ជាបងប្អូនប្រុសនោះ តើលោកស្រីបានបញ្ជាក់អ៊ីចឹងទេ ឬក៏ជាកំហុសឆ្គងទេ ដែលមកបញ្ជាក់កន្លែងនេះ?

**ឆ៖** ថាបងប្រុសនោះ គឺខ្ញុំមិនអាចឆ្លើយថា ឪពុកខ្ញុំបានទេ ព្រោះខ្ញុំឆ្លើយអត់រួច ទៅខ្ញុំឆ្លើយថាបងប្រុសរបស់ខ្ញុំទៅ ។

[១០:០៤:៥១]

**ស៖** ពីខាងដើមនោះខ្ញុំ យើងអាចត្រឡប់ទៅរករូបភាពប្រក្រតីវិញ យើងអាចនឹងសុំដកចេញនូវការបង្ហាញរូបថតនេះ ពេលនេះចេញ ។

ពីមុននោះលោកស្រីចៅក្រម ខាតវ៉ាយថ៍ បានសួរលោកនូវសំណួរមួយចំនួនទាក់ទង ថាតើមានអ្វីកើតឡើងចំពោះចំណុចមួយដែលលោកបានឃើញ បានជួបប្អូនប្រុសរបស់លោកស្រីទៀតនៅព្រៃឈរនោះ ។ អ៊ីចឹងសំខាន់យើងត្រូវអានឯកសារមួយ ដែលនៅក្នុងលេខ E232.1 នៅក្នុងភាសាបារាំងលេខ ERN 00321445 នៅក្នុងអត្ថបទភាសាខ្មែរលេខ ERN 00274363 ហើយលោកស្រីបាននិយាយថាការរៀបរាប់អំពីបទឧក្រិដ្ឋកម្ម ឪពុករបស់ខ្ញុំឈ្មោះ ម្តាយរបស់ខ្ញុំឈ្មោះ ឃិន តុះ ។

មុនឆ្នាំ១៩៧៥ ពួកគាត់នៅភ្នំពេញ ហើយបន្ទាប់ពីការដួលរលំភ្នំពេញ ពួកគាត់ត្រូវបានគេជម្លៀសទៅនៅក្នុងឃុំឈើបាក់ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ ក្រោយឆ្នាំ១៩៧៦ ឪពុករបស់ខ្ញុំបានចូលធ្វើទាហានខ្មែរក្រហមនៅទីក្រុងភ្នំពេញ ហើយបាននាំទាំងគ្រួសារទាំងអស់មកនៅជាមួយផង ។ ហើយនៅចុងឆ្នាំ១៩៧៧ គេបានចាប់ខ្លួនឪពុកខ្ញុំ ហើយយកទៅឃុំខ្លួននៅគុកទួលស្លែង ។ មួយខែក្រោយមកគេតាមចាប់ទាំងគ្រួសារទាំងអស់ទៅគុកទួលស្លែង ។ ក្នុងពេលនោះបងប្រុសរបស់ខ្ញុំឈ្មោះ យ៉ន រឿន, យ៉ន នឿន, យ៉ន សុខហេង, យ៉ន យ៉ុន ខ្លួនខ្ញុំ ណាំ ម៉ុន និងប្អូនប្រុសដែលរស់នៅសព្វថ្ងៃឈ្មោះ

យ៉ន រុន នៅក្នុងភូមិក្រគរ ឃុំក្រគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ ក្នុងពេលនោះដែរគេបានបញ្ជាឲ្យបងប្រុសខ្ញុំឲ្យវាយសម្លាប់ឪពុកម្ដាយ ហើយទើបគេសម្លាប់ពួកគាត់ជាក្រោយ ។

ក្នុងពេលនោះខ្ញុំស្រែកយំយ៉ាងខ្លាំង គេបានបញ្ជូនខ្ញុំទៅគុកព្រៃសវិញ ។ នៅទីនោះបានមួយខែគេបានបញ្ជូនខ្ញុំទៅគុកព្រៃឈរធ្វើជាកងចល័តបានបីខែ គេចាប់ជាមួយប្អូនប្រុស យ៉ន រុន ដាក់គុកនៅព្រៃឈរ ។ ក្រោយមកគេនឹងយកខ្ញុំ និងប្អូនប្រុសខ្ញុំ ទៅសម្លាប់ចោលនៅពេលយប់នោះ ប៉ុន្តែក្រោយមកបានទាហានវៀតណាម វាយចូលមកខ្ញុំទាំងពីរក៏បានរួចខ្លួន ។

[១០:០៨:៣៦]

នេះជាសេចក្តីរៀបរាប់ដែលលោកស្រី បានប្រាប់ទៅវិទ្យាស្ថានខ្មែរ គឺនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ ២០០៨ មានស្នាមមេដៃរបស់លោកស្រី ។ អ៊ីចឹង គឺវាមានភាពខុសគ្នាជាច្រើន អំពីការរៀបរាប់នៅក្នុងសេចក្តីថ្លែងការណ៍នេះនៅក្នុងពាក្យសុំ ហើយនិងអ្វីដែលលោកស្រីបានបញ្ជាក់នៅក្នុងសវនាការនេះ។

អ៊ីចឹងជាឧទាហរណ៍ លោកស្រីបាននិយាយពីឈ្មោះ យ៉ន រឿន នៅពេលដែលឆ្លើយទៅនឹងសំណួររបស់ចៅក្រម ខាតវ៉ាយថ៍ និយាយថាគាត់ជា គឺជាកូនប្រុស ឬក៏ជាបងប្អូនធម៌ អ៊ីចឹងហើយខ្ញុំមិនច្បាស់ តើ យ៉ន រឿន គាត់មានឈ្មោះ អ្វីផ្សេងទៀតទេ? ឈ្មោះ យ៉ន រឿន ហ្នឹង?

**ឆ៖** ប្អូនប្រុសរបស់ខ្ញុំគឺឈ្មោះ ផល, យៀត ផល ពីជំនាន់ ពីដើមគេហៅឈ្មោះ ផល ដល់ជំនាន់ ប៉ុល ពត គេហៅ យៀត រុន ជាប្អូនចិញ្ចឹមរបស់យើងខ្ញុំ ។

**ស៖** ខ្ញុំមិនយល់អ្វីដែលលោកស្រីបញ្ជាក់ តើលោកស្រីបានទៅជួបនៅព្រៃឈរនោះនរណា យ៉ន រឿន អ្នកដែលនៅរស់ដល់បច្ចុប្បន្នឬក៏ម្នាក់ផ្សេងទៀត? តើអ្នកដែលនៅរស់នៅឡើយនោះ ថាតើឈ្មោះអ្វី? ខ្ញុំដែលមិនច្បាស់ទេចំណុចនេះ ។

**ឆ៖** អ្នកដែលនៅរស់សព្វថ្ងៃនេះគឺ យៀត រុន ដែលផុតពីជំនាន់ប៉ុលពតមកនៅរស់ពីរនាក់ហ្នឹងមានតែ យៀត រុន ។ ប៉ុន្តែ យៀត រុន ហ្នឹងមិនមែនជាប្អូនរបស់យើងខ្ញុំបង្កើតទេ គឺជាប្អូនចិញ្ចឹមទេ។ ឯចំណែក ប្អូនខ្ញុំបង្កើតបងប្អូនខ្ញុំទាំងអស់ គឺស្លាប់នៅក្នុងគុកទួលស្លែងនេះអស់ទៅហើយ។

**ស៖** ប៉ុន្តែគាត់ជាកូនរបស់អ្នកណា? គាត់ជាកូនរបស់ឪពុកធម៌លោកស្រី ឬក៏យ៉ាងម៉េច?

**ឆ៖** គឺ យៀត រុន នេះជាប្អូនចិញ្ចឹមរបស់យើងខ្ញុំនេះ គឺកូនរបស់ម៉ែចិញ្ចឹមខ្ញុំនៅសព្វថ្ងៃនេះ ។

**ស៖** ឥឡូវនេះនិយាយអំពីឈ្មោះរបស់លោកស្រី ។ ខ្ញុំដូចជាមិនទាន់យល់ច្បាស់ លោកស្រីបាននិយាយថា ឈ្មោះផ្លូវការរបស់លោកស្រីគឺឈ្មោះ ណាំ ម៉ុន ប៉ុន្តែលោកស្រីក៏បានបញ្ជាក់ដែរថា លោក

ស្រីធ្លាប់ប្រើឈ្មោះមួយផ្សេងទៀតដែលហៅ រឿន ចាន់ថា អ៊ីចឹងមែនឬទេ? តើលោកស្រីធ្លាប់ប្រើឈ្មោះ រឿន ចាន់ថា ហ្នឹងដែរឬទេ?

**ឆ៖** គឺយើងខ្ញុំឈ្មោះ រឿន ចាន់ថា នេះ ចាប់ប្រើពីឆ្នាំ១៩៧៥ ដែលខ្ញុំរស់នៅទីក្រុងភ្នំពេញនេះរហូត ។ ដល់ទៅចប់យួនចូល គឺខ្ញុំអត់បានប្រើទេ គឺប្រើ ណាំ ម៉ុន វិញ ។

**សះ** តើលោកស្រីអាចប្រាប់យើងបានទេថា ហេតុអ្វីបានជាលោកស្រីប្រើឈ្មោះនេះនៅក្នុងសម័យកាលនោះ? ដែលថាជាឈ្មោះមួយដែលមិនបង្ហាញពីនាមត្រកូល ឬក៏ឈ្មោះត្រកូលឪពុក ហើយក៏មិនមែនជាឈ្មោះដែលប្រើ ដោយសមាជិកក្រុមគ្រួសារផ្សេងទៀតដែរ? ហេតុអ្វីបានជាលោកស្រីប្រើឈ្មោះ រឿន ចាន់ថា នេះ?

**ឆ៖** គឺខ្ញុំប្រើឈ្មោះនេះដោយសារលាក់ឈ្មោះឪពុកម្ដាយរបស់ខ្ញុំ ។ ខ្ញុំយកឈ្មោះឪពុកធម៌ម្ដាយធម៌យកមកដាក់ធ្វើជាឪពុក ។ ឪពុកធម៌ម្ដាយធម៌ខ្ញុំគឺឈ្មោះរឿន ចាន់ថា។ ឪពុកខ្ញុំឈ្មោះ រឿន ខ្ញុំឈ្មោះ ចាន់ថា បើឪពុកបង្កើតគឺឈ្មោះ ម៉ុន នេះ ណាំ ម៉ុន នេះ ហៅតែ ណាំ ម៉ុន ឪពុកបង្កើត ។ បើយកត្រកូលឪពុកបង្កើត គឺយក យៀត ណាំម៉ុន បានខ្ញុំអត់យកទៅប្រើទេខ្លាចគេវៃខ្ញុំចោល ខ្ញុំយកត្រកូលឪពុកចិញ្ចឹមរបស់ខ្ញុំវិញ ។

[១០:១៥:១៦]

**សះ** ជាថ្មីម្ដងទៀត យោងទៅរកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គឺមានឯកសារមួយដែលឆ្លើយតបទៅនឹងប្រវត្តិរូបរបស់លោកស្រីដែលខ្ញុំជឿថា យកមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ៊ីចឹងនៅក្នុងអត្ថបទភាសាអង់គ្លេស ERN គឺលេខ 00274366 ។

ដូច្នេះ ព័ត៌មាននៅក្នុងជីវប្រវត្តិ ឬក៏ប្រវត្តិរូបនេះ ដែលហៅមានឈ្មោះ យ៉ិន យ៉ន ហើយនិងមានឈ្មោះ យន់ នៅកន្លែងនោះផង ។ តើឈ្មោះ យ៉ាន យ៉ន តើមានអ្នកណានៅក្នុងក្រុមគ្រួសាររបស់អ្នកស្រីឈ្មោះអ៊ីចឹងទេ? តើហេតុអ្វីបានជាមានឈ្មោះហ្នឹងភ្ជាប់ទៅនឹងពាក្យសុំរបស់លោកស្រីនោះ?

**ឆ៖** ខ្ញុំក៏បានឲ្យគេដាក់ឲ្យឈ្មោះ យ៉ន យ៉ុន គឺឪពុកខ្ញុំឈ្មោះ យ៉ន ប្អូនខ្ញុំឈ្មោះ យ៉ុន គឺខ្ញុំយកនាម ត្រកូលដាក់ យ៉ន យ៉ុន តែម្ដង ។ ទើបមកឥឡូវខ្ញុំប្រែដាក់ យៀត យ៉ុន វិញ ។

**សះ** ព័ត៌មាននៅក្នុងប្រវត្តិរូបសង្ខេបនេះ ដែលឈ្មោះថា យ៉ាន យ៉ុន , យ៉ន យ៉ុន នេះតាមដែលលោកស្រីដឹងតើឈ្មោះនេះជាឈ្មោះរបស់អ្នកណាម្នាក់ក្នុងក្រុមគ្រួសាររបស់លោកស្រីទេ? តើវាឆ្លុះបញ្ចាំងពីព័ត៌មានទាក់ទងទៅឪពុករបស់លោកស្រីទេ ឬក៏ជាឈ្មោះមួយដាច់ដោយឡែកមិនស្ថិតនៅក្នុងនាម

ត្រកូល ឬក៏សមាជិកក្រុមគ្រួសារនោះ? ខ្ញុំសូមបញ្ជាក់បន្ថែម ។ ក្នុងនេះលោកស្រីបានបញ្ជាក់ជាច្រើនដងថា ឪពុករបស់លោកស្រីត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៧ ប៉ុន្តែខ្ញុំពិនិត្យ ខ្ញុំឃើញថា ឈ្មោះ យ៉ានយ៉ន ត្រូវបានគេដាក់ឃុំឃាំងនៅស-២១ នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦ បើសិនជាខ្ញុំយោងទៅរកបញ្ជីអ្នកទោសរួមដែលកែតម្រូវដោយសហព្រះរាជអាជ្ញាជាពិសេសនៅក្នុងទំព័រ 003301113 យើងអាចមើលឃើញថា មានឈ្មោះ យ៉ន យ៉ុន ដែលគេបញ្ជាក់ថាជាយុទ្ធជនដែលបានជាប់គុកនៅថ្ងៃទី៨ វិច្ឆិកា ឆ្នាំ១៩៧៦ ហើយត្រូវបានកម្ទេចនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៦ ត្រង់លេខ គាត់ជាមកពីកងពល៥០២ ។ អ៊ីចឹងគឺថានៅក្នុងកងពល៥០២ហ្នឹងជាកងពលរបស់គាត់ហ្នឹង ។ ខ្ញុំសួរសំណួរឡើងវិញតាមដែលលោកស្រីចាំ តើឈ្មោះនេះគឺជាឈ្មោះណាមួយក្នុងចំណោមក្រុមគ្រួសាររបស់លោកស្រីទេនៅក្នុងបញ្ជីអំមិញនេះ? បើសិនជាលោកស្រីមិនដឹងទេ គ្រាន់តែបញ្ជាក់ថាមិនដឹង ។

**ធ៖** គឺដែលអានអំមិញ គឺខ្ញុំអត់បានដឹងផង ។ ខ្ញុំ-- ប្អូននោះ បងប្អូនខ្ញុំស្លាប់នៅក្នុងឆ្នាំ១៩៧៧ រឿង ១៩៧៦ គឺយើងខ្ញុំអត់ដឹងផង អត់ដែលដឹង ។

**ស៖** នៅពេលលោកស្រីធ្វើការនៅស-២១ តើបុគ្គលិកស-២១ ដឹងដែរឬទេ ថាបងប្រុសពីរនាក់របស់លោកស្រីធ្វើការជាអ្នកយាមនៅស-២១ ឬក៏គ្រាន់តែជាអ្វីដែលលោកស្រីបានព្យាយាមលាក់កុំឲ្យគេដឹង?

[១០:២០:០៣]

**ធ៖** គឺបងប្រុសខ្ញុំបាននៅយាមនៅស-២១ នេះមែន ។ បានគេបញ្ជោគាត់ឲ្យវាយតាំងពីឪពុកខ្ញុំឡើងតាមបញ្ជោគេ ។

**ស៖** សំណួរខ្ញុំ គឺខុសពីអ្វីដែលលោកស្រីឆ្លើយ ខ្ញុំចង់ដឹងថាតើបុគ្គលិកស-២១ ដឹងដែរឬទេថាលោកស្រីជាប្អូនរបស់អ្នកយាមទាំងពីរនាក់នោះ ដែលធ្វើការនៅពេលនោះ?

**ធ៖** យុទ្ធជនខ្លះ យុទ្ធនារីខ្លះ គឺគេអាចដឹង ខ្លះក៏គេអាចមិនដឹង ព្រោះតែគេដឹងហ្នឹងហើយបានចាប់ ខ្ញុំដាក់ឃុំឃាំង បើគេអត់ដឹង ក៏គេអត់ប៉ាានចាប់ដល់ខ្ញុំ ។

**ស៖** ថាតើគេដឹងដោយរបៀបណា ដោយហេតុថាអ្វីដែលលោកប្រាប់យើងនោះ គឺថាលោកស្រីមិនប្រើឈ្មោះ នាមត្រកូលអី ដូចអ្នកនោះទៀតទេ លោកស្រីថា មិនប្រើជានាមត្រកូលទេ ដោយលោកស្រី ខ្លាចគេចាប់យកទៅសម្លាប់ ហើយក៏មិនចង់ឲ្យគេដឹងនូវអត្តសញ្ញាណ នាមត្រកូលពិតឲ្យគេដឹងដែរចុះហេតុអ្វីបានជាគេដឹង?

**ឆ៖** បានជាគេដឹងដល់យើងខ្ញុំហ្នឹង ព្រោះពួយើងខ្ញុំ ព្រមទាំងឪពុកយើងខ្ញុំនេះហើយជា អ្នកឲ្យគេដឹងជាមុន ព្រោះនៅកងពលជាមួយគាត់ ជាមួយពួខ្ញុំហ្នឹង ហើយនៅកន្លែងព័ស្តុភាជាមួយឪពុក ខ្ញុំអីហ្នឹង គេឲ្យមកនៅ នៅកន្លែងមន្ទីរឃុំឃាំងទួលស្លែងនេះតែម្តង ។ ម្ល៉ោះហើយគេស្គាល់ឈ្មោះខ្ញុំ ដឹងខ្ញុំកូនអ្នកនេះ កូនអ្នកនោះ គេដឹងប៉ុន្តែគេជួយលាក់ការណ៍ខ្ញុំដែរ គេអត់ប៉ានប្រាប់ ។ តាំងពីបងខាងកើតមកកាន់កាប់មកគេលាក់ការណ៍ឈ្មោះខ្ញុំរហូត គេមិនដែលបញ្ចេញឈ្មោះខ្ញុំទៅឈ្មោះ ណាំ ម៉ុន ទេគេ ហៅថា ចាន់ថា រហូត ។

**ស៖** តើលោកស្រីបានជួបអ្នកណាជាពិសេសដើម្បីឲ្យគេជ្រើសរើសធ្វើការនៅ ស-២១ នេះ តើលោកស្រីបានជួបអ្នកណាជាបុគ្គលិក ឬក៏ជាអ្នកដឹកនាំ ស-២១ ទេដើម្បីឲ្យធ្វើការងារជាពេទ្យនោះ?

**ឆ៖** គឺខ្ញុំអត់មានបានជួបអ្នកណាផង ជួបតែក្រុមពេទ្យរបស់យើងខ្ញុំទាំងបីនាក់ហ្នឹងតែម្តង គេចាប់ទាំងបីហ្នឹងចេញតែម្តងទៀត គឺក្រោយពីហ្នឹងខ្ញុំអត់ដែលបានជួបផង ។

**ស៖** សូមអរគុណលោកស្រី! ដែលលោកស្រីបានព្យាយាមឆ្លើយនូវសំណួរទាំងអស់នេះ គឺថាដែលអាចធ្វើឲ្យលោកស្រីមានការលំបាក ប៉ុន្តែយើងយល់ថាចាំបាច់ដើម្បីសួរទៅលោកស្រី ។

លោកប្រធានខ្ញុំមិនមានសំណួរអ្វីទៀតទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះគិតថាត្រូវសម្រាក អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងដប់និងសែសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចពិភាក្សាតទៅទៀត ហើយមន្ត្រីតុលាការសម្របសម្រួលដើម្បីឲ្យលោកស្រី ណាំ ម៉ុន បានទទួលនូវកន្លែងសម្រាកឲ្យបានសមរម្យ ។ ម៉ោងដប់ និងសែសិបនាទី អញ្ជើញចូលវិញ ។

*[សវនាការសម្រាកពីម៉ោង១០:២៤នាទី ដល់ម៉ោង១០:៤៤នាទី ]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះណាំ ម៉ុន ជាបន្ត ហើយមុននឹងជូនវេទិកានេះទៅតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូម

ជម្រាបជូនដល់សាធារណជន និងអ្នកចូលរួមនៅក្នុងដំណើរសវនាការថ្ងៃនេះបានយល់ និងបានជ្រាបថាលោកស្រីម្នាក់ដែលអង្គុយនៅក្បែរដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ណាំ ម៉ុន នោះគឺគាត់ឈ្មោះ ពៅ ម៉ាលីន ។ គាត់អញ្ជើញមកពីអង្គការជំនួយផ្លូវចិត្ត ដែលភាសាកាត់គេហៅថាអង្គការ *TPO* ដែលអង្គជំនុំជម្រះអញ្ជើញគាត់ដើម្បីធ្វើការសម្របសម្រួលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ណាំ ម៉ុន ដែលគាត់មានបញ្ហា មានការរំជួលចិត្តខ្លាំងកន្លងមកនេះ ដើម្បីសម្រួលឲ្យដំណើរការនីតិវិធីប្រព្រឹត្តទៅបានល្អ ។ អាស្រ័យហេតុនេះសូមជ្រាប និងសូមយល់អំពីបញ្ហានេះ ។

ជាកិច្ចបន្តអង្គជំនុំជម្រះសូមប្រគល់វេទិកានេះទៅតំណាងសហព្រះរាជអាជ្ញា បើមានសំណួរអ្វីពាក់ព័ន្ធជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះសូមអញ្ជើញ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ។ តំណាងសហព្រះរាជអាជ្ញាសូមការអនុញ្ញាតពីលោកប្រធានអង្គជំនុំជម្រះផងដែរ ដើម្បីនឹងបង្ហាញនូវរូបភាពមួយទៀត ដែលស្ថិតនៅក្នុងឧបសម្ព័ន្ធមួយដែលមានលេខ D48/2 ។ រូបភាពនេះ គឺជារូបភាពដែលបានថតយកពីសារមន្ទីរទួលស្លែង ដែលជារូបភាពពិតដើម្បីបង្ហាញជូនលោកស្រី ណាំ ម៉ុន ឲ្យបានឃើញ ហើយនិងចងចាំនូវអ្វីដែលលោកស្រីបានធ្វើការនាសម័យកាលនោះ ។ អ៊ីចឹងសូមអនុញ្ញាតលោកប្រធាន ដើម្បីឲ្យខាងសោតទស្សន៍បង្ហាញរូបភាពនៅក្នុង D48/2 ហ្នឹង ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងមន្ត្រីសោតទស្សន៍ដាក់បញ្ចាំងនូវឯកសារដែលមានលេខD48/2 លើអេក្រង់ទូរទស្សន៍។

[១០:៤៧:០៥]

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** លោកស្រី ណាំ មុន លោកស្រីបាន-- នេះគឺជារូបភាពសារមន្ទីរទួលស្លែងបច្ចុប្បន្ននេះ ដែលពីមុនគេហៅថាមន្ទីរស-២១ ដែលចៅក្រមស៊ើបអង្កេតបានថតយករូបភាពនេះឡើងវិញ នៅក្នុងអំឡុងពេលធ្វើការស៊ើបអង្កេតនោះ ។ តើលោកស្រីនៅពេលនេះ សូមលោកស្រីអាចបញ្ជាក់ជូនអង្គជំនុំជម្រះឡើងវិញបានទេថា នេះគឺជាអគារដែលយើងបានថតយកពីទិសខាងកើតទៅ ហើយជាអគារនៅខាងឆ្វេងដៃបំផុតនៃរូបភាពនេះ គឺជាអគារអក្សរ A ហ្នឹង គេហៅអក្សរ “ក” អគារដែលមានអក្សរ B នេះគេហៅអគារអក្សរ “ខ” បន្ទាប់មកអគារ E ហ្នឹង “គ” បន្ទាប់មក “ឃ” និង-- “ឃ” គឺអក្សរ D “ក,ខ,

គ,ឃ" និងចុងបំផុតគេហ្នឹងគឺជាអក្សរ "ង" ។ ហើយនៅខាង-- នៅក្នុងរូបភាពនេះ នៅខាងមុខ នៅខាងក្រោមអគារអក្សរ "ខ" នុំង ដែលមានអក្សរ B ហ្នឹង លេខពីររាប់ពីឆ្វេងដៃមកហ្នឹង កន្លែងហ្នឹងគឺជាខ្លោងទ្វារបច្ចុប្បន្នហ្នឹង ហើយនៅសម័យកាលនោះ ក៏ជាខ្លោងទ្វារធំរបស់សារមន្ទីររបស់ស-២១ ដែរ ។

សូមលោកស្រីបញ្ជាក់ឡើងវិញថា ទីកន្លែងណាដែលជាអគារសម្រាប់ឃុំឃាំងអ្នកទោសធម្មតា អគារឃុំឃាំងពិសេសរបស់កម្មាភិបាល ហើយនិងអគារណាមួយ ជាអគារដែលដាក់ឪពុករបស់លោកស្រី ហើយអគារណាមួយដែលលោកស្រីធ្លាប់បានបម្រើការជាពេទ្យនៅទីនោះ?

**ឆ៖** គឺអគារទាំងនេះ គឺខ្ញុំអាចមើលយល់ខ្លះ គឺអគារទៅពីហ្នឹងទៅខាងស្ដាំដៃ គឺអគារយើងខ្ញុំដែលនៅព្យាបាល ។

**ស៖** ហើយអគារនុំងឯងជាអគារពិសេសសម្រាប់ដាក់កម្មាភិបាលហ្នឹងឬ?

**ឆ៖** ហ្នឹងពិតមែនហើយ ។

**ស៖** ចុះអគារ១អក្សរ "C" ហ្នឹង បន្ទាប់ពីអគារដាក់កម្មាភិបាលហ្នឹង អគារដាក់--?

**ឆ៖** គឺអគារមួយនោះ គឺយើងខ្ញុំអត់ដឹងថាគេដាក់អីផង ព្រោះយើងខ្ញុំគេឲ្យដើរតែអគារមួយ ។ នៅក្នុងបរិវេណនោះ គឺយើងខ្ញុំអាចបម្រើបានតែអគារមួយទេ អគារក្រៅពីនុំងយើងខ្ញុំអត់ដឹងផង ។

**ស៖** សូមអនុញ្ញាតពីលោកប្រធានអង្គជំនុំជម្រះ ដើម្បីឲ្យគេកត់សម្គាល់នៅក្នុងប្រតិចារឹកថា អគារ "D" ហ្នឹង គឺជាអគារដែលឈ្មោះ ណាំ ម៉ុន ហ្នឹងបានធ្វើការនៅទីនោះក្នុងសម័យកាល--

**ប្រធានអង្គជំនុំ៖**

បើកមីក្រូ ។

[១០:៥០:៤៨]

**សួរដោយលោកតាន់ សេណារ៉ុង៖**

**ស៖** នៅក្នុងឯកសារដែលមានលេខ D49/13 នេះគឺជារបាយការណ៍របស់-- និងជាលិខិតរបស់-- របាយការណ៍របស់ចៅក្រមស៊ើបអង្កេតហ្នឹងបានបញ្ជាក់ថា មានផ្ទះដែលនៅពីមុខ និងច្រកចូលរបស់សារមន្ទីរទួលស្លែងនេះ គឺជាអតីតផ្ទះពេទ្យដែលលោកស្រីហ្នឹងហាក់ដូច-- ប្រហែលជាធ្វើនៅទីនុំង ។ តើលោកស្រីអាចបញ្ជាក់បានទេថា ផ្ទះខាងមុខហ្នឹង ដែលស្ថិតនៅលើផ្លូវ ដែលលោកស្រីបានបញ្ជាក់នៅលើផ្លូវ៣-- ដែលបច្ចុប្បន្នគេហៅផ្លូវ១១៣ ហ្នឹង ថាផ្ទះទាំងពីរហ្នឹងប្រហាក់ប្រហែលថា ជាផ្ទះដែល

លោកស្រីហ្នឹងបានសម្រាក និងធ្វើការនៅទីនោះមែនទេ?

**ផ៖** ជាការពិតហើយ ជាផ្ទះនោះហើយដែលយើងខ្ញុំសម្រាកនៅគ្នាបីនាក់នោះ ។

**ស៖** ផ្ទះហ្នឹងក្នុងដំបូលណាមួយៗរបស់-- ពណ៌លឿង ដំបូលដែលមានពណ៌លឿង ឬក៏ដំបូលដែលមានពណ៌ស្រអាប់បន្តិចនៅប៉ែកខាងក្រោមអក្សរ អគារឆ្វេងដៃគេបង្អស់គឺអក្សរ “A” ហ្នឹង?

**ផ៖** អគារនោះ គឺមានដំបូងរាងក្រហមស្រអាប់ ។

**ស៖** អរគុណ ។ សំណួរបន្ទាប់ជូនលោកស្រី សូមអញ្ជើញខាងក្រុមសោតទស្សន៍ត្រឡប់រូបភាពហ្នឹងចូលរូបភាពដើមនេះ ។ សំណួរបន្ទាប់ ចំពោះលោកស្រីថា នៅក្នុងរយៈកាលដែលលោកស្រីបានធ្វើការនៅមន្ទីរស-២១ ហ្នឹងតើលោកស្រីធ្លាប់ស្គាល់កម្មាភិបាលណាខ្លះដែរទេនៅទីនោះ? អាចចាំឈ្មោះបានទេ?

**ផ៖** គឺកាលយើងខ្ញុំរស់នៅក្នុងស-២១ ព្រមទាំងគុកទួលស្លែងនេះ គឺយើងខ្ញុំរស់នៅ អ្នកថ្មីគឺយើងខ្ញុំអត់បាន-- ស្គាល់តែ-- ដឹងតែគេហៅ ប៉ុន្តែ យើងខ្ញុំមិនអាចស្គាល់ឈ្មោះគេបាន ឮតែគេហៅបងខាងកើតហ្នឹង គឺខ្ញុំស្គាល់តែឈ្មោះបងខាងកើត ប៉ុន្តែដល់ឈ្មោះគេក្រៅក៏ខ្ញុំអត់ដែលស្គាល់ ខ្ញុំស្គាល់តែបងប្អូនខ្ញុំទាំងអស់ហ្នឹង ។

**ស៖** ចុះឥឡូវនេះ នៅក្នុងបន្ទប់សវនាការនេះ លោកស្រីអាចប្រាប់អង្គសវនាការបានទេថា បងខាងកើតហ្នឹង គឺជាលោក កាំង ហ្គេកអ៊ាវ ដែលមានឈ្មោះហៅ ឌុច ស្លៀកពាក់អាវស នៅក្នុងបន្ទប់សវនាការហ្នឹងមែនទេ? ដែលបងខាងកើតនាសម័យនោះនោះ?

[១០:៥៣:៤៦]

**ផ៖** ខ្ញុំបានតាមដានយូរមកហើយ គឺបងខាងកើតគឺនេះហើយ ។ ប៉ុន្តែ ពីបច្ចុប្បន្ននោះគឺគាត់មិនមែនរាងគាត់អ៊ីចឹងទេ គឺរាងគាត់គឺស្អាតជាងនេះដែរ ។ ប៉ុន្តែ នេះហើយជាបងខាងកើត គឺខ្ញុំអាចស្គាល់ច្បាស់តែម្តង ។

**ស៖** អរគុណលោកស្រី ចុះក្រៅពីបងខាងកើត តើលោកស្រីមានដែលស្គាល់អ្នកថតរូប អ្នកយាមនៅ-- អ្នកចុះបញ្ជីនានានៅក្នុងមន្ទីរស-២១ ហ្នឹងដែរទេ?

**ផ៖** គឺអ្នកថតរូប អ្នកអី គឺយើងខ្ញុំអត់បានស្គាល់ទេ នៅក្នុងស-២១ នេះ គឺយើងខ្ញុំអត់បានដើរទៅនិយាយស្តីទាក់ទងណា គឺវែងឆ្ងាយក្រៅភារកិច្ចផងខ្លួនឯងទេ ។ អត់ហ៊ានដើរលេងបន្តិចណាឆ្ងាយទេ ។

**ស៖** អរគុណលោកស្រី ។ សំណួរបន្ទាប់ជូនលោកស្រី ថាតើលោកស្រីដែលធ្លាប់ឃើញមានថ្នាក់ដឹកនាំផ្សេងក្រៅពីមន្ទីរស-២១ ហ្នឹងចូលទៅពិនិត្យនៅមន្ទីរស-២១ ហ្នឹងដែរឬទេ?

**ឆ៖** កាលពីបច្ចុប្បន្ននៅក្នុងឆ្នាំ៧៦ គឺខ្ញុំអាចឃើញបងខាងកើតហ្នឹងគឺនាំមានគ្នាបីប្អូននាក់ចូលនៅក្នុងស-២១ នៅក្នុងគុកទួលស្លែងនេះតែម្តង ឃើញតែម្តងនុ៎ង ។ ក្រៅពីហ្នឹងមកក៏ខ្ញុំឃើញគាត់កន្លះខែម្តង១តែប៉ុណ្ណឹង ។ ខ្ញុំមិនដែលឃើញភ្ញៀវណាចូលទៀតទេ ។

**ស៖** អរគុណលោកស្រី ពាក់ព័ន្ធហ្នឹងរូបថត ដែលលោកស្រីបានប្រគល់ជូនអង្គជំនុំជម្រះហ្នឹង ខ្ញុំសូមបញ្ជាក់ឡើងវិញ ថាតើរូបថតទាំងអស់នោះលោកស្រីបានទទួលដោយខ្លួនឯង ឬក៏លោកស្រី ត្រូវបានទទួលដោយអង្គភាពណាមួយដែលគេផ្តល់ជូន ហើយនៅពេលណាដែរលោកស្រី?

**ឆ៖** គឺរូបថតនេះយើងខ្ញុំខាងអង្គការហៅយើងខ្ញុំមករករូបថតឪពុកម្តាយ គឺយើងខ្ញុំខំស្វះស្វែងមករករូបថតឪពុកម្តាយ យើងខ្ញុំដឹងថា ឪពុកខ្ញុំស្លាប់នៅទីនេះ គឺខ្ញុំឈ្មុសឈ្មុលមកតាមរករូបថតទាល់តែឃើញនៅក្នុងពេលនេះ ។

**ស៖** អរគុណលោកស្រី ប្រសិនបើខ្ញុំស្តាប់មិនច្រឡំទេ លោកស្រីដូចជាធ្លាប់បានបញ្ជាក់ និងឆ្លើយជូនអង្គជំនុំជម្រះថា លោកស្រីធ្លាប់ឃើញគេបានសម្លាប់ឪពុកមារបស់លោកស្រីនៅក្នុងសារមន្ទីរទួលស្លែងហ្នឹងមែនទេ?

**ឆ៖** ជាការពិតណាស់ ខ្ញុំបានឃើញមែន ព្រោះថ្ងៃនោះ គឺម៉ោងប្រាំមួយល្ងាចហ្នឹង គឺយើងខ្ញុំឡើងទៅលើអគារជាន់ទីបី ខ្ញុំក្រឡេកមកឃើញគេវាយពូរបស់ខ្ញុំ-- ពូសែន, ពូអឿន តាកេត នេះ ប៉ុន្តែខ្ញុំកាលពីខ្ញុំនេះ គឺខ្ញុំអត់មានដាក់ទេ ពូរបស់ខ្ញុំទាំងអស់ ។ ប៉ុន្តែ អ្នកវ៉ៃហ្នឹងគឺបងខាងកើតនេះតែ-- ផ្ទាល់តែម្តងគឺវ៉ៃនឹងដែកប្រវែងប្រហែលជាកន្លះម៉ែត្រប៉ុនកដៃ វ៉ៃនៅក្រោមដើមដូងក្រៅអគារ ។

[១០:៥៧:១៣]

**ស៖** សូមលោកស្រីបញ្ជាក់ឡើងវិញ ថាលោកស្រីនៅអគារណាមួយ ។ សូមការអនុញ្ញាតពីលោកប្រធានអង្គជំនុំជម្រះ ដើម្បីត្រឡប់ទៅរូបភាពដែលខ្ញុំបានបង្ហាញជូនអង្គជំនុំជម្រះនៅក្នុង D48/2 អម្បាញ់មិញ ដើម្បីឲ្យសាក្សីហ្នឹងបញ្ជាក់ឡើងវិញថា គាត់ឈរនៅអគារណាមួយ? ហើយបានមើលទៅទិសណា? ហើយនៅចម្ងាយប៉ុន្មានពី-- ដែលលោកស្រីនៅជាន់ទីប៉ុន្មាននៃអគារណាមួយដែលបានមើលឃើញថាគេសម្លាប់ឪពុកមារបស់លោកស្រីហ្នឹង ដោយបងខាងកើតហ្នឹង? ហើយមានគ្នាប៉ុន្មាននាក់ក្រៅពីបងខាងកើត លោកស្រីដែលបានចងចាំហ្នឹង?

**ឆ៖** គឺអគារដែលយើងអាចដើរព្យាបាលអ្នកជំងឺនេះហើយជាអគារនេះ ដែលខ្ញុំនៅជាន់ទីលើហ្នឹង គឺខ្ញុំអាចមើលឃើញ មើលទៅនុំងឃើញបណ្ដើរអ្នកទោសចេញមកមាន-- ក្រៅរបងមានជិតដើមដូងមួយ គឺឲ្យពូរបស់ខ្ញុំទាំងពីរនាក់ហ្នឹង គឺលុតជង្គង់ចុះគឺវាយតែម្ដង សម្លាប់តែម្ដង ។ ហើយយើងខ្ញុំឃើញអ៊ីចឹង ខ្ញុំមិនហ៊ានមាត់ដែរ តក់ស្លុតតាំងពីនុំងមករហូត ។ នេះហើយបានហៅថា គាត់ពោលពាក្យថា "ធ្វើអីគឺមិនកើតទេ គឺពេទ្យៗហ្នឹងគឺអារីកអារាក (រឃើករឃាក) ។ អារីកអារាកមកពីមូលហេតុអី? មកពីគាត់ដែលសម្លាប់ឪពុកម្ដាយខ្ញុំ ព្រមទាំងពូរបស់ខ្ញុំផ្ទាល់ ខ្ញុំឃើញផ្ទាល់ទាំងភ្នែកតែម្ដង ។

**ស៖** អរគុណលោកស្រី នៅពេលនោះឃើញគាត់គ្នាប៉ុន្មាននាក់? ហើយនៅចម្ងាយពីកន្លែងជាន់ដែលលោកស្រីបានមើលហ្នឹងប្រហែលជាចម្ងាយប៉ុន្មានដែរ ល្ងាចអាចនៅមើលឃើញទេ ល្ងាចហ្នឹងម៉ោងប្រាំមួយហ្នឹង ទាំងខែៗហ្នឹងភ្លៀង ឬក៏ខែមានភ្លៀងធ្លាក់ទេ? ហើយម៉ោងប្រាំមួយហ្នឹងអាចមើលឃើញហើយនៅ ពន្លឺហ្នឹងអាចមើលច្បាស់ទេ? ហើយជ្រុងណាមួយបើទៅតាមរូបភាពដែលខ្ញុំបានបង្ហាញជូនលោកស្រីអំម្បាញ់មិញពីអគារ ដែលលោកស្រីធ្វើការហ្នឹង បញ្ជិតជ្រុងខាងណាដែរ?

**ឆ៖** គឺវ៉ៃនោះ នៅពីក្រោយអគារចំពីក្រោយតែម្ដង ។ ប៉ុន្តែ អ្នកទោសនោះមិនដឹងជាគាត់ដាក់បន្ទប់មួយណាទេ ឃើញបណ្ដើរចេញមកចម្ងាយពីអគារខ្ញុំនេះប្រហែលជាប្រាំម៉ែត្រ ដែលអគារខ្ញុំឈរនេះទៅ ។ ហើយនៅពេលដែលខ្ញុំឈរមើលនោះ គឺនៅភ្លឺល្អះៗទេ នៅមើលគ្នាស្គាល់ទេ មិនទាន់ជាយប់ណាស់ទេ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកស្រី ដែលបានឆ្លើយបំភ្លឺនូវសំណួររបស់ខ្ញុំ ។ ខ្ញុំអស់សំណួរលោកប្រធាន ហើយបញ្ជូនសំណួរបន្ទាប់ទៅសហការីរបស់ខ្ញុំ ។ អរគុណលោកស្រី ។

[១០:៥៩:៥៨]

**សួរដោយលោក អានីស អះម៉េត៖**

**ស៖** លោកស្រី ណាំ ម៉ុន នៅពេលដែលពូរបស់លោកត្រូវបានគេសម្លាប់នោះ ដែលមានវត្តមានឌុច នៅទីនោះ ថាមានអ្វីកើតឡើងបន្ទាប់ពីនោះទៅ?

**ឆ៖** គឺបន្ទាប់ពីសម្លាប់រួចហើយ គ្មានបាតុហេតុអីជាវែងឆ្ងាយទៅទៀតទេ គឺយើងខ្ញុំក៏វាភិតភ័យទៅ ក៏លែងមាត់លែងក លែងនិយាយទៅ ការងារអីក៏យើងខ្ញុំធ្វើអត់កើតតាំងពីថ្ងៃនោះតទៅ ។

**ស៖** យោងតាមលោកស្រី ថាតើជនជាប់ចោទគេប្រើអ្វី ដើម្បីសម្លាប់ពូរបស់លោកស្រី?

**ឆ៖** ប្រើដោយដំបងដែក ប្រវែងប្រហែលកន្លះម៉ែត្រ វ៉ៃចំកញ្ចឹងកងាប់ទៅ ។

**ស៖** ថាតើអ្នកទោសផ្សេងទៀត គាត់ប្រើរបស់ដូចគ្នានេះ ក្នុងការវាយប្រហារទៅលើពួកគេដែរ ឬទេ?

**ឆ៖** គឺយើងខ្ញុំអ្នកផ្សេងទៀត ក៏យើងខ្ញុំអត់បានតាមដានទេតាំងពីនោះមក តាំងពីក្រឡេកឃើញមក គឺយើងខ្ញុំអត់ដែលបានទៅទេ ព្រលប់ៗអី ខ្ញុំខ្លាចខ្លួនខ្ញុំ ខ្លាចគេវ៉ៃដែរ គឺអ្នកក្រៅពីហ្នឹង ក៏ខ្ញុំអត់បានឃើញ គេវាយហ្នឹងអីៗ ព្រោះខ្ញុំអត់ដឹងដែរ ។

**ស៖** លោកស្រីនៅស-២១ ជាងពីរឆ្នាំ លោកស្រីបានលើកថា លោកស្រីជួបជនជាប់ចោទតែពីរដងទេ ថាតើលោកស្រីដឹងតួនាទីរបស់ជនជាប់ចោទនេះមានតួនាទីអ្វីដែរនៅស-២១?

**ឆ៖** ចុះកាលនោះ កាលនុ៎ងខ្ញុំបានដេញដោលសួរគេដែរថា គេថាពួខ្ញុំក៏ឈប់ក្ដាប់ហើយ គេថាពួខ្ញុំហ្នឹងគេឈប់ក្ដាប់ហើយ គេយកបងខាងកើតមកក្ដាប់នៅទីនេះ ។ ខ្ញុំមិនបានសួរគេថា បងខាងកើតហ្នឹង គឺជាអ្នកណា ជាមួយណា អីមួយណា គេបង្ហាញថា ឈ្មោះថានេះទៅ ។ ដល់ខ្ញុំសួរគេទៅ គេថាឈ្មោះបងខាងកើតតែម្ដង គេអត់ស្គាល់ឈ្មោះថាស្អីទេ ។ ប៉ុន្តែ មិនដឹងជាគេកាន់ខាងស្អី ខ្ញុំអត់ដឹងៗថាគេកាន់ខាងគុកហ្នឹងផង ។ ឮតែគេហៅថាបងខាងកើតៗ ។ ដល់ពេលខ្ញុំតាមដានទៅបងខាងកើតនេះហើយ ជាសម្លាប់ឪពុកមាខ្ញុំ បងប្អូនខ្ញុំ ។ ខ្ញុំទើបដឹងថា គាត់អ្នកយាមគុកដែលសម្លាប់ពួខ្ញុំទេ បានខ្ញុំភ្ញាក់ខ្លួនថា គាត់ជាមេគុកទួលស្លែងនេះតែម្ដង ។

**ស៖** លោកស្រីដឹង-- លោកស្រីនិយាយថា លោកស្រីដឹងថាបងខាងកើតជាប្រធានស-២១ ប៉ុន្តែក្នុងពេលដែលលោកស្រីនៅស-២១ យូរនោះ តើលោកស្រីបានជួបបងខាងកើតនេះក្នុងស្ថានភាពផ្សេងទៀត ដែរឬទេ? ឧទាហរណ៍ថា លោកស្រីបានទៅផ្ទះគាត់ ឬក៏គាត់មកផ្ទះលោកស្រីដែរឬទេ?

**ឆ៖** ឯចំណែកបងខាងកើត គឺចាប់ផ្ដើមដំបូង គឺគេយកគាត់មកដំបូងនេះ គឺមានគាត់ហ្នឹង អាចដើរទៅមានជប់លៀងនៅផ្ទះពូរបស់ខ្ញុំអស់ប្រហែលជាពីរដងដែរ ។ ខ្ញុំឃើញៗ ប៉ុន្តែកាលនោះឡើយ គឺពួខ្ញុំគាត់អាចនៅក្ដាប់នៅក្នុងកងពលគាត់ហ្នឹង ក៏មកដំបូងក៏គាត់ទៅអបអរសាទរគ្នាទាំងអស់ហ្នឹង មិត្តភក្ដិល្អត្រឹមត្រូវទេ ។ គាត់គ្មានស្អីទេ ខ្ញុំបានឃើញ ។

**ស៖** លោកស្រីឃើញជនជាប់ចោទទៅផ្ទះរបស់ឪពុកមាររបស់លោកស្រី ហើយប្រសិនបើឪពុកមាររបស់លោកស្រីជាមិត្តភក្ដិរបស់ជនជាប់ លោកស្រីដឹងទេ ហេតុអ្វីបានជាជនជាប់ចោទសម្លាប់ឪពុកមាររបស់លោកស្រី?

**ឆ៖** គឺយើងខ្ញុំមិនដឹងជាមិត្រភក្តិ ឬមួយអបអរសាទរដើម្បីទទួលយកជ័យជម្នះបងខាងកើតហ្នឹង ដែលមកកាន់គុកហ្នឹង ក៏មិនដឹង គឺគាត់ស្គាល់ជាពួកម៉ាក់ក៏មិនដឹង ប៉ុន្តែឃើញគាត់ទៅ ។

**ស៖** លោកស្រីក៏បានលើកឡើងផងដែរថា សមមិត្តលន ឃើញការសម្លាប់ឪពុករបស់លោកស្រីតើលោកស្រីបានសួរសមមិត្ត លន ទេ ហេតុអ្វីបានជាគេសម្លាប់ឪពុករបស់លោកស្រី? ហើយអ្នកណាគេជាសម្លាប់នោះ?

**ឆ៖** គឺសម្លាប់ឪពុកខ្ញុំនេះ គឺមិត្តលន ប្រាប់ថា បងខ្ញុំហ្នឹង គេបញ្ជា ប៉ុន្តែមិនដឹងជាអ្នកណាមួយបញ្ជាឲ្យបងខ្ញុំទៅសម្លាប់ទេ ហើយគេឃើញបងខ្ញុំសម្លាប់ផ្ទាល់ហ្នឹងភ្នែក ដោយសារគេបញ្ជា ។

**ស៖** លោកស្រីបានប្រាប់តុលាការកាលពីម្សិលមិញ និងថ្ងៃនេះ លោកស្រីមិនមានប្រធានពេទ្យទេ ។ លោកស្រីលន និង ឃីម ធ្វើការនៅអង្គភាពពេទ្យនោះ ថាតើនរណាជាមេរបស់លោកស្រី? ហើយលោកស្រីទទួលបញ្ជាពីនរណា? ហើយលោកស្រីធ្វើការរាយការណ៍ទៅនរណាគេ?

**ឆ៖** គឺនៅក្នុងមួយចំណោមយើងខ្ញុំបីនាក់ហ្នឹង គឺមិត្តលន នេះហើយជាប្រធានតពីគេថ្នាក់លើមកទៀត មានតែមិត្តលនហ្នឹងទេ អាចយកថ្នាំអីមកឲ្យយើងខ្ញុំព្យាបាល ។

**ស៖** ថានរណាគេប្រធានរបស់ លន ហើយគាត់និយាយជាមួយនឹងនរណាគេដែរដែលនៅលើគាត់ដើម្បីទទួលបញ្ជាមកអនុវត្តន៍?

[១១:០៦:២៥]

**ឆ៖** គេបញ្ជាពីលើសមមិត្តលន ហ្នឹង គេនៅកន្លែងមន្ទីរនៅជិតប៉ុស្តិ៍វ៉ាឌ្យូលេខប្រាំយើងសព្វថ្ងៃនេះ គេមានឈ្មោះ វង់ ។ គេអ្នកលើហ្នឹងទៀត គេមេពេទ្យប្រចាំការនៅទីក្រុងភ្នំពេញនេះ ។

**ស៖** ថាតើលោកស្រីដឹងថាបុគ្គលដែលមេធំអំម្បាញ់មិញនេះ ធ្វើការឲ្យនរណាគេ? ហើយគាត់រាយការណ៍ទៅណាទៀតនៅលើគាត់?

**ឆ៖** គឺយើងខ្ញុំអត់ដឹងដែរ អត់បានតាមដាន ។ ដឹងតែថាគាត់យកថ្នាំឲ្យមិត្តលន ឲ្យតាមមិត្តលនមកនាំគ្នាមកព្យាបាលនៅក្នុងមន្ទីរហ្នឹង តែម្តង ។ មិនដឹងគាត់ទៅយកពីណាមកទៀត គឺខ្ញុំអត់ដឹង ។

**ស៖** តើក្នុងការងារជាពេទ្យ លោកស្រីៗបានធ្វើកត់ត្រាថា តើលោកស្រីមានអ្នកជំងឺណាខ្លះ? ហើយលោកស្រីបានទៅព្យាបាលនរណាខ្លះដែរឬទេ?

**ឆ៖** គឺយើងខ្ញុំអត់បានកត់ត្រាទុកទេ ឲ្យតែទៅដល់ឲ្យថ្នាំៗអ្នកជំងឺហ្នឹងទៅ គេវាយដំគាត់មកឈឺទៅ ក្តៅទៅ គ្រុនទៅ គឺយើងខ្ញុំចែកថ្នាំតាមនុំង ឲ្យយើងខ្ញុំកត់តាមសាច់ជំងឺ គឺអត់មាន ។

**សៈ** ជាពេទ្យ ថាលោកស្រីទទួលការណែនាំយ៉ាងម៉េចក្នុងការព្យាបាលអ្នកឈឺឲ្យទៅមានសុខ-ភាពស្រួលបួលឡើងវិញ ដើម្បីឲ្យពួកគេរស់ ដើម្បីផ្តល់ចម្លើយសារភាពនោះ តើមេរបស់លោកស្រីបង្គាប់បញ្ជាលោកស្រីឲ្យធ្វើយ៉ាងម៉េចខ្លះ ក្នុងការងារជាពេទ្យនោះ?

**ឆៈ** គាត់បញ្ជាខ្ញុំឲ្យខិតខំ ឲ្យអ្នកជំងឺហ្នឹងព្យាបាលឲ្យមានកម្លាំងកំហែង គ្រាន់នឹងសួរចម្លើយហ្នឹងគឺយើងខ្ញុំក៏មិនដឹងដែរ អ្នកឱនទ្រោមហើយ ក៏គេអត់ឲ្យថ្នាំគាត់លេបថែមទៀត ឲ្យតែអ្នកគ្រាន់បើ ។ អ្នកណាគ្រាន់បើ គឺយើងខ្ញុំអាចចែកឲ្យ ។

**សៈ** ប្រសិនបើខ្ញុំយល់ត្រឹមត្រូវពីលោកស្រី លោកស្រីត្រូវបានគេឲ្យទៅព្យាបាលអ្នកដែលមិនទាន់ផ្តល់ចម្លើយ ។ ថាតើអ្នកដែលបានផ្តល់ចម្លើយឲ្យគេរួចហើយនោះ ប្រសិនបើពួកគេឈឺតើលោកស្រីត្រូវបានគេចាត់តាំងឲ្យទៅព្យាបាលពួកគេដែរឬទេ?

**ឆៈ** ដល់ពេលផ្តល់ចម្លើយរួចហើយ ដល់ពេលគេឈឺ គឺពួកគេឲ្យខ្ញុំយកថ្នាំទៅឲ្យបន្ថែមទៀត។ ទុកដល់ថ្ងៃក្រោយមួយតទៀត ។

**សៈ** តុលាការបានស្តាប់ភស្តុតាងអ្នកដែលនៅរស់នោះ គឺគេបានបង្រៀនឲ្យធ្វើការវះកាត់ ថាតើលោកស្រីដឹងអំពីការពិសោធន៍ធ្វើការវះកាត់ទៅលើអ្នកដែលរស់រានមានជីវិតនៅពេលដែលពួកគេជាប់ឃុំដែរឬទេ?

[១១:១០:០៥]

**ឆៈ** អត់ដែលបង្រៀនផង ។ អត់ដឹង ។

**លោក អានីស អះម៉េត៖**

សូមអរគុណច្រើន លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំពុំមានសំណួរទៀតទេ ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីមានឱកាសនៅក្នុងការសួរដេញដោលដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។ ហើយតើមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីរបស់ក្រុមពីរហ្នឹង មានអាទិភាពនៅក្នុងការសួរសំណួរដោយប្រើពេលវេលាទាំងប៉ុន្មានដែលបានចែកឲ្យនេះសម្រាប់សួរកូនក្តីរបស់លោកស្រី ហើយនៅសេសសល់ គឺប្រគល់ទុកទៅឲ្យមេធាវីក្រុមផ្សេង ។ តើអនុវត្តនូវរបៀបនេះដដែល ឬយ៉ាងម៉េច? មុននឹងធ្វើការតាំងសំណួរ

សូមឆ្លើយនូវសំណួរនេះជាមុន ។

**សួរដោយលោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី៖**

អរុណសួស្តីលោក លោកស្រីចៅក្រម លោកប្រធាន ។ ត្រឹមត្រូវហើយ គឺយើងអនុវត្តន៍នីតិវិធីដដែលដូចដែលយើងធ្លាប់ធ្វើពីមុន ។

**ស៖** លោកស្រី ណាំ ម៉ុន ខ្ញុំមានសំណួរបន្ថែមមួយចំនួនទៀតជូនលោកស្រី ។ ជាដំបូង តើលោកស្រីអាចពិពណ៌នាអំពីការជាប់សាច់ញាតិ និងទំនាក់ទំនងជាមួយនឹងពូរបស់លោកស្រីឈ្មោះ អ៊ិនដែរឬទេ? ពេលដែលលោកស្រីរស់នៅភ្នំពេញគឺ អឿន, ពូអឿន ។

**ឆ៖** គឺយើងខ្ញុំ កាលពីយើងខ្ញុំរស់នៅទីក្រុងភ្នំពេញ គឺយើងខ្ញុំរស់នៅជាមួយ ពូអឿន នេះហើយ នេះហើយបានខ្ញុំអាចឃើញបងដែលទៅជប់លៀងនៅផ្ទះបងអឿន របស់ពូយើងខ្ញុំនេះ ។

អឿន នេះហើយជា គាត់ស្លាប់នៅក្នុងគុកទួលស្លែងនោះ ជាពូបង្កើតរបស់យើងខ្ញុំ ខ្ញុំរស់នៅជាមួយ ។

**ស៖** តើនៅចុងក្រោយនរណាគេណែនាំលោកស្រី ហើយបញ្ជូនលោកស្រីទៅធ្វើការរៀនវគ្គពេទ្យនោះ?

**ឆ៖** ពីមុនយើងខ្ញុំរស់នៅជាមួយឪពុកម្តាយយើងខ្ញុំ។ ម្តាយឪពុកយើងខ្ញុំឲ្យខ្ញុំទៅនៅជាមួយពូអឿន ។ ពូអឿន នេះហើយអ្នកនាំឲ្យខ្ញុំទៅរៀនធ្វើពេទ្យនៅប្រចាំការនៅគុកទួលស្លែងនេះតែម្តង ។

**ស៖** ថាតើនៅពេលដែលផ្ទះរបស់លោកស្រី-- ផ្ទះពូរបស់លោកស្រី នៅពេលដែលលោកស្រីនៅផ្ទះពូលោកស្រីនោះ តើលោកស្រីនៅបន្តរៀនពេទ្យហ្នឹងដែរឬទេ?

**ឆ៖** កាលខ្ញុំនៅផ្ទះពូខ្ញុំ គឺខ្ញុំនៅរៀនពេទ្យហ្នឹង គឺខ្ញុំដេកនៅឯកន្លែងពេទ្យនោះទេ ។ ខ្ញុំនៅរយៈមុនខ្ញុំទៅរៀនចុះឡើងៗមកផ្ទះពូយើងខ្ញុំហ្នឹង ដល់ពេលចុងក្រោយដែលគាត់ឲ្យខ្ញុំមកនៅខាំក្រាបនៅកន្លែងគុកទួលស្លែងនេះ គឺយើងខ្ញុំអត់បានទៅផ្ទះពូនុំងទៀតទេ ។

**ស៖** តើលោកស្រីទៅលេង ឬក៏គេកោះប្រជុំនៅផ្ទះរបស់ ពូអឿន របស់លោកស្រីដែរឬទេ នៅពេលដែលលោកស្រីទទួលការងារជាពេទ្យនៅស-២១ ហើយនោះ?

**ឆ៖** គឺខ្ញុំទទួលនេះ ហើយដែលខ្ញុំបានទៅលេងនៅផ្ទះពូរបស់ខ្ញុំដែរ ទៅជួបគាត់ជាញឹកញាប់ម្តងជាពីរដងហើយ បានគេចាប់គាត់ ។ កាលពីដើមឡើយខ្ញុំរស់នៅៗនោះហើយ ដែលថា ពូខ្ញុំជប់លៀងនៅអ្នក-- បងខាងកើតនោះ គឺកាលនោះខ្ញុំទើបតែរៀនពេទ្យទេ ខ្ញុំអាចមកលេងផ្ទះពូខ្ញុំបានជាម្តងៗ ។

[១១:១៥:00]

**ស៖** ថាតើលោកស្រីបានចូលរួមជួបប្រជុំគ្នាជាមួយនឹងគ្រួសារដែរឬទេ នៅក្នុងផ្ទះរបស់ ពូអឿន ដែលបានលើកឡើងពិភាក្សាគ្នាអំពីការរត់គេចខ្លួនអីផ្សេងៗនោះ?

**ឆ៖** ខ្ញុំបន្ទាប់មក គឺយើងខ្ញុំអាចទៅផ្ទះពូខ្ញុំជាមួយដងទៀត បានពូខ្ញុំមួយឈ្មោះ សែម គាត់នៅឯវាលវង់កប៉ាល់ហោះ នាំគ្នាពិភាក្សាគ្នាប្រុងរត់ទៅប្រទេសក្រៅ ប៉ុន្តែពូខ្ញុំ ឈ្មោះ អឿន នេះ ព្រមទាំងឪពុកខ្ញុំ ព្រមទាំងខ្ញុំផ្ទាល់ គឺអត់បានរត់ទៅទេ គឺមានតែពូមួយទេ អាចនៅស្រុកអាមេរិកសព្វថ្ងៃនេះ គាត់រត់ទៅរួចឈ្មោះ សែម ។

**ស៖** តើលោកស្រីនៅទាក់ទងជាមួយនឹង ពូសែម របស់លោកស្រីដែរឬទេ?

**ឆ៖** គឺយើងខ្ញុំសព្វថ្ងៃនេះ គឺពូខ្ញុំអាចទាក់ទងខ្ញុំ ក្នុងមួយខែ គឺគាត់តេមកបានម្តង ឬមួយពីរតែប៉ុណ្ណោះ ។

**ស៖** តើលោកស្រីត្រូវបានគេ ប្រាប់ព័ត៌មានអំពីការចាប់ខ្លួន ពូអឿន របស់លោកស្រីដែរឬទេ? ប្រសិនបើប្រាប់អំពីការចាប់ខ្លួនពូលោកស្រីនោះ តើអ្នកណាគេជាអ្នកប្រាប់?

**ឆ៖** គឺគាត់អត់បានដឹងខ្លួនទេ មានតែពូ សែម ទេ មកប្រាប់ថាយើងត្រូវគេចខ្លួនទៅ គេចាប់ផ្តើមសម្លាប់មនុស្សហើយ យើងគេខាងនិរតីចូលហើយ គឺសម្លាប់មនុស្សហើយ គឺយើងអាចគេចខ្លួនទៅ ។ប៉ុន្តែ ពូខ្ញុំគាត់អត់ជឿ គឺគាត់អត់ទៅ អត់ទៅៗគាត់ទៅតែគាត់ទៅ រួចខ្លួនតែគាត់ទៅសព្វថ្ងៃហ្នឹងអាអ្នកនៅហ្នឹងស្លាប់ទាំងអស់ ។

**ស៖** តើគេបានបង្ហាញនិងប្រាប់លោកស្រីទេ នៅពេលដែលពូ អឿន លោកស្រីនោះ ត្រូវបានគេចាប់ខ្លួន?

**ឆ៖** គឺគេអត់បានបង្ហាញអីខ្ញុំផង ស្រាប់តែឃើញ តែគេសម្លាប់ហើយ ។ កាលពីចាប់ទៅដើមដំបូងមិនដឹងគេចាប់គាត់ទៅដាក់គុកមួយណា ព្រោះខ្ញុំរកសង្កេតមើលដែរ ក៏អត់ដឹង ស្រាប់តែដល់ថ្ងៃគេសម្លាប់គាត់ហ្នឹង គឺក្រឡេកមើលទៅឃើញម្តង ឃើញថាគាត់ម្តង ឃើញគេប្រសាតខោអាវគាត់អស់ហើយគាត់លុតជង្គង់ ហើយវាយនឹងដែកហ្នឹង ក្រឡេកទៅពូរបស់ខ្លួនឯង ។

**ស៖** ខ្ញុំព្យាយាមនឹងធ្វើការសួរឡើងវិញ ។ តើលោកស្រីបានឃើញ និងលោកស្រីនៅទីនោះដែរឬទេ? នៅពេលដែលគេមកយកលោកពូរបស់លោកស្រីទៅនោះ តើលោកស្រីមានវត្តមាន ឬក៏នៅទីនោះដែរឬទេ?

**សៈ** ខ្ញុំកាលពេលគេចាប់គាត់ពីផ្ទះទៅ គឺយើងខ្ញុំអត់បាននៅផ្ទះជាមួយគាត់ បាននៅទៅលេងជាមួយនឹងគាត់ហ្នឹង ហើយនឹងគេ ក៏ហៅគាត់ទៅ ។ គេអត់បានចាប់ចងគាត់ពីផ្ទះមកទេ គេបណ្ដើរគាត់មក ក៏អត់ចង ហើយយើងខ្ញុំក៏អត់ដឹងថា គេចាប់គាត់ដែរ ដឹងតែគេហៅបណ្ដើរគាត់មក ។

[១១:១៨:៥៦]

**សៈ** នៅពេលណាដែលលោកស្រីបានឃើញគាត់នោះ ជាលើកដំបូងនៅស-២១?

**ឆៈ** គឺលើកដំបូងដែលខ្ញុំបានឃើញគាត់ជាប់ឃុំឃាំង ហើយជាលើកដំបូងនោះ គឺខ្ញុំដើរ មិនអាចទៅព្យាបាលទៅអីឯណាទេ គឺយើងខ្ញុំដើរជាមួយសមមិត្ត លន ទៅមន្ទីរគេធ្លាប់ព្យាបាលនោះ ។ ទៅដល់ឮគេថា នេះហើយជាគុកកម្មាភិបាល គុកអ្នកធំ គឺផ្ទះគាត់នោះ គឺគេដាក់គាត់នោះផ្ទះតូច អគារតូចទេ ទទឹងថ្ងៃ បន្ទប់នុ៎ង ក៏បន្ទប់តូចដែរ ។ ហើយខ្ញុំក៏អត់បានតាមដានមើល គាត់តទៅទៀតទេ ព្រោះខ្ញុំជាប់សាច់ឈាមដែរ ខ្លាចគេតាមដាននាងខ្ញុំ ក៏យើងខ្ញុំឈប់ដឹង ឈប់ឮទាំងពីថ្ងៃនោះទៅ ។ ដល់ចុងបំផុតបានឃើញគាត់លើកទីពីរ គេសម្លាប់គាត់តែម្ដង ។

**សៈ** តើលោកស្រីបានសង្កេតទៅលើស្ថានភាពរបស់គាត់នៅផ្ទះដែរឬទេ នៅពេលដែលលោកស្រីនោះឃើញគាត់នៅស-២១? ខ្ញុំសូមកែតម្រូវ គឺឃើញស្ថានគាត់យ៉ាងម៉េច ស្ថានភាពសុខភាពគាត់?

**ឆៈ** គឺសុខភាពគាត់ដែលខ្ញុំអាចឃើញហ្នឹង គឺគាត់នៅរឹងមាំ ក្លាហាននៅឡើយទេ ដល់គាត់ទ្រុឌទ្រោម ក៏យើងខ្ញុំអត់បានជួបគាត់ដែរ ។

**សៈ** តើលោកស្រីចាំដែរឬទេថា ពេលដែលលោកស្រីឃើញគាត់មិនមានជំងឺ ហើយក្រោយមកឃើញគាត់ថា បងខាងកើតវ៉ៃគាត់ រហូតដល់ស្លាប់នោះ ថាតើលោកស្រីបានឃើញគាត់ហ្នឹងប៉ុន្មានដងក្នុងអំឡុងពេលហ្នឹង?

**ឆៈ** នៅអំឡុងពេលដែលគាត់បានជាប់ទោសហ្នឹង គឺយើងខ្ញុំឃើញពីរដង ទាំងថ្ងៃស្លាប់នេះតែម្ដង ។

**សៈ** ខ្ញុំត្រឡប់ទៅស្ថានភាពដែលលោកស្រីបានឃើញការសម្លាប់ ពូអឿន របស់លោកស្រី ។ ថាតើនៅពេលស្លាប់នោះ មានអ្នកផ្សេងនៅទីនោះដែរឬទេ នៅពេលដែលបងខាងកើត ហ្នឹងវាយគាត់រហូតដល់ស្លាប់ហ្នឹង?

**ឆៈ** គឺកាល ខ្ញុំឃើញដែលវាយគាត់នោះ គឺមានតែក្រុមគាត់ហ្នឹង មានតែបីនាក់ ទាំងគាត់ទេ ពីរនាក់នោះឈរស្ពាយកាំភ្លើង ហើយគាត់មួយកាន់ដៃតែប៉ុណ្ណោះឯង ។

[១១:២២:២២]

**សៈ** តើការសម្លាប់នោះ គឺធ្វើឡើងនៅក្នុងបរិវេណស-២១ ឬក៏ការសម្លាប់នោះគឺសម្លាប់នៅក្រោយរបងមន្ទីរនេះ?

**ផៈ** កាលពីសម្លាប់នោះ នៅក្រៅរបងបរិវេណនោះ ក្រោមដើមដូង ។

**សៈ** តើលោកស្រីអាចសង្កេតឃើញដែរឬទេ មានអ្វីកើតឡើងក្រោយពីគេសម្លាប់ពូរបស់លោកស្រី និងដំបងដែកហ្នឹង តើមានអ្វីកើតឡើងទៀតបន្ទាប់ពីនុំង?

**សៈ** គឺខ្ញុំសង្កេតមើលតាំងពីនោះមកចេះតែឮមនុស្សស្រែកនិងក្មេងយំ ប៉ុន្តែយើងខ្ញុំអត់បានដឹងគេវាយ ឬអត់ ក៏អត់បានឃើញ អត់បានដឹងទេ គ្រាន់តែឮសំឡេងទេ ។

**សៈ** ខ្ញុំសូមរៀបចំសំណួររបស់ខ្ញុំឡើងវិញ នៅពេលដែល ពូអឿន គេសម្លាប់គាត់ហ្នឹង ក្រោយពីសម្លាប់នោះ តើគេធ្វើអីលើគាត់ទៀត? ថាតើគេយកចេញ គេយកគាត់ចេញ ហើយតើ បងខាងកើតហ្នឹងធ្វើអ្វីទៅលើគាត់នៅពេលដែលសម្លាប់ហើយនោះ?

**ផៈ** គឺកាលដើមឡើយនោះ ខ្ញុំឃើញតែស្លាប់ហ្នឹងទៅ ដល់ពេលព្រលឹមឡើងទៅ ខ្ញុំដើរទៅចែកថ្នាំទៀត ស្រាប់តែបាត់សាកសពនោះទៅ ខ្ញុំមិនដឹងអ្នកយកចេញ ឬមួយពីណា គឺខ្ញុំអត់ដឹង ។

**សៈ** តើលោកស្រីដឹងដែរឬទេ ថាគេយកសាកសពគាត់ហ្នឹងទៅណា?

**ផៈ** អត់បានដឹងថាគេយកទៅណាផង បើព្រលឹមឡើងខ្ញុំចេញមក បាត់សាកសពនោះបាត់ហើយមិនដឹងគេយកទៅកប់នៅទីណាផង ឃើញតែវ៉ៃស្លាប់នៅទីកន្លែងនោះតែម្តង ។

**សៈ** ខ្ញុំសូមចូលទៅដល់ការសម្លាប់ពូរបស់លោកស្រី គឺឈ្មោះ ពូខឿន ថាតើនរណាគេមានវត្តមាននៅទីនោះ នៅពេលដែលគេសម្លាប់ពូរបស់លោកស្រីហ្នឹង គឺពូកេត?

**ផៈ** ពូរបស់យើងទាំង ពូអឿន ទាំង ពូកេត ហ្នឹង គឺសម្លាប់ពេលតែមួយ គឺគ្មានអ្នកណាអាច--មានតែគ្នាគាត់ គ្នាបីនាក់ទាំង អ្នកវ៉ៃម្នាក់ អ្នកឈរពីរនាក់តែប៉ុណ្ណោះ គេអ្នកក្រៅមិនអាចមើលបានទេ មានតែខ្ញុំមើលឃើញពីលើអគារបីជាន់មក ក៏យើងខ្ញុំអាចមើលមកឃើញមួយភ្លែតហ្នឹង ក៏យើងខ្ញុំចុះចេញមក ។

**សៈ** តើការសម្លាប់ពូ កេត របស់លោកស្រីហ្នឹង នៅក្រៅរបងដូចគ្នាដែរឬទេ?

**សៈ** ចាស, ពីរនាក់ហ្នឹង គឺគេសម្លាប់នៅកន្លែងតែមួយទេ ពូអឿន នេះ គឺសម្លាប់នៅកន្លែងនុំងដែរ ពូកេត នេះ ក៏សម្លាប់នុំងដែរ ទាំងពីរនាក់តែម្តង ។

[១១:២៦:៥៩]

**ស៖** លោកស្រីបានជម្រាបសហព្រះរាជអាជ្ញាថា លោកស្រីបានឃើញ និងបានជួបបងខាងកើត រយៈពេលពីរអាទិត្យម្តង ។ តើលោកស្រីអាចជម្រាបដែរឬទេ នៅពេលដែលជួបគាត់នៅស-២១ នោះ បង ខាងកើត គាត់ធ្វើអី? ក្រៅពីការសម្លាប់ពូរបស់លោកស្រី តើគាត់ធ្វើអីទៀតនៅពេលដែលលោកស្រី ជួបគាត់?

**ឆ៖** ក្រៅពីគាត់សម្លាប់ពូខ្ញុំមក គឺខ្ញុំមិនដែលជាឃើញគាត់ធ្វើស្អីក៏មិនដឹងដែរ គឺខ្ញុំអត់បានតាម ដានប៉ុន្តែឃើញតែគាត់ចូលទៅ ដើរវេរ៉ជុំវិញទីធ្លានៅគុកទួលស្លែងនេះតែម្តង ឃើញដើរជុំវិញនៅក្នុង ទីធ្លានោះ ។ ពីរថ្ងៃអីចឹងទៅ បាត់ប្រហែលជាកន្លះខែ បានឃើញគាត់មកមួយសាទៀត បីថ្ងៃទៅបាត់ ប្រហែលមួយអាទិត្យបានឃើញគាត់មកមួយសាទៀត តែខ្ញុំឃើញតែប៉ុណ្ណឹង តែគាត់អនុវត្តធ្វើអី គឺយើង ខ្ញុំអត់បានឃើញផង ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកស្រី ស៊ីលឃី មុនពេលដែលលោកស្រីបន្ត ខ្ញុំមានសំណួរមួយដោយសារខ្ញុំមានភាពយល់ ច្រឡំ ។ ថាតើលោកស្រីបានលើកឡើងអំពី ពូកេត នេះ ខ្ញុំអត់ដឹងថា តើគាត់ធ្វើអីនៅពេលដែលនៅ ស-២១ ហើយគាត់មានមុខនាទីអ្វីខ្លះ? សូមឲ្យធ្វើការបញ្ជាក់បំភ្លឺបន្ថែមទៅលើចំណុចនេះដោយសារតែយើង មិនទាន់ទទួលព័ត៌មានពេញលេញនៅឡើយទៅលើចំណុចនេះ ។

**លោកស្រី ស៊ីលឃី ស្នូតហ្វ៊ីនស្ទី៖**

**ស៖** ខ្ញុំចង់សួរសំណួរមួយនេះទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដូច្នេះ តើលោកស្រីអាចរំឭក និងប្រាប់ទេថា នរណាគេទៅជា ពូកេត? ហើយលោកស្រីដឹងតួនាទី ឬក៏ដឹងថាគាត់ហ្នឹងធ្វើអីខ្លះ?

**ឆ៖** គឺពូកេត របស់យើងខ្ញុំនេះ ពូកេត នេះ គឺជាបង តាអឿន គាត់នៅកាន់កងពលហ្នឹងទាំង អស់គ្នា គាត់គ្មានភារកិច្ចធ្វើអី គាត់រួមរស់នៅជាមួយពូរបស់ខ្ញុំ ឈ្មោះ ពូអឿន ។ ហើយខ្ញុំបានតាមដាន ឃើញគាត់នេះ ដែលខ្ញុំពីមុនមក ពួកយើងខ្ញុំអត់បានដាក់ពាក្យបណ្តឹងជូនដល់តុលាការដែរ ដើម្បីថាយើង ខ្ញុំហ្នឹងខ្លាច ខ្លាចកាលណា យើងដាក់ពាក្យបណ្តឹងច្រើនផ្នែកអីចេះទៅ ខ្លាចខ្លួន ខ្លាចដល់មកដល់គេ សម្លាប់យើងខ្ញុំផុតពូជទៅ ម្ល៉េះហើយខ្ញុំអត់ហ៊ាន ។ ខ្ញុំមានការកោតក្រែង ចំពោះយើងខ្ញុំ ។

**ស៖** នៅពេលដែលលោកស្រីរស់នៅផ្ទះ ពូអឿន លោកស្រីក៏រស់នៅជាមួយនឹង ពូកេត ផងដែរ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ពាក្យហ្នឹងជាការត្រឹមត្រូវល្អ ។

**ស៖** ថាតើ ពូកេត គាត់បានចូលរួមពិភាក្សា នៅពេលដែលមានការនិយាយឡើងអំពីការរត់គេចខ្លួនដែរឬទេ? ឬក៏មានតែ ពូសែម ទេ ដែលគាត់បានដឹងទៅលើស្ថានភាពនេះ ហើយរត់គេចខ្លួនបាន?

**ឆ៖** នៅបញ្ហារត់គេចខ្លួននេះពូខ្ញុំ ពូសែម ទាំងអស់ ព្រមទាំងឪពុកខ្ញុំអី គឺដឹង ប៉ុន្តែថាដឹងដោយស្រពិចស្រពិល ហើយម្យ៉ាងគាត់អត់ប៊ានរត់ចោលគ្នា ចោលប្រពន្ធកូនគាត់ទេ មានតែពូខ្ញុំ ឈ្មោះពូសែមមួយទេ ដែលគាត់អត់មានប្រពន្ធ គាត់អាចរត់ទៅចោលប្រពន្ធគាត់បាន ។ ឯចំណែកដឹង គឺដឹងទាំងអស់គ្នាហ្នឹង ប៉ុន្តែគ្រាន់តែប្រុងប្រយ័ត្នរៀងខ្លួនតែប៉ុននុ៎ង ។

**ស៖** ប្រសិនបើលោកស្រីចាំអំពីការនិយាយប្រជុំគ្នាអំពីការរត់គេចខ្លួននោះ បន្ទាប់ពីការជួបប្រជុំនេះ គឺការប្រជុំនេះមានរយៈពេលប៉ុន្មានដែរ?

**ឆ៖** កាលពីគាត់ប្រជុំដែលនាំគ្នាប្រុងរត់ទៅនេះ គឺគាត់ប្រជុំ គាត់មកលេងតាំងពីម៉ោងប្រហែលជាប្រាំរហូតដល់ម៉ោងប្រាំបួនយប់ បានគាត់អាចវិលត្រឡប់ទៅវិញ ។

**ស៖** ពីពេលនោះមក ពេលការជួបប្រជុំនោះ ថាតើមានរយៈពេលប៉ុន្មាន ក្រោយពីប្រជុំនោះទើបមានការចាប់ខ្លួនពូទាំងពីររបស់លោកស្រីនោះ?

**ឆ៖** តាំងពីពូខ្ញុំមកហៅប្រជុំ ហើយរំលងរយៈប្រហែលបីថ្ងៃ ពូហ្នឹងក៏ឡើងកប៉ាល់ហោះទៅបាត់ ។ ក្រោយនោះមកទៀត ប្រហែលជាកន្លះក៏ចាប់ ពូអឿន និង តាកេត នេះតែម្តង ចំណែកឪពុកខ្ញុំក៏គេអត់ទាន់ចាប់ទេ ទាល់តែសម្លាប់ពីរនាក់ ។ ពីរនាក់ហ្នឹងសួរចម្លើយជិតស្លាប់ បានគេចាប់ឪពុកខ្ញុំមកជាបន្តទៀត ។

**ស៖** បានន័យថា ពូសែម របស់លោកស្រី បានឡើងយន្តហោះ ហើយចេញពីប្រទេសនេះ ។ បានន័យថា គាត់ចេញពីអាទិត្យ ក្រោយពី ពូអឿន និង ពូកេត របស់លោកស្រីត្រូវបានគេចាប់ខ្លួន ។ តើខ្ញុំលើកឡើងនេះត្រឹមត្រូវដែរឬទេ?

[១១:៣៣:១៧]

**ឆ៖** ត្រឹមត្រូវហើយ ។

**ស៖** ខ្ញុំសូមបន្តទៅចំណុចមួយដែលលោកស្រីធ្វើការជាពេទ្យនៅស-២១ ដែលពេលនោះដែលលោកស្រីប្រើថ្នាំបូរាណ ថ្នាំឫសឈើនោះ តើអ្នកណាជាអ្នកយកថ្នាំឫសឈើហ្នឹងមកឲ្យកន្លែងធ្វើការ ឬកន្លែងផ្ទះសម្រាប់យកទៅចែកតទៅទៀតនោះ?

**ឆ៖** គឺកាលខ្ញុំចាប់ធ្វើពេទ្យដំបូង គឺខ្ញុំប្រើតែថ្នាំសេសសល់ពីយើងពីដើមមកទេ ដល់ពេលចុងក្រោយបំផុត គឺមានថ្នាំឫសឈើមកខ្ញុំព្យាបាលចំនួនប្រហែលមួយខែ ទៅពីរខែតែប៉ុណ្ណោះឯង។ គឺយកហ្នឹងតាមរយៈប្រធានពេទ្យយើងខ្ញុំ យកមកដល់កន្លែងឲ្យ មិត្តលន តែម្តង ។ មិនដឹងណាអ្នកព្យាបាលធ្វើ ។

**ស៖** ចាតើលោកស្រីដឹងទេ អ្នកណាជាឲ្យថ្នាំពេទ្យទៅ លន? ថាឲ្យម្តងៗមានចំនួនច្រើនប៉ុនណាដែរ ប្រហែល?

**ឆ៖** គឺបងសែម គាត់យកមកឲ្យ បើអាថ្នាំ ដែលគេធ្វើអាយហ្នឹង ម្តងប្រហែលជាកន្លះគីឡូក្នុងមួយថង់ យកមកឲ្យប្រាំដងក្នុងមួយខែ ។

**ស៖** ចាតើអ្នកដែលឲ្យថ្នាំពេទ្យទៅ លន ហ្នឹង តើគាត់ជាអ្នកធ្វើការនៅស-២១ ដែរ ឬក៏គាត់មកពីអង្គភាពណាខាងក្រៅ?

**ឆ៖** ដែលអ្នកយកថ្នាំមកផ្តល់ឲ្យមិត្តលន ហ្នឹង គឺៗ គាត់អង្គភាពពេទ្យ ជាប្រធានពេទ្យ គាត់ឈ្មោះ មិត្តសែន អ្នកយកមកឲ្យគាត់នៅពេទ្យ នៅប៉ុស្តិ៍វ៉ាដ្យូ យើងឥឡូវនេះ ប៉ុស្តិ៍លេខប្រាំនេះ ។

**ស៖** នៅពេលដែលលោកស្រីឈប់ធ្វើជាពេទ្យហ្នឹង តើអ្វី-- លោកស្រីធ្វើការអ្វីតទៅទៀតពេលនោះ?

**ឆ៖** កាលពីយើងខ្ញុំ គេឈប់ឲ្យធ្វើពេទ្យនោះ គឺគេឲ្យយើងខ្ញុំជម្រះស្មៅតាមកៀនគុកទួលស្លែងនេះតែម្តង អស់រយៈប្រហែលជាកន្លះខែបានគេចាប់ខ្ញុំ ។ ខ្ញុំឈប់ធ្វើពេទ្យអស់រយៈប្រហែលជាកន្លះ គេចាប់ខ្ញុំតែម្តង ប៉ុន្តែខ្ញុំរស់នៅតែនៅក្នុងគុកទួលស្លែងនេះជារៀងទាល់តែគេចាប់ ។ គ្រាន់តែឈប់ដើរចែកថ្នាំចែកអីទេ ទៅគេឲ្យខ្ញុំជម្រះស្មៅជម្រះអីទៅ រួចទៅគេចាប់ខ្ញុំតែម្តង ។

**ស៖** តើលោកស្រីដឹងទេពីមូលហេតុដែលគេប្តូរពីឲ្យធ្វើពេទ្យ ឲ្យមកជម្រះស្មៅក្នុងមន្ទីរស-២១ នោះ?

[១១:៣៧:៣៩]

**ឆ៖** គឺយើងខ្ញុំអត់ដឹងថាខ្លួនឯង គេដកធ្វើពេទ្យនោះក៏នៅក្នុងចិត្តខ្លួនដឹងហើយ គេអត់ទុកចិត្តយើងខ្ញុំ ព្រោះយើងខ្ញុំមាន ខ្ញុំបានស្រែកទ្រហោយំឃើញឪពុកម្តាយខ្ញុំ ម្លោះខ្ញុំគេលែងទុកចិត្តខ្ញុំហើយ បានគេដកខ្ញុំមក ។ ខ្ញុំមិននឹកស្មានថា គេយកខ្ញុំទៅសម្លាប់ចោលផង ប៉ុន្តែគេដកហើយ គេឲ្យខ្ញុំជម្រះស្មៅប្រហែលជាកន្លះបានគេដាក់ខ្ញុំបញ្ចូលខ្នោះតែម្តង ។

**ស៖** ឥឡូវនេះ ខ្ញុំបន្តទៅពីស្ថានភាពនៅព្រៃស លោកស្រីបានប្រាប់សវនាការរួចហើយ ថាគេឲ្យជីករណ្តៅកប់ខ្មោចក្មេងកុមារ ។ តើនៅព្រៃស លោកស្រីធ្លាប់បានឃើញទេ ថាតើគេបានសម្លាប់កុមារ ឬក្មេងទេនៅព្រៃសនោះ?

**ឆ៖** គឺកាលពេលខ្ញុំផ្លាស់ពីគុកទួលស្លែងរហូតដល់គុកព្រៃសនោះ គេឲ្យខ្ញុំជីករណ្តៅ ពេលយប់ឡើង គឺឮស្នូរតែក្មេងស្រែ ឬមួយយំ ហើយខ្ញុំហ្នឹងក៏ខំតាមដាន អ៎! ខំលួចមើលទៅឃើញគេសម្លាប់ក្មេង បោះក្មេងឡើងទៅលើយកកាណុងកាំភ្លើងនេះហើយ គេភ្ជង់ក្មេងអាចស្លាប់នៅក្នុងគុកព្រៃស ។ ប៉ុន្តែយើងខ្ញុំឃើញហ្នឹង គឺឃើញតែម្នាក់ទៅពីរនាក់តែប៉ុណ្ណោះទេ ដល់បន្ទាប់មកគេឲ្យខ្ញុំទៅជីករណ្តៅនេះតែម្តង ។

**ស៖** តើលោកស្រីនៅចាំទេ ថាតើកុមារ ឬក្មេងហ្នឹងប្រហែលជាអាយុប៉ុនណាដែរ អាចសម្គាល់បានទេ?

**ឆ៖** អាចគេបោះហ្នឹង គឺក្មេងគ្មានធំទៅប៉ុន្មាន ប្រហែលជាអាយុមួយឆ្នាំ ទៅពីរតែប៉ុណ្ណោះ ។

**ស៖** តើលោកស្រីបានឃើញអ្វីទៀតនៅព្រៃស នៅពេលដែលលោកស្រីនៅទីនោះ ដូចជា កុមារ ឬក៏កុមារតូចៗ ដែលទទួលរងបួស ឬក៏ដំបៅអ្វីទេ ដែលគេមាននៅលើរាងកាយគេនោះ?

**ឆ៖** គឺក្មេងទាំងអស់នោះ គឺមានរាងកាយស្គមស្គាំង ដំបៅដោយសារមូសខាំរគើមកម ។ នេះហើយធ្វើឲ្យ-- ស្គមស្គាំងទៅយកគ្នាទៅវាយចោលនៅក្នុងរង្វង់ព្រៃសនេះមួយទាំងមូល មិនមែនគុកប្រមូលសតិអារម្មណ៍ មិនមែនគុកកសាងខ្លួន គឺគុកនេះ គឺគុកវាយចោល ក្មេងៗ និងស្ត្រី ។

**ស៖** តើលោកស្រីបានឮ ឬក៏បានឃើញរបៀប ដែលគេសម្លាប់ក្មេងតូចៗហ្នឹងដោយរបៀបណានៅព្រៃសហ្នឹង?

**ឆ៖** គឺខ្ញុំកាលនោះ គឺខ្ញុំដែលគេនាំខ្ញុំទៅនុ៎ង គេនាំខ្ញុំបកមកវិញនុ៎ង គឺខ្ញុំបានក្រឡេកឃើញគេសម្លាប់ក្មេងហ្នឹង គឺខ្ញុំទាន់តែម្នាក់នោះទេ គេបោះឡើងលើ គេយកកាំណុងកាំភ្លើងទៅទ្រនោះ ខ្ញុំឃើញតែម្នាក់នោះឯង ។ ក្រៅពីនុ៎ង គឺយើងខ្ញុំអត់បានឃើញទេ ឃើញតែខ្មោចងាប់ ក៏គេធ្វើ-- វាយយ៉ាងម៉េច គឺខ្ញុំអត់បានឃើញ ខ្ញុំឃើញតែមួយនោះផ្ទាល់ហ្នឹងភ្នែកតែម្តង ។

[១១:៤១:៤៥]

**ស៖** ខ្ញុំយល់ ប៉ុន្តែសួរតទៅទៀតថា តើលោកស្រីបានឮអ្នកណាផ្សេងទៀតនិយាយទេនៅព្រៃសថាតើគេសម្លាប់ក្មេងហ្នឹង ដោយរបៀបណា? ហើយគេយកទៅណា?

**ឆ៖** នៅក្នុងគុកព្រៃស គឺខ្ញុំមិនដែលតាមដានអ្នកណានិយាយប្រាប់ខ្ញុំរឿងសម្លាប់ទេ តែខ្ញុំឃើញផ្ទាល់ទាំងភ្នែក ឃើញតែខ្មោច ហើយអ្នកនិយាយប្រាប់ ក៏គេអត់មាននិយាយប្រាប់ខ្ញុំទេ ។ ខ្ញុំពាក្យអីដែលខ្ញុំឃើញផ្ទាល់ភ្នែក គឺខ្ញុំអាចនិយាយបាន បើតាមពាក្យដែលគេញុះញង់ឲ្យខ្ញុំមិនប្តឹង គឺខ្ញុំអាចនិយាយអត់បាន ។ ព្រោះខ្ញុំមិនដឹងពិត បើខ្ញុំដឹងពិត ខ្ញុំនិយាយប្រាប់តុលាការជាការពិត ក្រៅពីពាក្យពិត គឺខ្ញុំអាចអត់និយាយ អត់បាន អត់មាន អ៊ីចឹងតែម្តង ។

**ស៖** សូមអរគុណលោកស្រីជាច្រើនចំពោះការឆ្លើយតបទៅនឹងសំណួរដោយច្រើន ហើយខ្ញុំសួរសំណួរមួយទៀត ដែលវាខុសពីខាងដើម ។ ប៉ុន្តែ ទាក់ទងទៅនឹងចំណុចមួយទៀតនៅព្រៃស តើគេបានប្រាប់លោកស្រីដែរឬទេ អំពីការរៀបការរួម ដែលកើតឡើងនៅព្រៃស រវាងបុគ្គលិកនារី ហើយនិងកូនកំលោះ ឬក៏ថាបុគ្គលិកបុរសនុំងជាអ្នកពិការ?

**ឆ៖** គឺអាចនារីហ្នឹង-- នៅក្នុងគុកព្រៃសនោះ គឺយកនារី និងពួកពិការ គេរៀបការម្តងមានតែដប់គូ ប្រាំគូជារៀងរាល់ខែ ។ ជួនកាលទៅអស់ទៅ ក៏ឈប់ទៅដាច់ ខ្លះក៏អត់យកទៅ ចាប់បង្ខំជាមួយនឹងជនពិការ រៀបនៅក្នុងគុកព្រៃសតែប៉ុណ្ណឹង ។

**ស៖** តាមដែលលោកស្រីដឹងនោះ តើគេមានការស្ម័គ្រចិត្ត ឬក៏គេចង់រៀបការដែរឬទេ ខាងនារីនោះ?

**ប្រធានអង្គជំនុំ៖**

ចម្លើយនេះលោកស្រី ណាំ ម៉ុន មិនបាច់ឆ្លើយទេ នេះក្រៅអង្គហេតុ អង្គហេតុនេះអត់មានការចោទប្រកាន់ពាក់ព័ន្ធជាមួយនឹងរឿងអាពាហ៍ពិពាហ៍ហ្នឹងទេ ។ លោកស្រីមេធាវីរកសំណួរឯណាសួរពាក់ព័ន្ធជាមួយអង្គហេតុដើម្បីបង្ហាញឲ្យឃើញការពិត ។ ហើយអង្គហេតុនេះ គឺ ណាំ ម៉ុន ជាជនរងគ្រោះផង ជាដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធជាមួយនឹងញាតិសន្តានរបស់គាត់ដែលគាត់អះអាងថាបានទទួលមរណភាពនៅក្នុងទួលស្លែង ។

[១១:៤៥:១២]

**សួរដោយលោកស្រី ស៊ីលឃើស្ទួត ហ្សីនស្ទី៖**

**ស៖** សូមអរគុណលោកប្រធាន ខ្ញុំកត់សម្គាល់ឃើញថា យើងមានមួយនាទីជាងទៀតដែលសម្រាប់គាត់ធ្វើការសម្គាល់ដែលធ្វើឡើងដោយអង្គជំនុំជម្រះ ។ លោកស្រី ណាំ ម៉ុន ខ្ញុំចង់ដឹងថែមទៀត

ទៀតថា លោកស្រីមានស្លាកស្នាមអ្វីដែលបន្សល់ទុកមកពីទារុណកម្មនៅស-២១ ឬក៏ព្រៃសទេ នៅពេលដែលគេឃុំឃាំងលោកស្រី? តើអាចរៀបរាប់ដែរឬទេ? ថាតើមានស្លាកស្នាមអ្វីខ្លះដែលនៅសេសសល់?

**ឆ៖** គឺយើងខ្ញុំ តាំងពីគេចាប់ដាក់ខ្នោះនៅជើងគឺយើងខ្ញុំអាចបង្ហាញស្លាកស្នាមនេះបាន ។ ស្លាកស្នាមកជើងតែម្ខាងទេ នៅអាចតម្កល់សេសសល់ ។

**ស៖** តើមានស្លាកស្នាមដែលសល់ពីការវាយដំនៅព្រៃស ហើយនៅលើរាងកាយនៅសល់ស្លាកស្នាមដល់ថ្ងៃនេះទេ?

**ឆ៖** សព្វថ្ងៃនេះនៅស្លាកស្នាមតែជើងមួយខាងនេះហើយ ដែលជាស្លាកស្នាមដែលខ្ញុំជាប់គុក។

**ស៖** សំណួរ ហើយសំណួរចុងក្រោយមួយទៀត ហេតុអ្វីៗបានជាថ្ងៃនេះលោកស្រីមានអារម្មណ៍ធូរស្រាលក្នុងការនិយាយអំពីអ្វីដែលលោកស្រីបានឆ្លងកាត់នៅទួលស្លែងហើយនិងព្រៃស? ហេតុអ្វីបានជាពេលនេះលោកស្រីមានលទ្ធភាពនិយាយបានច្រើនអំពីរឿងដែលបានកើតឡើងចំពោះលោកស្រីហ្នឹងបានច្រើនជាងមុន?

[១១:៤៧:១៦]

**ឆ៖** គឺយើងខ្ញុំបានពង្រឹងគោលជំហររកការអយុត្តិធម៌ជូនឪពុកម្ដាយខ្ញុំ ទាំងបងប្អូនពូមីងទាំងអស់ឲ្យបានឃើញនៅក្នុងថ្ងៃនេះ ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

សូមអរគុណលោកស្រី ណាំ ម៉ុន ហើយខ្ញុំសូមអនុញ្ញាតប្រគល់វេទិកាទៅឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីបី ។ ហើយខ្ញុំសូមជម្រាបអង្គជំនុំជម្រះថា មុននឹងបញ្ចប់សួរលោកស្រី ណាំ ម៉ុន នេះលោកស្រីនឹងមានសំណួរទៅជនជាប់ចោទនោះផងដែរ ។ សូមអរគុណ ។

**សួរដោយលោកស្រី ម៉ាទីន ហ្សាកកាំង៖**

**ស៖** សូមជម្រាបសួរលោកប្រធាន លោក លោស្រីចៅក្រម ហើយនិងសូមអរគុណលោកស្រី ណាំ ម៉ុន ។ ហើយគឺជាការលំបាកណាស់ ដែលថាឆ្លើយនោះ ។ តើលោកស្រីអាចបញ្ជាក់ទេ? ថាតើនៅអគារណាមួយដែលគេឃុំខ្លួនលោកស្រីនោះ? តើនៅក្នុងអគារដែលកន្លែងលោកស្រីធ្វើការជាពេទ្យហ្នឹង ឬកន្លែងណា?

**ឆ៖** គឺអគារដែលគេឃុំខ្លួនចំពោះយើងខ្ញុំគឺអគារនេះហើយដែលខ្ញុំធ្វើការនោះ ប៉ុន្តែ នៅជាន់ក្រោមនៅបន្ទប់តែមួយតែឯង ។

**សៈ** តើគេបានថតរូបលោកស្រីទេ មុនពេលដែលគេដាក់ឃុំឃាំងនោះ?

**ឆៈ** នៅក្នុងគុកទួលស្លែងនេះ គឺយើងខ្ញុំអត់មានថតទេដល់ទៅគុកព្រៃសបានថត ប៉ុន្តែខ្ញុំដើររក អត់ឃើញរូបយើងខ្ញុំទេ ។

**សៈ** សំណួរលោកស្រីបានបញ្ជាក់ថា គេបានដាក់ឃុំលោកស្រីនៅស-២១ បីខែ ហើយថាតើគេ បានឲ្យលោកស្រីងូតទឹកដែរឬទេ? ហើយបើពេលនោះលោកស្រីបញ្ជាក់ថា គេឲ្យទៅងូតទឹក ប៉ុន្តែលោក ស្រីមិនព្រមទៅ ថាហេតុអីបានជាមិនព្រមទៅនោះ?

**ឆៈ** កាលនោះឡើង គេឲ្យយើងខ្ញុំទៅងូតទៅដែរ ប៉ុន្តែខ្ញុំអត់ៗបានទៅងូតទេព្រោះខ្លាចឈឺជើង ព្រោះជើងយើងខ្ញុំដំបៅរលួយទៅហើយកជើង ។ ងូត តែត្រូវទឹកវាឈឺ ម្ល៉ោះហើយនៅក្រៀមនៅចោល ហ្នឹងអីចឹងទៅ ។

**សៈ** សំណួរ នៅពេលដែលលោកស្រីនៅស-២១ តើលោកស្រីបានឃើញអ្នកទោសមានផ្ទៃពោះ ឬក៏មានអ្នកទោសណាឆ្លងទន្លេកើតជាកូនង៉ែតដែរឬទេ?

[១១:៥០:២៦]

**ឆៈ** កាលយើងខ្ញុំនៅស-២១នេះ គឺអត់បានមានឃើញនារីណាដែលឆ្លងទន្លេហើយនិងពោះធំ គឺអត់បានឃើញទេ ឃើញតែមីងអ៊ីចាស់ៗដែលគេយកមកដាក់ឃុំឃាំងនេះ ដែលប្រពន្ធកម្មាភិបាល ទាំងអស់ ។

**សៈ** តើលោកស្រីអាចប្រាប់យើងបានទេ ថាហេតុអ្វីបានអ្នកទោសស្រីផ្សេងៗទៀតដែល ពួកគាត់ មិនសប្បាយចិត្ត ឬក៏មានការស្រងូតស្រងាត់ក្រោយពីគេត្រឡប់មកពីងូតទឹកវិញនោះ?

[១១:៥១:១០]

**ឆៈ** កាលគេអ្នកទៅងូតទឹក គឺខ្ញុំអត់បានតាមដានទេ ។ ខ្ញុំនៅតែក្នុងគេចាក់សោពីក្រៅឃុំឃាំង ដោយសារតែខ្ញុំអត់ទៅងូតទឹក គឺខ្ញុំអត់បានមើលគេបានទេ ។ ដឹងគេសប្បាយ ដឹងគេកើតទុក្ខក៏យើងខ្ញុំ អត់ដឹងផង ។

**សៈ** លោកស្រីបានដឹងថា បងប្រុសរបស់លោកស្រីត្រូវបានគេវាយសម្លាប់ ថាតើលោកស្រីដឹង ដោយរបៀបណានៅពេលហ្នឹង? ថាគេសម្លាប់បងរបស់លោកស្រីហ្នឹង?

**ឆៈ** ខ្ញុំពេលដែល-- ខ្ញុំអាចដឹងថា បងខ្ញុំព្រមទាំងម្ដាយខ្ញុំដែលចាប់ពីក្រោយឪពុកខ្ញុំហ្នឹង គឺខ្ញុំអាច យល់ដឹងថាគាត់ស្លាប់នៅក្នុងគុកនេះតែម្ដង ព្រោះខ្ញុំរង់គេចាប់ខ្ញុំដើមឆ្នាំ៧៨នេះ គឺអត់មានឃើញរូបគាត់

គេបញ្ជូនទៅដល់ណាផងឃើញនៅតែក្នុងគុកហ្នឹងឈឹងសូន្យទាំងអស់ ។ ម្ល៉េះហើយខ្ញុំប៉ាន់ស្មានថា គាត់ស្លាប់នៅទីនេះហើយ ចុះអ្នកណាវ៉ៃក៏ខ្ញុំមិនដឹងដែរ ដឹងតែស្លាប់នៅនឹងគុកទួលស្លែងនេះតែម្តង ។

**ប្រធានអង្គជំនុំ៖**

អស់ពេលហើយមេធាវី ពេលចែកឲ្យអស់ហើយ ។ លោកស្រី ណាំ ម៉ុន តាមសម្តីរបស់មេធាវី លោកស្រី ស្វូតហ្សឹនស្តី ថាលោកស្រីមានបំណងនឹងតាំងសំណួរខ្លះចំពោះជនជាប់ចោទ ។ ឥឡូវនេះ លោកស្រីនៅមានបំណងតាំងសំណួរចំពោះជនជាប់ចោទដែរ ឬទេ?

**លោកស្រី ណាំ ម៉ុន៖**

យើងខ្ញុំចង់សួរទៅជនជាប់ចោទបងខាងកើតនេះតែម្តង ។ សំណួរទីមួយ ខ្ញុំសូមសួរបងថា តើខ្ញុំនិយាយពាក្យពិតទាំងប៉ុន្មាន បងបដិសេធចោល ហើយបងទទួលឬអត់?

[១១:៥៣:២៣]

**ប្រធានអង្គជំនុំ៖**

លោកស្រីអាចសួរបាន ។ ប៉ុន្តែ លោកស្រីអត់មានសិទ្ធិសួរទៅជនជាប់ចោទផ្ទាល់ទេ ។ លោកស្រីសួរឲ្យច្បាស់មក ហើយយើងកត់ត្រា យើងជាអ្នកបញ្ជូននូវសំណួរទាំងនោះចំពោះជនជាប់ចោទ ដើម្បីឲ្យគាត់ឆ្លើយ ឬគាត់រក្សាសិទ្ធិមិនឆ្លើយតប នេះជាសិទ្ធិរបស់ជនជាប់ចោទដែលមានដរាបនៅក្នុងអំឡុងពេលនៃកិច្ចដំណើរសួរដេញដោលនេះ ។ អ៊ីចឹងសួរមកយើង ។

**លោកស្រី ណាំ ម៉ុន៖**

បងជាប្រធាន! ខ្ញុំសូមសួរទៅជនជាប់ចោទ ។ ជនជាប់ចោទនេះដែរ ធ្វើបាបឪពុកម្តាយបងប្អូនខ្ញុំទាំងអស់ ហើយប្រុងបដិសេធពាក្យនេះចោល ឬមួយគាត់គិតថាគាត់ធ្វើដែរឬ ហើយគាត់មិនធ្វើ? ខ្ញុំសូមសួរ ។

**ប្រធានអង្គជំនុំ៖**

មានអីទៀតទេ? នេះមិនបាច់សួរក៏គាត់នឹងឆ្លើយដែរ ។ សំណួរអស់នេះមិនបាច់សួរគាត់និងនិយាយហើយ អង្គជំនុំជម្រះនឹងប្រគល់សិទ្ធិនិងផ្តល់សិទ្ធិឲ្យជនជាប់ចោទធ្វើការកត់សម្គាល់នឹងសេចក្តីថ្លែងការណ៍ ឬក៏ពាក្យសម្តីទាំងឡាយដែលលោកស្រីបាននិយាយទាំងពីម្សិលមិញ ហើយនិងព្រឹកមិញនេះ ។ មានសំណួរជាក់លាក់ណាផ្សេងទៀតទេ?

[១១:៥៥:២៤]

**លោកស្រី ណាំ ម៉ុន៖**

ខ្ញុំចង់សួរតែប៉ុណ្ណឹង ឲ្យគាត់ឆ្លើយផ្ទាល់មាត់ជាមួយយើងខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅជនជាប់ចោទ ។ ទីមួយ គឺជនជាប់ចោទអាចធ្វើការកត់សម្គាល់នូវសេចក្ដីថ្លែងការណ៍សម្ដីនិយាយ បង្ហាញហេតុផលនានារបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ណាំ ម៉ុន ហើយជាមួយនឹងគ្នាដែរ គឺឆ្លើយតបទៅនឹងអ្វីដែលជាគាត់អះអាងថា ជាសំណួរនេះប្រសិនជាលោកមានប៉ុនប៉ងក្នុងការឆ្លើយតបទៅនឹងសំណួរនេះ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទៅគោរព! ខ្ញុំសូមជូនជាសេចក្ដីសង្កេតដូចតទៅ៖

ទីមួយ ទុក្ខវេទនារបស់ប្រជាជនកម្ពុជាទូទាំងប្រទេសជំនាន់នោះ ខ្ញុំអត់គេចទេ ខ្ញុំពិតជាទទួលខុសត្រូវខាងផ្លូវចិត្ត ។ ដោយឡែកជនរងគ្រោះទាំងឡាយណាដែលបាត់បងជីវិតនៅមន្ទីរស-២១ ខ្ញុំទទួលខុសត្រូវទាំងពីរទាំងផ្លូវច្បាប់ទាំងផ្លូវចិត្ត ។ នេះគឺ ខ្ញុំសូមបញ្ជាក់គោលជំហរច្បាស់លាស់របស់ខ្ញុំនៅក្នុងពេលនេះម្ដងទៀត ។ ដោយឡែកករណីប្រវត្តិសាស្ត្រខ្លះដែលខ្ញុំលើកជូនបញ្ជាក់ ជូនអង្គប្រជុំនៅពេលនេះមានដូចតទៅ៖

ក្រោយ ១៧ មេសា បក្សកុម្មុយនីស្តកម្ពុជាជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ។ កម្លាំងតស៊ូសម្ងាត់របស់ក្រុងភ្នំពេញអត់ជម្លៀសចេញទេ មួយភាគប្រគល់ទៅឲ្យបងវន គឺ វន វ៉េត ចាត់ចែងខាងការងារឧស្សាហកម្ម ។ មួយភាគប្រគល់មកជូនលោកគ្រូ សុន សេន ចាត់ចែងខាងការងារសេនាធិការប្រាំនាក់ប្រគាល់មកស-២១ ជាកម្មាភិបាលសួរចម្លើយ ។ នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយ ។

[១១:៥៧:៥១]

ឯចំណែកកម្មករ បង ចេង អន ចុះទៅជនបទ ទៅប្រមូលកម្មករមករោងចក្រវិញ ។ ជាហូរហែបើតាមខ្ញុំចាំ ហើយដែលខ្ញុំបានជួបបង ចេង អន ខ្លះៗនៅពេលនុំងដើម្បីដឹងដំណឹងពីអង្គការ បងចេង អន ប្រមូលកម្មករចូល ។ ជាមូលដ្ឋានចប់នៅមុនថ្ងៃ៣១ ឧសភា ឆ្នាំ១៩៧៥ ។ ចំណែកសក្ខីភាពរបស់លោកស្រី ណាំ មុន មានប្រសាសន៍ថា ឪពុកលោកស្រីមកជាព័ស្តុភាររបស់ស-២១ គ្មានទេ ។ ព័ស្តុភាររបស់ស-២១ អត់មានឈ្មោះលោកស្អី ជាឪពុកអ្នកស្រី ណាំ ម៉ុន នេះទេ ។ ហើយពេទ្យនៅស-២១ គឺជាពេទ្យដែលសល់មកពីកងពល៧០៣ គេចែកមក ជាគេរដំណែលគ្មានស្រីទេ មានតែប្រុស ។ យើងខ្ញុំ

បានចាប់មែន ប្រធានពេទ្យបណ្ដើរៗរហូតចុងក្រោយបញ្ចប់ចាប់ មិត្តទ្រី តាមការសម្រេចរបស់ខាងលើមែន ក៏ប៉ុន្តែគ្មានពេទ្យស្រីទេ ។

ខ្ញុំសូមជូនជាការសង្កេតមួយបែបទៀត សភាពការណ៍ដែលលោកស្រី ណាំ ម៉ុន លោកមានប្រសាសន៍អំពីសភាពការណ៍ស-២១ ឆ្ងាយអំពីរឿងពិតនៅស-២១ ណាស់ ។ លោកស្រីអត់ស្គាល់អ្នកណាទាំងអស់ ក្រៅពីបងប្អូនលោកស្រីប៉ុន្មាននាក់ដែលលោកស្រីមានប្រសាសន៍ថា មកស្លាប់នៅមន្ទីរស-២១ ហើយលោកស្រីស្គាល់តែពេទ្យបីនាក់ មិត្តលន មិត្តឃីម ហើយនិងខ្លួនលោកស្រី ។ ហើយក្រៅពីនោះស្គាល់បងខាងកើតម្នាក់ ដែលទើបលោកស្រី-- ឮលោកស្រីមានប្រសាសន៍ថ្ងៃនេះ ។

[១១:៥៩:៥៣]

ឯចំណែកនៅព្រៃស ការងារមួយគរគោក ដូច មិត្តម៉េត គាត់មានប្រសាសន៍រាយការណ៍ជូនអង្គជំនុំជម្រះហើយ ឯចំណែកលោកស្រី ណាំ ម៉ុន លោកមានប្រសាសន៍តែអីណាទៅជីកតែរណ្ដៅនោះទៅវិញ ។ ដូច្នេះសភាពការណ៍ស-២១ ទាំងនៅភ្នំពេញ ទាំងនៅព្រៃសលោកស្រី ណាំ ម៉ុន ក្លាប់អត់បានទេ ។ ខ្ញុំបានអានពាក្យបណ្ដឹងលោកស្រី ណាំ ម៉ុន ខ្ញុំតក់ស្លុតណាស់ ឃើញបាត់បងឪពុកបាត់បង់ម្ដាយបាត់បង់បង បាត់បង់ប្អូនច្រើនណាស់ ។ ខ្ញុំថាពិតជាមានទុក្ខវេទនានៅជំនាន់នោះ ក៏ប៉ុន្តែ មិនមែននៅស-២១ ទេ ។

ខ្ញុំបញ្ជាក់ជូនអង្គជំនុំជម្រះថា ស-២១ គ្មានសិទ្ធិផ្ទេរអ្នកស្រី ណាំ ម៉ុន ពីស-២១ ទៅព្រៃទទឹងទេ ខ្ញុំសង្ស័យនៅខាងនោះទៅវិញ ។ ដូច្នេះ ភស្តុតាងអត់មាន បើចង់ដឹងច្បាស់ថាអ្នកស្រី ណាំ ម៉ុន ធ្វើពេទ្យនៅហ្នឹង សូមខាងមេធាវីនៃរដ្ឋប្បវេណីលោកមេត្តាជួយរកបញ្ជីបុគ្គលិករបស់ស-២១ យកមកដាក់ជាភស្តុតាងជូនអង្គជំនុំជម្រះ ។ តើមានឈ្មោះអ្នកស្រី ណាំ ម៉ុន ទេ? ឬមានឈ្មោះអ្នកស្រី រឿន ចាន់ថាហ្នឹង ឬមាន-- ឯចំណែកឈ្មោះអ្នករងគ្រោះទាំងប៉ុន្មានខ្ញុំបើកមើលនៅក្នុងបញ្ជីនេះអត់ឃើញមានទេ ។ ដូច្នេះភស្តុតាងគ្មាន ភស្តុតាងជាលាយលក្ខណ៍អក្សរជាឯកសារគ្មានទាំងអស់ ។ សភាពការណ៍ដែលគាត់ចេះក៏ប្លែកអំពីជាក់ស្ដែងនៅស-២១ ភស្តុតាងក៏មិនមាន ឯចំណែកព្រឹត្តិការណ៍ប្រវត្តិសាស្ត្រក៏អត់ដឹងទៀត ។ គាត់អត់ទាំងដឹងថា ស-២១ ផ្លាស់ប្ដូរទីតាំងប៉ុន្មានលើកផង ។ ខ្ញុំបានរាយការណ៍ជូនអង្គប្រជុំហើយស-២១ ផ្លាស់ប្ដូរទីតាំងប៉ុន្មានលើក ។ អង្គជំនុំជម្រះសាលាដំបូងលោកជ្រាប ដូច្នេះខ្ញុំសូមបញ្ចប់បញ្ហានេះប៉ុណ្ណេះ ។

[១២:០១:៤៦]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ម៉ោងត្រូវពិសាអាហារថ្ងៃត្រង់ហើយ ។ អង្គជំនុំជម្រះប្រកាសដើម្បីសម្រាកពិសាអាហារថ្ងៃត្រង់ ហើយអង្គជំនុំជម្រះនឹងបន្តនៅរសៀលនេះចាប់ពីម៉ោងមួយកន្លះទៅ ។ មន្ត្រីតុលាការសម្របសម្រួលចំពោះលោកស្រី ណាំ ម៉ុន ដើម្បីឲ្យគាត់បានកន្លែង មានកន្លែងសម្រាកសមរម្យ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រងចាំ ហើយឲ្យនាំគាត់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោងមួយកន្លះរសៀលនេះ ។

*[សវនាការសម្រាកពីម៉ោង ១២:០២នាទី ដល់ម៉ោង ១៣:៣៣នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ណាំ ម៉ុន ជាបន្ត ។ មុននឹងប្រគល់វេទិកានេះទៅមេធាវីការពារក្ដី អង្គជំនុំជម្រះសូមឲ្យជនជាប់ចោទធ្វើការកត់សម្គាល់ ឬក៏មានមតិយោបល់លើរូបថតដែលបានបញ្ចាំងជូនព្រឹកមិញ ថាតើមានយោបល់ ឬក៏កត់សម្គាល់យ៉ាងណាខ្លះលើរូបថតទាំងអស់ដែលបានដេញដោលព្រឹកមិញនោះ ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំសូមមានមតិអំពីរូបថត ។ ដំបូងដើម្បីច្បាស់លាស់ ខ្ញុំសូមអនុញ្ញាតមានមតិអំពីការដែលខ្ញុំសុខចិត្តទទួលស្គាល់រូបថត ជិន ម៉េត ដើម្បីជាពន្លឺក្នុងរឿងរូបថតនេះ ។ នៅពេលដែលខ្ញុំបាទអានពាក្យបណ្ដឹងរបស់ ជិន ម៉េត ខ្ញុំចាប់អារម្មណ៍បញ្ហាបី ។ បញ្ហាទីមួយ គឺខ្លឹមសារដែល មិត្តម៉េត រាយការណ៍អំពីទុក្ខវេទនារបស់ខ្លួនគាត់នៅព្រៃស ជាទុក្ខវេទនាដែលខ្ញុំទទួលបាន ទោះបីមានលើសខ្វះតិចតួចក៏សុខចិត្តទទួលថា ពិត នេះទិដ្ឋភាពមួយ ។ ទិដ្ឋភាពពីរ ជិត ម៉េត មាននិយាយអំពីកង១៧ ខ្ញុំថា “ហ្អា! កង១៧ ខ្ញុំសង្ស័យណាស់ ពិតជាកងនៅព្រៃសហើយ” ។ ហើយទិដ្ឋភាពទីបី ដែលខ្ញុំមានការតក់ស្លុត ខ្ញុំឃើញរូបថតនៅនឹងកាត ជិត ម៉េត ចាស់ណាស់ ។ រូបថតនៅក្នុងកាតនោះ ហាក់ដូចជា ជិន ម៉េត អាយុ៧០ទៅហើយ ។ ខ្ញុំអាណោចអាធម្មគិតអាណិតអាសូរគេ ។ ដល់ក្រោយមកខ្ញុំឃើញឯកសារមួយ ដែលឯកសាររបស់ព្រៃស និយាយអំពីនៅព្រៃសនេះ លេខ ERN នៅនេះ ខ្ញុំពិបាកមើល

ទាន់ណាស់ ។ នៅព្រៃសនេះមានកង១១ កង១២ កង១៣ កង១៤ កង១៥ កង១៦ កង១៧ ខ្ញុំឃើញឯកសារនេះភ្លាម ខ្ញុំថា នោះ! ជិត ម៉េត និយាយនោះត្រូវហើយ គេពិតជារងទុក្ខនៅទុំងមែន ខ្ញុំទទួលស្គាល់បញ្ហា ជិត ម៉េត ទាំងអស់រួចហើយ ខ្ញុំរង់ចាំតែឯកសារមកទៀតទេ ។ ដល់ឃើញឯកសារប្រវត្តិរូបសង្ខេបរបស់ ជិត ម៉េត ខ្ញុំថានោះ ស-២១ ច្បាស់ថែស កងចាស់៤៥០ បច្ចុប្បន្ននៅកង១៧ ខ្ញុំថានោះដូច្នេះខ្ញុំទទួលស្គាល់ឯកសារទុំងអស់ហើយបានៗទទួលស្គាល់រូបថត ជិត ម៉េត ក្រោយ ឃើញរូបថត ជិត ម៉េត នៅនឹងផ្ចិត បិទជាប់នឹងប្រវត្តិនោះ ហើយឃើញរូបថត ជិត ម៉េត មួយផ្ទាំងច្បាស់ថែសអ៊ីចឹងឃើញរូបថត ជិន ម៉េត នៅនឹងកាត ហើយនៅពេលដែល ជិត ម៉េត និយាយហ្នឹង ខាងសោតទស្សន៍គេបង្ហាញ ជិត ម៉េត ពេញមុខនៅនេះ ខ្ញុំយករូបហ្នឹងទៅដាក់ញល់ផ្ដុំគ្នាអ៊ីចឹងរូបប្អូនវាដូចគ្នា ។ ដូច្នេះហើយការទទួលស្គាល់រូបថត  ជិត ម៉េត វាជាជំហានចុងក្រោយដែលមានឯកសារសព្វគ្រប់ហើយទេ ។ នេះខ្ញុំសូមលើកបញ្ហានេះមួយជូនអង្គជំនុំជម្រះទុកជាគោល ។

[១៣:៣៧:១៦]

រូបថតខ្លះទៀត ខ្ញុំសូមលើករូបថតមួយទៀតចុះ របស់ដើមបណ្ដឹងរដ្ឋប្បវេណី D25/6 គាត់ថារូបថតប្អូនគាត់ ។ គាត់មិនទុកចិត្តគាត់ទៅពឹងបញ្ញាជនម្នាក់ ដែលគេពេញកិត្តិយសរបស់គេ រក្សាកិត្តិយសរបស់គេ គេស៊ីញ៉េថា "រូបនេះពិតជារូបថត ជុំ ស៊ីណារ៉េត" ។ ខ្ញុំរូបថតនេះ ខ្ញុំគោរពស្មារតីស្រលាញ់កិត្តិយសរបស់គេទាំងពីរ ។ ក៏ប៉ុន្តែ ជុំ ស៊ីណារ៉េត នេះខ្ញុំស្គាល់ ខ្ញុំថាអាមនុស្សនេះ ខ្ញុំស្គាល់រូបថតនេះខ្ញុំស្គាល់ ខ្ញុំទៅឯាកមើលបញ្ជីនេះ ជុំ ស៊ីណារ៉េត នៅក្នុងបញ្ជីនេះ ។ ដូច្នេះ វាមានឧបករណ៍សម្រាប់បញ្ជាក់ថារូបថតនេះ  វាពិត  ឯចំណែករូបថតទាំងប្រាំមួយ-ប្រាំពីរព្រឹកមិញ  អត់ទាន់មានឯកសារអីបញ្ជាក់នៅឡើយទេ ។ ដូច្នេះ ខ្ញុំមិនទាន់មានហេតុផលសម្រាប់បដិសេធរូបថតនេះនៅឡើយ  ហើយក៏មិនទាន់មានឯកសារសម្រាប់បញ្ជាក់រូបថតនេះនៅឡើយដែរ ។   ខ្ញុំសូមអនុញ្ញាតលោកប្រធានពេលខ្លះដើម្បីមើលលេខ ERN អំពី ជិន ម៉េត បន្តិច ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

គឺខ្ញុំដឹងថាកំពុងតែមើលឯកសារនៅទីនេះ ។ ប៉ុន្តែ ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ថា ជនជាប់ចោទគឺបានលើកឡើងទៅលើឯកសារ (សូមអភ័យទោស) ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន ពាក្យបណ្តឹង ជិន ម៉េត ដែលមាន ERN00281158 ដែល ជិន ម៉េត និយាយថានៅកង១៧នេះ គឺនៅលើលេខ ERN ប៉ុណ្ណឹង ។ ឯចំណែក ឯកសាររបស់ស-២១ ព្រៃស ដែលអង្គសវនាការប្រគល់មកខ្ញុំលើកក្រោយនេះ ដែលមានកង១៧ដែរ គឺឯកសារលេខ E47.22 ត្រង់ទំព័រ 288,868 ដូច្នេះឯកសារពីរនេះវាឆ្លើយឆ្លងគ្នា កង១៧ ជាកងរបស់ព្រៃស ។ ដូច្នេះឯកសារប៉ុណ្ណឹងវាគ្រប់គ្រាន់សម្រាប់ខ្ញុំទទួលស្គាល់ ជិន ម៉េត ហើយ ។

[១៣:៤០:១៤]

ឯចំណែក ប្រវត្តិរូប ជិន ម៉េត ដែលឲ្យមកខ្ញុំលើកក្រោយនេះ អង្គជំនុំជម្រះជ្រាបហើយ គឺប្រវត្តិរូបលេខ 00343200 ដូច្នេះវាបញ្ជាក់ទៅវិញទៅមកអ៊ីចឹង ។ សរុបមកខ្ញុំសូមនិយាយសាឡើងវិញ រូបថតរបស់អ្នកស្រី ណាំ ម៉ុន ទាំងប្រាំពីរសន្លឹក ខ្ញុំអត់ទាន់ឃើញឯកសារអីល្អមទទួលស្គាល់ ហើយក៏មិនទាន់មានឯកសារអីល្អមបដិសេធទេ សូមទុកជាបញ្ហានេះប៉ុណ្ណឹង ។ សូមចប់ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះ យើងទើបតែបានស្តាប់នូវយោបល់ ហើយយោបល់នេះមិនពាក់ព័ន្ធទៅនឹងបុគ្គលនៅក្នុងអង្គជំនុំជម្រះយើងនេះទេ ។ លោកកំពុងតែនិយាយអំពី ជិត ម៉េត ដែលយើងបានដេញដោលកាលអាទិត្យមុន ឬក៏លោកកំពុងតែនិយាយយោបល់បូកបញ្ចូលគ្នាទៅលើដើមបណ្តឹងរដ្ឋប្បវេណីកាលពីលើកមុន និងដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ថាតើលោកបានលើកឡើងយ៉ាងម៉េចទៅលើចំណុចទាំងនេះ?

**ជនជាប់ចោទ៖**

លោកចៅក្រមជាទីគោរព! ខ្ញុំនិយាយអំពីលក្ខណៈសម្បត្តិដើម្បីខ្ញុំទទួលស្គាល់រូបថត ហើយនិងសភាពទទួលស្គាល់បានខាងរូបថត ។ សភាពទទួលស្គាល់បានខាងរូបថតរបស់ ជិន ម៉េត ខ្ញុំបានអធិប្បាយសម្រាប់ជូនអង្គសវនាការថា គោលជំហរខ្ញុំក្នុងការទទួលស្គាល់រូបថតវាជាជំហានចុងក្រោយ ដែលខ្មែរយើងគេហៅថា ចុងមែកចុងធាងនៃសេចក្តីវិភាគរបស់ខ្ញុំ ។ មានឯកសារសព្វគ្រប់បានខ្ញុំទទួលស្គាល់ជាក្រោយ ។ នេះខ្ញុំបានលើកឧទាហរណ៍ ជិន ម៉េត មួយ ។ ទន្ទឹមនេះ ខ្ញុំលើកឧទាហរណ៍មួយទៅទៀត ពីដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ គឺដើមបណ្តឹងរដ្ឋប្បវេណីលេខ D255/6 ពីរឿងរូបថតប្អូនគាត់ ដើម្បី

បញ្ជាក់ វាមានទិដ្ឋភាពប្លែកពីរូបថត ជិន ម៉េត បន្ថិច ។

ដោយឡែកចំពោះអ្នកស្រី ណាំ ម៉ុន ក្រោយពីបានពន្យល់បញ្ហាពីរនេះហើយ ខ្ញុំបញ្ជាក់ជូនអង្គសវនាការថា រូបថតទាំងប្រាំពីរសន្លឹករបស់អ្នកស្រី ណាំម៉ុន នេះមិនទាន់មានឯកសារគ្រប់គ្រាន់សម្រាប់ឲ្យខ្ញុំទទួលស្គាល់ ហើយក៏មិនទាន់មានឯកសារគ្រប់គ្រាន់សម្រាប់ឲ្យខ្ញុំបដិសេធទេ នេះបញ្ជាក់ប៉ុណ្ណឹងសូមអស់យោបល់ ។

[១៣:៤៣:៤៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំយល់នូវអ្វីដែលលោកបានលើកឡើងជូនយើងខ្ញុំនៅក្នុងរសៀលនេះ ។ នៅពេលដែលលោកមានការបញ្ជាក់ត្រឹមត្រូវពីដើមបណ្តឹងផ្សេងទៀត និងសាក្សី នៅពេលនោះលោកនឹងទទួលស្គាល់ទៅលើសក្ខីកម្មនេះ ។ អ្វីដែលខ្ញុំចង់ដឹងពីលោកនៅរសៀលនេះ គឺថា ទោះបីជាលោកនិយាយថា ពុំមានឯកសារបញ្ជាក់ទៅលើរូបថតដែលយើងបានបង្ហាញព្រឹកមិញនេះក៏ដោយ ថាតើលោកទទួលស្គាល់បុគ្គលណាមួយដែលមាននៅក្នុងរូបថតនោះដែរឬទេ? ដែលថា អ្នកទាំងអស់នោះធ្លាប់ជាបុគ្គល ធ្លាប់ជាអ្នកយាម ឬក៏ធ្លាប់ជាអ្នកជាប់ឃុំនៅស-២១?

[១៣:៤៥:០០]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំបញ្ជាក់ព្រឹកមិញ វាជាទិដ្ឋភាពរួម បានន័យថា ក្នុងចំណោមបុគ្គលទាំងប៉ុន្មាន ដែលអ្នកស្រី ណាំ ម៉ុន ប្រកាសថាមករងគ្រោះនៅស-២១ នេះ គ្មានបុគ្គលិកណាម្នាក់របស់ស-២១ ទេ ។ អ្នកស្រី ណាំ ម៉ុន គាត់ប្រកាសថា ឪពុកគាត់ជាកម្លាំងតស៊ូក្រុង ។ ខ្ញុំបានបញ្ជាក់ព្រឹកមិញថា កម្លាំងតស៊ូក្រុងឲ្យមកស-២១ ប្រាំនាក់ ។ មួយ, ឈ្មោះ ម៉ា ម៉េងឃាង ហៅ ម៉ុន ខាងស្នងចម្លើយ ។ ពីរ, ឈ្មោះឡាយ ម៉េងហុង ហៅ ហាន ខាងសួរចម្លើយ ។ បី, ឈ្មោះ ពុយ តាយនី ហៅ នឿន ខាងសួរចម្លើយ ។ បួន, ឈ្មោះ ប៉ាន់ សុខន ហៅ ត្រូវ ខាងសួរចម្លើយ ។ ហើយប្រាំម្នាក់ទៀតឈ្មោះ ត្រូវ ខាងសួរចម្លើយដែរ ។ ដូច្នេះ គ្មានអ្នកណាម្នាក់ប្រគល់មកឲ្យ ស-២១ ខាងព័ស្តុភារទេ ។ ព័ស្តុភារ ខ្ញុំប្រើកម្លាំងចាស់របស់៧០៣ ។ ដូច្នេះ សរុបមកប៉ុន្មាននាក់នេះ ខ្ញុំអត់សង្កេតឃើញថា ខ្ញុំស្គាល់

អ្នកណាម្នាក់នោះសោះនៅឡើយទេ ។

សូមជម្រាបជូនប៉ុណ្ណេះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

សូមអរគុណ ។ ខ្ញុំពុំមានសំណួរសម្រាប់ជនជាប់ចោទនោះទេ ។ លោកប្រធាន តើខ្ញុំអាចសួរ ដើមបណ្តឹងរដ្ឋប្បវេណី ណាំ ម៉ុន ឲ្យគាត់ធ្វើការពិនិត្យទៅលើរូបភាពបានដែរឬទេ? សូមអនុញ្ញាតខាង សោតទស្សន៍បញ្ចាំងនៅលើអេក្រង់នូវរូបភាព ដែលមានលេខ ERN 00005249 ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅ ម៉េចខាងសោតទស្សន៍អាចបង្ហាញនូវរូបភាពដែលមានលេខ ERN លោកស្រីចៅក្រម បានបញ្ជាក់អំម្បាញ់មិញ នៅលើអេក្រង់ទូរទស្សន៍ទេ?

**សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

សូមអរគុណ ។

**ស៖** លោកស្រី ណាំ ម៉ុន តើលោកស្រីអាចប្រាប់ខ្ញុំដែរឬទេ? តើលោកស្រីស្គាល់បុគ្គលណា មួយនៅក្នុងរូបភាពនេះដែរឬទេ?

**ឆ៖** អត់ស្គាល់ផង ។ មើលអត់ស្គាល់ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

សូមអរគុណ ។ ខ្ញុំសុំអនុញ្ញាតពីលោកប្រធាន ខ្ញុំសូមសួរជនជាប់ចោទឲ្យគាត់ប្រាប់ឈ្មោះទៅ លើមនុស្សចាស់ទាំងអស់ ដែលមាននៅក្នុងរូបភាពនេះ?

[១៣:៤៩:០៤]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំសូមរាប់ពីឆ្វេងទៅស្តាំ ។ នៅខាងឆ្វេងគេបំផុតនេះ មនុស្ស ប្រុស គឺបង ម៉ម ណៃ ។ មនុស្សស្រីជាប្រពន្ធគាត់ ឈ្មោះ ស្វាយ គ្រួ ហៅ មុំ ។ ទីពីរ មនុស្សប្រុសនេះ ឈ្មោះ យូ ប៉េងគ្រី ហៅ ម៉ុន ប្រពន្ធគាត់ ខ្ញុំមិនស្គាល់ឈ្មោះទេ ខ្ញុំភ្លេចបាត់ហើយ ។ ឯចំណែកទីបី គឺ ខ្ញុំបាទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ។ ហើយនៅពីមុខនេះ គឺនាង ឈឹម សុផល ហៅ រ៉ុម ប្រពន្ធខ្ញុំបាទ ។ ហើយខាងនេះ គឺមិត្ត ម៉ា ម៉េងឃាង ហៅ ម៉ុន ប្រពន្ធឈ្មោះ មិត្តរិទ្ធ ។ នេះគឺសូមជម្រាបទាំងអស់ប្រាំបី នាក់ មនុស្សចាស់ៗ គឺប៉ុណ្ណឹង ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៏៖**

សំណួរចុងក្រោយអំពីរូបថតនេះ ។ តើលោកអាចប្រាប់ខ្ញុំដែរឬទេ? ក្រៅពីរូបលោកតើនរណាគេទៀត ដែលធ្វើការនៅស-២១ គឺចំពោះបុគ្គលដែលមាននៅក្នុងរូបភាពនេះ ជាមនុស្សចាស់ដែលលោកបានបញ្ជាក់អម្បាញ់មិញនេះ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកជំទាវ! ទាំងបួននាក់ប្រុសៗ សុទ្ធតែជាបុគ្គលិករបស់មន្ទីរស-២១ ។ ឯចំណែក មនុស្សស្រីម្នាក់ គឺប្រពន្ធបង ម៉ម ណៃ ក៏ជាបុគ្គលិករបស់មន្ទីរស-២១ ដែរ ប្រធានចុងភៅបុគ្គលិក ។ ឯចំណែកប្រពន្ធមិត្ត ម៉ា ម៉េងឃាង ឈ្មោះ មិត្តរិទ្ធ នេះ ធ្វើការនៅខាងរោងចក្រទេ អត់ទាន់បានយកចូលមកស-២១ទេ ។ ដល់ក្រោយមកក៏ចាប់ទាំងពីរនាក់ប្តីប្រពន្ធទៅ ។ សូមបញ្ជាក់ជូនប៉ុណ្ណេះ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៏៖**

សូមអរគុណ ។ ខ្ញុំពុំមានសំណួរផ្សេងទាក់ទងទៅនឹងរូបភាពនេះទេ លោកប្រធាន ហើយប្រហែលជាយើងអាចបង្វិលរូបភាពមករូបភាពធម្មតាវិញ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកានេះទៅមេធាវីការពារក្តី ដើម្បីមានឱកាស មានតាំងសំណួរសួរពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ណាំ ម៉ុន ។ ប្រសិនបើមាន សូមអញ្ជើញលោកមេធាវីការពារក្តី ។

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន សូមគោរពចៅក្រមជាតិ និងអន្តរជាតិ សូមគោរពអង្គសវនាការ ។

**ស៖** លោកស្រី ណាំ ម៉ុន ព្រឹកមិញ លោកស្រីបានជម្រាបជូនអង្គសវនាការថា លោកស្រីនិយាយតែការពិត ការមិនពិតលោកស្រីនិយាយមិនកើតទេ អ៊ីចឹងមែនទេ?

[១៣:៥២:១៥]

**ឆ៖** ពិតជាអ៊ីចឹងមែន ។

**ស៖** សូមអរគុណ ។ អ៊ីចឹង ខ្ញុំសូមសួរលោកស្រីទៀត នៅក្នុងពាក្យបណ្តឹងលោកស្រីរៀបរាប់បងប្អូនលោកស្រី ខ្ញុំរាប់ទៅឃើញប្រាំមួយនាក់ បងប្អូនបង្កើត គឺបងប្រុស បួននាក់ លោកស្រី និងប្អូនប្រុសម្នាក់ ។ ក៏ប៉ុន្តែពេលសវនាការ នៅថ្ងៃព្រហស្បតិ៍ លោកស្រីថាបងប្អូនបង្កើត គឺប្រាំនាក់ ទាំងលោក

ស្រី ។ ហើយយ៉ាងម៉េចបានម្តងថា ប្រាំមួយ ម្តងថាប្រាំនាក់? ហើយលោកស្រី-- លោកស្រីបញ្ជាក់ថា អាណាមិនពិត លោកស្រីនិយាយអត់កើតទេ ។ ឥឡូវ សូមលោកស្រីបញ្ជាក់មើល តើវាយ៉ាងម៉េចរឿងហ្នឹង?

**ផ៖** ពេលវេលាព្រឹកមិញ ដែលនាងខ្ញុំបាននិយាយហើយតើ ។ បងប្អូនខ្ញុំមានប្រាំនាក់ ប្រាំមួយនាក់ទាំងប្អូនចិញ្ចឹមរបស់ខ្ញុំ ។ ហ្នឹងដែលខ្ញុំដាក់ពាក្យបណ្តឹងសាមុន ។

**ស៖** សូមអរគុណ ។ ពីព្រោះក្នុងពាក្យបណ្តឹង--

**ប្រធានអង្គជំនុំ៖**

ឈប់ៗសិនមេធាវី ការ សាវុត្ថ ដោយសារមានការជំទាស់ពីមេធាវី ស្ទួតហ្សីនស្គី ។ មានបញ្ហាអីទៅ មេធាវី ស្ទួតហ្សីនស្គី?

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំចង់ស្នើសុំលោកប្រធានឲ្យធ្វើការណែនាំមេធាវី ការ សាវុត្ថ កុំឲ្យគាត់និយាយប្រាប់មានលក្ខណៈច្រឡោតខ្លាំងពេក ដែលការធ្វើដូច្នោះ គឺធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីគាត់មានបញ្ហា ។ សូមឲ្យគាត់យល់ទៅលើបញ្ហានេះ ។ ដូច្នេះ ខ្ញុំស្នើសុំទៅឲ្យលោកប្រធាន ឲ្យធ្វើការណែនាំទៅដល់មេធាវីការពារក្តី ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ ហើយការកត់សម្គាល់នេះជាការល្អដែរ ហើយដោយសារអារម្មណ៍របស់ដើមរដ្ឋប្បវេណីរូបនេះ មានបញ្ហាផ្នែកខាងផ្លូវចិត្ត ដោយគាត់រន្ធត់ខ្លាំង ។ ដូច្នេះហើយ មេធាវីសុំបង្រួមនូវសំឡេង ហើយនិងពាក្យសម្តី ដើម្បីតាំងសំណួររាបសាបន្តិច ដើម្បីឲ្យគាត់អាចទទួលយកបាន ហើយនិងឆ្លើយតបនឹងសំណួរបានរហូតដល់ចប់ចុងចប់ដើម ។ សូមអញ្ជើញបន្ត លោកមេធាវី ។

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** សូមអរគុណលោកប្រធាន ។ ការពិត វានេះ គឺជាទម្លាប់របស់ខ្ញុំទេ ។ ខ្ញុំមិនបាននិយាយដើម្បីសម្លុត ឬគំរាមកំហែងរូបគាត់ ជាដើមបណ្តឹងរដ្ឋប្បវេណីទេ ។ ខ្ញុំគ្រាន់តែសុំឲ្យគាត់បញ្ជាក់ការពិតបានជាខ្ញុំសួរ ពីព្រោះក្នុងពាក្យបណ្តឹងរបស់គាត់ លោកស្រី ណាំ ម៉ុន អត់បាននិយាយថា មានកូនចិញ្ចឹមទេក្នុងពាក្យបណ្តឹង ថាបង និងប្អូន ។ អ៊ីចឹងត្រង់ហ្នឹងៗ ដែលខ្ញុំបាទឆ្ងល់ហ្នឹង បានឲ្យគាត់សុំឲ្យគាត់

បញ្ជាក់ ។ ខ្ញុំសុំតែឲ្យគាត់បញ្ជាក់អីតើ ។ សំណួរមួយទៀត លោកស្រីថា ធ្វើពេទ្យនៅទួលស្លែង តើលោកស្រី ធ្វើពេទ្យហ្នឹង ដែលបួមឈាមអ្នកទោសឬទេ?

[១៣:៥៦:០០]

**ឆ៖** ឯចំណែកខ្ញុំ ធ្វើពេទ្យនៅគុកទួលស្លែង គឺខ្ញុំមិនដែលបួមឈាម មិនដែលអីទេ ដើរតែចែកថ្នាំអ្នកជំងឺតែប៉ុណ្ណោះ ។

**ស៖** សូមអរគុណ ។ លោកស្រីបានបញ្ជាក់ជូនតុលាការកាលថ្ងៃព្រហស្បតិ៍ថា ពាក់កណ្តាលឆ្នាំ១៩៧៥ លោកស្រីធ្វើពេទ្យនៅ-- ចូលធ្វើពេទ្យនៅទួលស្លែង ។ ខ្ញុំសុំលោកស្រីបញ្ជាក់ឲ្យបានច្បាស់មើលបើគុកទួលស្លែង កើតនៅខែ២ ឆ្នាំ១៩៧៦ ។ កាលមុននេះ គុកទួលស្លែងមិនមែននៅត្រង់ទេ គឺនៅប៉េហ្ស៊ី (PJ) អ៊ីចឹង តើលោកស្រីទៅធ្វើពេទ្យនៅកន្លែងហ្នឹងម៉េច បើពេទ្យហ្នឹងមិនទាន់កើត? សូមលោកស្រី-- បើទួលស្លែងមិនទាន់កើតផង អាកន្លែងហ្នឹង សូមលោកស្រីបញ្ជាក់?

**ឆ៖** ពេលវេលាឆ្នាំ៧៥ ខ្ញុំបានធ្វើពេទ្យនៅម្តុំគុកទួលស្លែងនេះ ពិតប្រាកដមែន ប៉ុន្តែនៅក្នុងពេលនេះ កន្លែងនោះ ជាសាលារៀនទេ ដំបូងគេមិនហៅជា "គុក" ទេ ។ ហើយបន្ទាប់មកទៀត ខ្ញុំរស់នៅដល់ទៅឆ្នាំ៧៦ ចូលឆ្នាំ៧៧ ខ្ញុំធ្វើពេទ្យតាំងពីឆ្នាំ៧៥ រហូតទល់មក ។ ដល់ឆ្នាំ៧៧ នៅកន្លែងគុកនេះតែម្តង ។

**ស៖** សូមអរគុណ ។ សូមឲ្យលោកស្រីបញ្ជាក់ឲ្យចំសំណួររបស់ខ្ញុំ ។ ខ្ញុំចង់ដឹងថា គុកទួលស្លែងកើតនៅខែ២ ឆ្នាំ១៩៧៦ ហើយលោកស្រីបានបញ្ជាក់ជូនតុលាការថា លោកស្រីធ្វើពេទ្យនៅទួលស្លែងនៅកន្លែងទួលស្លែងហ្នឹង វានៅពាក់កណ្តាលឆ្នាំ១៩៧៥ ។ អ៊ីចឹង ខ្ញុំសុំសួរលោកស្រី ឲ្យលោកស្រីបញ្ជាក់មើល បើទួលស្លែង វាមិនទាន់កើតនៅកន្លែងហ្នឹងផង វានៅឯប៉េហ្ស៊ី នោះនៅឡើយទេ ។ វាមិនទាន់យកលើកយកមកដាក់កន្លែងហ្នឹងទេ ហើយលោកស្រីបញ្ជាក់ប្រាប់តុលាការថា លោកស្រីបានមកធ្វើពេទ្យហ្នឹង អាផ្ទះមួយដំបូលរាងដែលក្រហមស្រអាប់ នៅៗអាមុខទួលស្លែង ។ សូមលោកស្រីបញ្ជាក់មើលបើពេទ្យ-- ទួលស្លែងមិនទាន់កើតផង លោកស្រីទៅធ្វើពេទ្យនៅហ្នឹងមើលអ្នកណា? ហ្នឹងខ្ញុំចង់ដឹងប៉ុណ្ណឹងទេ ។ សូមអរគុណ ។

**ឆ៖** ព្រោះខ្ញុំធ្វើពេទ្យនៅកន្លែងគុកទួលស្លែង ។ បញ្ជាក់ខ្ញុំថាព្យាបាលអ្នកណា? ពីដើមដំបូងគឺព្យាបាលនោះហើយ អ្នកបោសសម្អាតកន្លែងនោះ កើតឡើងជាគុក ។ បន្តទៅបានយកអ្នក-- បានយកប្រជាជនកូនកម្មាភិបាលអី យកទៅដាក់ទីនោះ គឺគេបង្កើតជាគុកតែម្តងទៅ ពីមុនគេមិនទាន់មែនហៅ

គុកទេ កន្លែងនោះ តាំងពីខ្ញុំទៅនៅឆ្នាំ៧៥ ក៏គេមិនទាន់ហៅគុកដែរ ។ មានក្រុមកងពលពួយើងខ្ញុំនេះ ហើយ ដែលបោសសម្អាតសាលារៀន នៅទីគុកទួលស្លែងនេះ ហើយខ្ញុំចាប់ធ្វើពេទ្យតាំងពីនុំងរហូតទៅ រហូតដល់ឆ្នាំ៧៧ នេះតែម្តង ។ ពីដំបូងខ្ញុំព្យាបាលយោធាទេ បន្ទាប់មកខ្ញុំព្យាបាលពួកអ្នកជាប់គុក ។

**ស៖** សូមអរគុណ ។ ខ្ញុំចង់ដឹងតែប៉ុណ្ណឹងទេ ។ សំណួរមួយទៀត លោកស្រីថាបងលោកស្រីឈ្មោះ ខន ដែលបើកយន្តហោះ ។ កាលបងលោកស្រីទាំងអស់រៀបរាប់នៅក្នុងសំណុំរឿង បើមិនជឿលោកស្រីយកមើលទៅ នៅក្នុងពាក្យបណ្តឹងរបស់លោកស្រី អត់មានឃើញឈ្មោះ ខឿន នេះទេ ។ ហេតុអីក៏ដល់ពេលសវនាការនេះ ថាមានឈ្មោះ ខឿន ជាបងលោកស្រី បានបើកកប៉ាល់ហោះទៅវិញ? សូមលោកស្រីបញ្ជាក់ ។

[១៤:00:00]

**ឆ៖** កាលដើមឡើយឈ្មោះ ខឿន នោះ ដែលខ្ញុំដាក់ពីដើមដំបូង គឺខ្ញុំដាក់ថាបងប្អូនជីដូនមួយ ហើយខ្ញុំមិនបានថាគាត់ធ្វើការងារអី ព្រោះមកពីខ្ញុំភ័យខ្លាចខ្លួនឯង គេយកទៅសម្លាប់ចោលដូចគាត់ដែរ ។

**ស៖** សូមអរគុណ ។ នៅក្នុងនេះខ្ញុំរកឈ្មោះ ខឿន ហ្នឹង ក៏វាអត់ឃើញទៀតក្នុងពាក្យបណ្តឹង ។ សូមអរគុណ ។

ឥឡូវសូមសួរសំណួរមួយទៀត ។ តើលោកស្រីចាំថ្ងៃខែឆ្នាំទេ ដែលលោកស្រីថា ម៉ោងប្រាំមួយ ដែលលោកស្រីឃើញបងខាងកើតវាយសម្លាប់ប្តីរបស់លោកស្រី? តើលោកស្រីចាំថ្ងៃខែឆ្នាំទេ?

**ឆ៖** គឺខ្ញុំពេលវេលានោះ គឺខ្ញុំអត់បានចាំទេ មិនដឹងថ្ងៃអីខែអីឆ្នាំអី គឺខ្ញុំមិនដឹង ។ ដឹងតែប្តីរបស់ខ្ញុំស្លាប់នៅឆ្នាំ៧៦ ។

**ស៖** សូមលោកស្រីបញ្ជាក់ម្តងទៀតអំពីទីតាំងកន្លែងរបស់លោកស្រីឈរ ថានៅលើអគារមួយ ដែលបណ្តោយថ្ងៃហ្នឹង ។ ហើយលោកស្រីបញ្ជាក់ប្រាប់តុលាការថា ឃើញគេពួ អឿន និង ពូ នៃ នេះ ព្រឹកមិញហ្នឹងពីរនាក់ហ្នឹង មើលទៅឃើញ លោកស្រីនៅជាន់ទីពីរខាងលើ ខ្មែរយើងហៅថា ជាន់ទីពីរអីចឹងចោះ ។ ក៏ប៉ុន្តែ អគារទទឹងថ្ងៃហ្នឹង អាជាន់ខាងលើហ្នឹង វាបាំងជិតៗ អាខាងកើតក៏បាំងជិត អាខាងលិចក៏បាំងជិត អត់មានមើលឃើញទេ ពីព្រោះគេខ្លាចសិស្សធ្លាក់ ហើយវាមានតែអា*វេរង់ដា*នៅខាងមុខ ។ ហើយបើគេសម្លាប់នៅក្រោយខាងនោះ វាបាំងជិតទាំងអស់ ហើយតើលោកស្រីមើលម៉េចឃើញ? សូមស្រីបញ្ជាក់មើល ។

**ឆ៖** ខ្ញុំនៅជាន់ទីបី ខ្ញុំមើលតាមបង្អួចនោះមានដែកចម្រឹងបង្អួចនោះកន្លះម៉ែត្របួនជ្រុងនៅបង្អួចសាលាបង្រៀននៅគុកទួលស្លែងនេះតែម្តង ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមបញ្ជាក់ថា នៅអគារជាន់ទីបីខាងលើហ្នឹង ដែលលោកស្រីថាទីបីហ្នឹង ពីព្រោះចុងខាងកើត និងចុងខាងលិចសុទ្ធជណ្តើរឡើងៗ ដល់ជណ្តើរឡើង អ៊ីចឹងអគារដែលគេធ្វើនេះ អត់មានបង្អួចទេ នៅខាងដែលលោកស្រីថា គេឃើញជនជាប់ចោទហ្នឹងវាយ វាមានតែមើលមកតាម *វេរង់ដា* និងតាមបង្អួចទៅខាងទិសខាងជើង ។ ចុះអាកន្លែងដែលគេសម្លាប់នោះ វានៅក្រោយអគារមួយនោះ វានៅក្រោយដើមដូងទៅទៀត ក្បែរដើមដូងខាងណោះ ។

ដូច្នេះ អត់មានឃើញកន្លែងណា ដែលអាចមើលឃើញជនជាប់ចោទវាយអ្នកទោសទេ?

[១៤:០៣:១០]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សូមលោកសម្រួលនូវពាក្យពេចន៍របស់លោក ដើម្បីចៀសវាងនៅក្នុងធ្វើការងារបែបសន្និដ្ឋាន ។ សូមលោកតាំងសំណួរជាក់លាក់អំពីស្ថាននានា ដើម្បីគាត់បានយល់ ហើយនិងឆ្លើយតបមិនអាចធ្វើ-- មិនគប្បីធ្វើតែសន្និដ្ឋាននៅក្នុងពាក់កណ្តាលទីនៃដំណើរការដេញដោលទេ ។

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។

**ស៖** កាលពីថ្ងៃព្រហស្បតិ៍ លោកស្រីថាពេទ្យបីនាក់គ្មានអ្នកណាប្រធានទេ តែថ្ងៃនេះលោកស្រីថា មានមិត្តលន ជាប្រធាន ហេតុអីបានខុសគ្នាអ៊ីចឹង? សូមលោកស្រីបញ្ជាក់ ។

**ឆ៖** កាលពីថ្ងៃមុនគាត់សួរខ្ញុំថា ពេទ្យមានប៉ុន្មាននាក់ ខ្ញុំឆ្លើយថាបីនាក់ រឿងប្រធាន មិនប្រធាន មិនប្រធានខ្ញុំអត់បានឆ្លើយទេ ។ នៅពេលនេះគាត់បញ្ជាក់ខ្ញុំ មួយណាជាប្រធាន គឺខ្ញុំប្រាប់ថាឈ្មោះមិត្តលន មិត្ត ឃីម, ខ្ញុំ បីនាក់តែម្តង ។

**ស៖** សូមអរគុណ ។ តើនៅក្នុងរបប ប៉ុល ពត តើគេមានអនុញ្ញាតឲ្យគេជប់លៀងទេ?

**ឆ៖** គឺនៅក្នុងពេលវេលានោះ គេជប់លៀង កាលពីពូខ្ញុំ ពុកខ្ញុំអី ម្តាយខ្ញុំនៅរស់មានគឺមាន ដល់គាត់គេយកគាត់ដាក់គុកអស់ទៅ គឺគ្មានទេ ។

**ស៖** សូមអរគុណ ។ តើពូអឿន ដែលគាត់ជប់លៀងហ្នឹង ដើម្បីជប់លៀង ដើម្បីអបអរសាទរស្អីដែរ? សូមលោកស្រីបញ្ជាក់ផងមើល ។

**ឆ៖** គឺពួកខ្ញុំ ដែលគាត់ជប់លៀងហ្នឹង គឺខ្ញុំមិនដឹងជាសន្និដ្ឋានថា គាត់ជប់លៀងអូរអរអីទេ ប៉ុន្តែពេលកាលណាជប់លៀងហ្នឹង គឺមានកម្មាភិបាលយ៉ាងច្រើនរួមទាំងអស់ ជប់លៀង ។ ហើយកន្លងមកទៀតគឺមានតែពីរបីនាក់ គឺអាចនៅជប់លៀងផ្ទះគាត់ទៀត ។ ខ្ញុំមិនដឹងគាត់ជប់លៀងមានផែនការអីក៏អត់ដឹងដែរ ។

[១៤:០៥:៣១]

**ស៖** លោកស្រី-- សូមអរគុណ លោកស្រីថា លោកស្រីចូលស-២១ បីខែ អ៊ីចឹងក្នុងរយៈពេលបីខែនេះ តើមានគេសួរចម្លើយលោកស្រីប៉ុន្មានដង?

**ឆ៖** ខ្ញុំជាប់គុកនៅទួលស្លែងនេះ ខ្ញុំជាប់បីខែ គេសួរចម្លើយខ្ញុំមួយខែពេលតែម្តង មួយថ្ងៃពីរដង ឬមួយម្តង ពេញក្នុងមួយខែ ។ បន្ទាប់ពីរខែក្រោយគេអត់សួរទេ គេបញ្ជូនទៅព្រៃស ។

**ស៖** សូមអរគុណ ។ ហើយអ៊ីចឹង ពេលដែលគេចាប់លោកស្រីចូលទៅស-២១ អ៊ីចឹង គេអត់បានថតលោកស្រីទេ? គេមានថតទេ?

**ឆ៖** នៅស-២១ គុកទួលស្លែងនេះ ខ្ញុំអត់មានថតទេ ។

**លោកស្រី ស៊ីលឃី ស្ទួតហ្វ៊ីនស្ត៖**

លោកប្រធាន ជាថ្មីម្តងទៀត ហើយគឺជាលើកទីបីហើយ ដែលសួរសំណួរដដែលនេះបីដងហើយ ដោយលោកចៅក្រម ដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ឥឡូវមេធាវីការពារសួរទៀត ។ ដូច្នេះ គ្រាន់តែរំឭក ។

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** សូមអរគុណ ។ ខ្ញុំសួរសំណួរនេះ ដើម្បីបញ្ជាក់ទៅលោកស្រី ថាតើលោកស្រីមានភស្តុតាងអ្វីខ្លះសម្រាប់បញ្ជាក់ថាលោកស្រីពិតជាជាប់នៅស-២១ ប្រាកដមែន? ខ្ញុំសូមបញ្ជាក់បន្ថែម ដូចខ្ញុំសួរអំមិញហ្នឹង ន៎! លោកស្រីអាចមានប្រវត្តិរូប លោកស្រីទៅរកមានប្រវត្តិរូបឃើញទេ? លោកស្រីអាចមានរូបថតទៅរករូបថតឃើញទេ? លោកស្រីអាចមានចម្លើយសារភាព ពីព្រោះថា លោកស្រីចូលទៅគេសួរលោកស្រីដល់ពេញមួយខែតែម្តង ។ អ៊ីចឹង លោកស្រីអាចទៅស្វែងរកចម្លើយហ្នឹងឃើញទេ? មានភស្តុតាងហ្នឹងទេ? ន៎! ហើយក្នុងនៅក្នុងនោះមានបញ្ជីឈ្មោះទៀត នៅទាល់សព្វថ្ងៃហ្នឹង បញ្ជីអត់ទាន់ទៅណាទេ នៅទួលស្លែងក៏មាន ខ្ញុំឧស្សាហ៍ចូលទៅមើលណាស់ ។

ដូច្នេះ ខ្ញុំសួរលោកស្រីជាម្តងទៀត ថាតើលោកស្រីមានភស្តុតាងអីខ្លះ សម្រាប់បញ្ជាក់ថាលោក

ស្រីពិតជាជាប់នៅ ស-២១ ពិតប្រាកដមែន? សូមលោកស្រីជ្រាប ។

**ឆ៖** ឥឡូវ ខ្ញុំសូមឆ្លើយ ខ្ញុំតាមរករូបខ្ញុំហ្នឹងពាក់ព័ន្ធនៅសួរចម្លើយរបស់ខ្ញុំ គឺរកមិនឃើញទេ ។ តែឪពុកម្តាយខ្ញុំនេះ ក៏រកមិនឃើញដែរ ដែលស្លាប់នៅពេញមុខខ្ញុំហើយ ក៏រកមិនឃើញ ។ ចុះដឹងបោះចោលរណាត់រណែង បានខ្ញុំតាមរកមិនឃើញ ។ មានតែរូបថតនុំងជាតំណាង ឲ្យខ្ញុំទៅរកឯកសារឯណាទៀត បើរកអត់ឃើញផង ។

[១៤:០៨:៣៧]

**លោក ការ សាវុត្ថ៖**

សូមអរគុណ ខ្ញុំសូមអស់សំណួរ សូមឲ្យលោកមេធាវីអន្តរជាតិមេត្តាសួរបន្ត ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្វ្រង់ស្វ័រ រូ មេធាវីការពារអន្តរជាតិ ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រូ៖**

**ស៖** សូមអរគុណលោកប្រធាន ។ សូមជំរាបសួរលោកស្រីសាក្សី ខ្ញុំឈ្មោះ រូ ខ្ញុំជាមេធាវីការពារម្នាក់ទៀត ហើយខ្ញុំសូមសួរសំណួរទៅលោកស្រីពីរបីបន្ថែមទៀត ដើម្បីឲ្យលោកស្រីជួយធ្វើយ៉ាងណាឲ្យយើងខ្ញុំបានយល់ ។

លោកស្រីបានប្រាប់យើងថា លោកស្រីបានរៀនវិជ្ជាពេទ្យ ហើយមុននឹងចូលទៅធ្វើការនៅ ស-២១ ។ ខ្ញុំចង់សួរលោកស្រីថា ដើម្បីជម្រាបយើងឲ្យបានច្បាស់បន្ថែមទៀត ជាពិសេស តើលោកស្រីចាំបានដែរឬទេ? អំពីកាលបរិច្ឆេទ អំពីថ្ងៃខែឆ្នាំដែលចូលទៅរៀនពេទ្យនោះ? ហើយការបង្រៀនពេទ្យនោះ គេបង្រៀននៅកន្លែងណា? អ៊ីចឹង សួររកថ្ងៃខែឆ្នាំ ហើយនិងទីកន្លែងដែលគេបង្រៀនពេទ្យ ។

**ឆ៖** ខែឆ្នាំ គឺឆ្នាំ គឺយើងខ្ញុំដឹង ប៉ុន្តែខែអត់ដឹងទេ ខ្ញុំរៀនពេទ្យនៅឆ្នាំ៧៥នេះ ដើមឆ្នាំ៧៥ ហើយខ្ញុំរៀននៅជិតប៉ុស្តិ៍លេខប្រាំយើងសព្វថ្ងៃនេះ ។

**ស៖** សូមអរគុណ ដែលលោកស្រីបានឆ្លើយ ។ ដូច្នេះ លោកស្រីនិយាយថា គឺនៅជិតកន្លែងអគ្គីភ័យ តើនៅកន្លែងហ្នឹងវានៅជិតមន្ទីរពេទ្យ ឬក៏នៅជិតណា ដែលទាក់ទងទៅនឹងទីកន្លែង ដែលគេបង្រៀននោះ?

**ឆ៖** បង្រៀនអីខ្ញុំស្តាប់អត់បានផង អត់យល់ផង មិនដឹងថាម៉េច?

**ស៖** តើការបង្រៀនលោកស្រីនោះគេបង្រៀនកន្លែងណា? នៅក្នុងមន្ទីរពេទ្យ ឬក៏កន្លែងធ្វើការ? តើលោកស្រីទទួលការបង្រៀននៅកន្លែងណា ដែលថានៅជិតវិទ្យុប៉ុស្តិ៍លេខប្រាំហ្នឹង ថាតើនៅអគារនៅកន្លែងណា ដែលគេបង្រៀនពេទ្យនោះ?

[១៤:១១:៥៥]

**ឆ៖** គឺយើងខ្ញុំរៀនពេទ្យហ្នឹង នៅជិតនុ៎ងមែន ប៉ុន្តែអត់បានចាំថា អគារហ្នឹងនៅខាងលិច ឬមួយខាងកើត ខាងជើង ខាងត្បូង គឺអត់មានចាំទេ ។ បើចំពោះរូបយើងខ្ញុំ គឺរៀននៅឯណោះ-- កន្លែងនុ៎ងមែន ។ បន្តបន្ទាប់មកបានផ្លាស់ខ្ញុំមកនៅទួលស្លែងនេះតែម្តង ។

**ស៖** តើកន្លែងនោះជាមន្ទីរពេទ្យឬ?

**ឆ៖** កន្លែងដែលយើងខ្ញុំរៀនហ្នឹង គឺមិនមែនមន្ទីរពេទ្យពីសង្គមនោះទេ គឺរៀនតាមផ្ទះ គ្រាន់តែមានថា ហៅថាប្រធានមួយ គេអ្នកចេះដឹងអ៊ីចឹងទៅ គេមកបង្រៀនយើងបន្តែប៉ុននុ៎ង ។

**ស៖** សូមអរគុណ ។ តើមានមនុស្សប៉ុន្មាននាក់ ដែលទទួលការបណ្តុះបណ្តាល ឬរៀនសូត្រខាងវិជ្ជាពេទ្យជាមួយលោកស្រីនោះ?

**ឆ៖** ឯចំណែករៀននៅជិតប៉ុស្តិ៍វ៉ាដ្យូនោះ ផ្ទះនោះ គឺមានគ្នាច្រើន ដល់ពេលយើងខ្ញុំមកនៅទួលស្លែងនេះគឺមានតែបីនាក់ទេ ។ គេចាត់តាំងគ្រប់ជ្រុងទាំងអស់ ដកយើងខ្ញុំមកតែបីនាក់ទេ ដែលនៅកន្លែងរៀននោះមានគ្នាដប់នាក់រួចទៅហើយ ។

**ស៖** លោកស្រីបាននិយាយថា លោកស្រីបានទៅទួលស្លែងនៅក្នុងពាក់កណ្តាលឆ្នាំ១៩៧៥ តើអ៊ីចឹងមែនទេ?

**ឆ៖** ជាការពិតហើយ ខ្ញុំចេញពីពេទ្យមកពាក់កណ្តាលហ្នឹង ខ្ញុំទៅរស់នៅហ្នឹងគុកទួលស្លែងម្តង។

**ស៖** អ៊ីចឹង គឺថាលោកស្រីអាចចាំខែនៅក្នុងខែហ្នឹង នៅក្នុងខែមិថុនា កក្កដា ឬខែសីហា?

**ឆ៖** គឺយើងខ្ញុំចាំអត់បានដែរព្រោះនៅក្មេងពេក ចាំអត់ពេញមុខពេញមាត់ មិនអាចនិយាយបាន។

**ស៖** តាមពិតគឺអ៊ីចឹង តើលោកស្រីចាំទេ អ្នកណាជាប្រធានស-២១ នៅពេលដែលលោកស្រីទៅដល់ដំបូងនោះ?

**ឆ៖** កាលពីយើងខ្ញុំទៅដល់ដំបូងមានឈ្មោះ យ៉ែម ប្រធាននៅស-២១ នេះ ពាក់កណ្តាលឆ្នាំ១៩៧៥ ។ គេជាប្រុស កាន់កងពលនៅទីនោះ ។

**ស៖** តើលោកស្រីចាំទេ គាត់ជាប្រធានកងពលហ្នឹង កងពលលេខប៉ុន្មាន ឬកងពលឈ្មោះអ្វី?

[១៤:១៥:៥៤]

**ឆ៖** គាត់ បើប្រធានកងពលធំនោះ គាត់ជាប្រធានកងពលតូចរាយរងទ្រណាក់ទ្រនាប់ពីពូរបស់ខ្ញុំមក ពូខ្ញុំឲ្យគាត់កាន់កាប់កន្លែងនេះ ។ ប្រធាននៅកាន់ក្តាប់នៅកន្លែងគុកទួលស្លែងនេះ មិនទាន់ដាក់គុកទេ នៅជាសាលានៅឡើយទេ គាត់នៅក្តាប់ហ្នឹងនោះ មិនទាន់កើតជាគុកផង ។ មិត្តយ៉ែម ហ្នឹងគាត់ក្តាប់ហ្នឹងតាំងពីគាត់មិនទាន់សម្លាប់មនុស្សទេ ។ ហ្នឹងដំបូងហើយដែរ ចូលបងខាងកើតមក អាហ្នឹងបានកើតជាគុកទួលស្លែង ។

**ស៖** ដូច្នេះ អ៊ីចឹងគាត់នោះជាអ្នកក្រោមបង្គាប់របស់ពូរបស់លោកស្រីដែលថាកាន់កងពលនោះ។ អ៊ីចឹងតើកងពលនោះ ដែលគាត់កាន់កាប់នោះឈ្មោះអ្វីនៅកន្លែងនោះ?

**ឆ៖** ខ្ញុំអត់ដឹងកងពលហ្នឹងទីប៉ុន្មានអីប៉ុន្មានគឺ យើងខ្ញុំអត់ដឹងដែរ ។ ដឹងថាគាត់ចាត់តាំងកងពលគាត់មកនៅហ្នឹង មិត្តយ៉ែម ហ្នឹងនាំមកនៅកន្លែងគុកទួលស្លែងហ្នឹងតែម្តង ។ មិនទាន់កើតគុកទេនៅសាលាទួលស្លែង ដឹងកងពលគាត់លេខប៉ុន្មាន គឺយើងខ្ញុំអត់ដឹង ភ្លេចភ្លាំងអស់ហើយច្រើនពេក ។

**ស៖** សូមលោកស្រីព្យាយាមរំឭកឡើងវិញ ថាតើលោកស្រីបានបញ្ជាក់ថា ពូ មួយចំនួន ថាតើពូរបស់លោកស្រីមានប៉ុន្មាននាក់ហ្នឹង សូមរំឭកឡើងវិញបានទេ?

**ឆ៖** ពូរបស់ខ្ញុំគឺមានតែ អឿន, កេត, សែម ហ្នឹង តែប៉ុនទុំង ហើយ យ៉ែម ដែលប្រធានកងពលពូអឿន ចាត់តាំងមកហ្នឹង ពូ ដែរប៉ុន្តែ សាច់ឆ្ងាយ ។ ប៊ុន កេត ហើយនិង អឿន ហ្នឹងសាច់បង្កើតតែម្តងប្អូនពុកខ្ញុំបង្កើតតែម្តង ។

**ស៖** តើឈ្មោះ យ៉ែម ហ្នឹង តើឈ្មោះយ៉ែម នេះតើគាត់ជាអ្នកក្រោមបង្គាប់ពូរបស់លោកស្រីហ្នឹងពូមួយណា? អាចប្រាប់បានទេ?

**ឆ៖** ឈ្មោះ យ៉ែម ហ្នឹងគាត់ក្រោមបង្គាប់ពូខ្ញុំឈ្មោះ អឿន ជាគាត់ប្រធានធំនៅទីក្រុងភ្នំពេញនេះ ។ ឈ្មោះ យ៉ែម នៅពីក្រោមគាត់ទេ គាត់ចាត់តាំងមក ។

**ស៖** អ៊ីចឹងនៅពេលដែលលោកស្រីមកដល់ទួលស្លែងនៅពាក់កណ្តាល់ឆ្នាំ១៩៧៥ ប្រធានរបស់លោកស្រីនៅកន្លែងនោះឈ្មោះ យ៉ែម តើអ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងមែនហើយ ឈ្មោះ យ៉ែម ។

**ស៖** នៅពេលដែលលោកស្រីទៅដល់ស-២១ នៅឆ្នាំ១៩៧៥ តើលោកស្រីនៅពេលណាមួយលោកស្រីធ្លាប់បានប្តូរទីកន្លែងទេ តើទួលស្លែងធ្លាប់ប្តូរពីកន្លែងមួយទៅកន្លែងណាមួយទេនៅក្នុងចុងឆ្នាំ

១៩៧៥ នោះ ?

**ឆ៖** គឺកន្លែងខ្ញុំរស់នៅក្រុមពេទ្យបីនាក់នេះ គឺមិនដែលប្តូរទេ បើខ្ញុំចង់ទៅលេងម្តាយខ្ញុំ ឪពុកខ្ញុំ គឺខ្ញុំអាចទៅលេងមួយយប់ពីរយប់បាន ឲ្យប្តូរតែម្តងគឺអត់មានទេ ។

**ស៖** ដូច្នេះលោកស្រីបានប្រាប់អង្គជំនុំជម្រះថា លោកស្រីទៅដល់ទួលស្លែងនៅក្នុងពាក់កណ្តាលឆ្នាំ១៩៧៥ ហើយប្រធានរបស់លោកស្រីនេះ ឈ្មោះ យ៉ែម ហើយនៅក្នុងពេលរយៈពេលទាំងស្រុងដំណើរការទួលស្លែងនោះ គឺមិនដែលផ្លាស់ប្តូរទីកន្លែងទេ តើត្រឹមត្រូវទេ?

**ឆ៖** ចាស, ជាការត្រឹមត្រូវ ។

**ស៖** តើគេប្រាប់លោកស្រីដូចម្តេចដែលនៅពេលដែលស្រីទៅដល់ទួលស្លែងនៅពាក់កណ្តាលឆ្នាំ១៩៧៥ តើគេណែនាំឲ្យធ្វើការងារអ្វី ហើយសូមលោកស្រីជម្រាបអង្គជំនុំជម្រះអំពីកិច្ចការនោះ?

**ឆ៖** កាលមុនខ្ញុំទៅនៅក្នុងគុកទួលស្លែងហ្នឹង ខ្ញុំចេញពីរៀនពេទ្យមក ពួខ្ញុំអ្នកនាំទៅ ឲ្យខ្ញុំខិតខំធ្វើតម្រិះវិជ្ជាពេទ្យដើម្បីព្យាបាលដល់ទាហាន យោធាដែលនៅកាន់នៅកន្លែងនោះ ។ ខ្ញុំមិនបានធ្វើការអីធ្ងន់ធ្ងរទេ តាំងពីឆ្នាំ១៩៧៥ រហូត ព្រោះខ្ញុំរស់នៅជាមួយពួខ្ញុំ ព្រមទាំងពុកខ្ញុំទាំងអស់ ។

**ស៖** ហើយបន្ទាប់ពីនោះមក នៅពេលដែលអ្នកទោសមកដល់ តើលោកស្រីទទួលការណែនាំឲ្យធ្វើការងារអ្វីបន្ថែមទៀតទេ?

**ឆ៖** គឺដល់ពេលចុងក្រោយមកមានគេថា កន្លែងនេះជាកន្លែងដាក់អ្នកទោសកម្មាភិបាល សុទ្ធតែអ្នកកម្មាភិបាលបានយកទោសនេះបាន ព្រោះគុកនេះជាគុកសំខាន់សម្រាប់កម្មាភិបាល ព្រោះគេគ្មានណែនាំអីក្រៅពីឲ្យព្យាបាលមនុស្សទុកសួរចម្លើយនោះតែម្តង ។

**ស៖** តើគេប្រាប់ឲ្យលោកថា ថាមិនឲ្យនិយាយប្រាប់អ្នកណាម្នាក់អំពីអ្វីដែលលោកស្រីធ្វើដែរឬទេ?

**ឆ៖** អត់មានទេ ។

**ស៖** តើលោកស្រីមានសិទ្ធិប្រាប់អ្នកណាម្នាក់ផ្សេងទៀតនៅក្នុងស-២១ ថាពីការងារដែលលោកស្រីធ្វើដែរឬទេ?

[១៤:២៤:១៣]

**ឆ៖** គឺខ្ញុំអត់មានប្រាប់អ្នកណាក្រៅពីបងប្អូនខ្ញុំទេ ។

**ស៖** តើលោកស្រីស្គាល់ឈ្មោះ អ៊ុន លន់ ហៅថា ណាត ដែរឬទេ?

**ឆ៖** ខ្ញុំអត់បានស្គាល់ទេ ឈ្មោះ មិត្តណាត ហ្នឹងនោះ ។

**ស៖** ខ្ញុំសង្កេតឃើញថានៅក្នុងពាក្យបណ្តឹងរបស់លោកស្រីនោះ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ លោកស្រីមិនបានចង្អុលបង្ហាញ មិនបានបញ្ជាក់ថាលោកស្រីបានឃើញ មិនបានឃើញថាឪពុកមារបស់លោកស្រីត្រូវបានគេសម្លាប់នោះទេ តើលោកស្រីបានបញ្ជាក់ ឬមិនបានបញ្ជាក់ក្នុងនោះ ?

**ឆ៖** កាលពីខ្ញុំដាក់ពាក្យបណ្តឹងដំបូង គឺខ្ញុំអត់ប៉ានដាក់បញ្ជាក់ទេ តែឃើញគេវ៉ៃឪពុកមាខ្ញុំហ្នឹងក៏ខ្ញុំក្រៅពីដាក់ពាក្យបណ្តឹងគឺខ្ញុំអត់មានដាក់ទេ គឺខ្ញុំដាក់តែឪពុកម្តាយខ្ញុំតែប៉ុណ្ណោះ ។ ឯចំណែក ពូខ្ញុំនេះខ្ញុំទើបបន្ថែមពាក្យមកខាងក្រោយ ព្រោះខ្ញុំដឹងថាពេលណាខ្ញុំដាក់ ពេលនោះខ្ញុំខ្លាចខ្ញុំស្លាប់ វរៗបងប្អូនច្រើនអ៊ីចឹងទៅ គេគុំខ្ញុំ វ៉ៃខ្ញុំស្លាប់ទៅ ម៉្លេះហើយខ្ញុំអត់ប៉ាន ។ ទើបមកបច្ចុប្បន្ននេះបានខ្ញុំដាក់បន្ថែម ។

**ស៖** នៅពេលដែលគេសម្ភាសលោកស្រីពីសប្តាហ៍មុនដោយចៅក្រមនៅទីនេះ ហើយចៅក្រមបានសួរសំណួរមួយចំនួនទៅលោកស្រី ហើយលោកស្រីមិនបាននិយាយថា ឪពុកមារបស់លោកស្រីត្រូវបានគេសម្លាប់ រហូតដល់ពេលនេះបាននិយាយ តើអ៊ីចឹងមែនឬទេ?

**ឆ៖** ជាការអ៊ីចឹងពិតមែន ។

**ស៖** ដូច្នេះ គឺនៅពេលដែលសហព្រះរាជអាជ្ញាសួរសំណួរទៅលោកស្រីទេ ដែលលោកស្រីបញ្ជាក់ពីហេតុការណ៍ដែលលោកស្រីបានឃើញដោយផ្ទាល់ភ្នែកនូវការសម្លាប់នូវឪពុកមា ពូម្នាក់របស់លោកស្រី តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស, ប្រាកដអ៊ីចឹងមែនហើយ ព្រោះអីពីមុនខ្ញុំអត់ដែលបានដាក់ពាក្យព្រោះខ្លាចគេសម្លាប់ខ្ញុំដូចពូខ្ញុំដែរ ។ ទើបឥឡូវនេះបានខ្ញុំបានប្រាប់ ។

**ស៖** ហើយពេលនៅពេលដែលលោកសហព្រះរាជអាជ្ញាសួរទៅលោកស្រី លោកស្រីនិយាយតែពីឪពុកមាតែម្នាក់ទេ មិននិយាយពីរទេ តើអ៊ីចឹងមែនទេ?

**ឆ៖** នាងខ្ញុំនិយាយទាំងពីរ និយាយទាំងឈ្មោះ អឿន ហើយឈ្មោះ កេត ហើយឈ្មោះ សែមទៀតដល់ទៅបី ។ ឪពុកមាខ្ញុំមានបីនាក់ ខ្ញុំនិយាយទាំងបី ប៉ុនថាជួនមុនទៅយើងខ្ញុំអត់បាននិយាយឲ្យអស់ពីសាច់ញាតិរបស់យើងខ្ញុំទើបពេលនេះទេ ដែលខ្ញុំចេញឲ្យលោកតុលាការដឹង ។

[១៤:២៨:៥០]

**ស៖** ពិតអ៊ីចឹងមែនហើយ ។ ដូច្នេះ នៅពេលដែលសហព្រះរាជអាជ្ញាសួរសំណួរទៅលោកស្រីលោកនិយាយថា លោកស្រីនិយាយថា បានឃើញផ្ទាល់ភ្នែកនូវការសម្លាប់ពូម្នាក់ ហើយបន្ទាប់មកនៅ

ពេលដែលលោកស្រី ស្តួតហ្សីនស្តី សួរទៅលោកស្រី លោកស្រីប្រាប់អង្គជំនុំជម្រះថា លោកស្រីបានឃើញមានការសម្លាប់ឪពុកមាពីរនាក់ ។ ដូច្នេះ តើយើងយល់ស្របគ្នាទេនៅក្នុងពេលបញ្ចប់នៅការផ្តល់សក្ខីកម្មនេះ តើលោកស្រីបានឃើញការសម្លាប់ពូទាំងពីរនាក់ ពូពីរនាក់របស់លោកស្រីមែនទេ?

**ឆ៖** កាលដើមឡើយ គឺខ្ញុំឃើញពិតប្រាកដណាស់ យារដំបងវ៉ៃពូខ្ញុំម្នាក់ ក្រោយពីថ្ងៃវ៉ៃម្នាក់ហើយ តែពីរថ្ងៃក្រោយគឺវ៉ៃម្នាក់ទៀត ។ ដំបូង វ៉ៃពូខ្ញុំឈ្មោះ អឿន បីថ្ងៃក្រោយគឺវ៉ៃឈ្មោះ កេត ។ វ៉ៃរួមកន្លែងតែមួយតែម្តង ទាំងពីរហ្នឹងវ៉ៃកន្លែងតែមួយ ។

**ស៖** ហើយលោកស្រីក៏បានជម្រាបតុលាការផងដែរថា ប៉ុន្តែលោកស្រីមិនបានឃើញការសម្លាប់អ្នកទោសផ្សេងៗទៀតទេ ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ជាការពិតអ៊ីចឹងមែន ។

**ស៖** ដូចគ្នានោះដែរ នៅក្នុងពាក្យសុំរបស់លោកស្រី លោកស្រីមិនបាននិយាយអំពីកូនក្មេងដែលត្រូវបានគេសម្លាប់នៅព្រៃស តើលោកស្រីបាន មិនបានលើកឡើងដូច្នោះដែរឬទេ?

**ឆ៖** គឺកាលពីមុន ខ្ញុំគេសួរទៅដែលឃើញ បានឃើញក្មេងនៅឯព្រៃសនោះស្លាប់ទេ? ខ្ញុំថា បានឃើញ ប៉ុន្តែនៅអា ដែលគេសម្លាប់ផ្ទាល់ដែលយើងខ្ញុំឃើញនោះ គឺខ្ញុំអត់បាននិយាយទេ ខ្ញុំទើបនិយាយថ្ងៃនេះ ខ្ញុំឃើញគេបោះឡើងលើ ហើយគេយកកាណុងកាំភ្លើងព្យួរ ទ្រ នុំង គឺខ្ញុំទើបនិយាយថ្ងៃនេះទេ ។ ពីមុនមកខ្ញុំមិនដែលនិយាយទេ ។

**ស៖** ជាការពិតណាស់ នៅក្នុងពាក្យសុំរបស់លោកស្រី លោកស្រីមិនបាននិយាយទាល់តែសោះអំពីកូនក្មេងទាំងឡាយដែលត្រូវបានគេសម្លាប់នៅព្រៃស ហើយដូចគ្នានោះដែរខ្ញុំជឿថា វាជាការពិតផងដែរថា លោកស្រីមិនបានជម្រាបលោក លោកស្រីចៅក្រមនៅថ្ងៃព្រហស្បតិ៍និងនៅព្រឹកមិញនេះ ។ លោកស្រីមិនបានរៀបរាប់ប្រាប់ចៅក្រមអំពីទីកន្លែងដែលគេបោះកូនក្មេងឡើងទៅលើ ហើយចាក់នឹងចំពុះទុង ។ លោកស្រីមិនបានលើកឡើងអំពីទីកន្លែងនោះ នៅថ្ងៃនេះ និងនៅថ្ងៃព្រហស្បតិ៍សប្តាហ៍មុន តើមែនដែរឬទេ?

**ឆ៖** អត់បានលើកមែន ទើបលើកនៅថ្ងៃនេះតែម្តង ពីមុនមកខ្ញុំអត់ដែលបាននិយាយផង ។

[១៤:៣២:២៤]

**ប្រធានអង្គជំនុំ៖**

អស់ពេលហើយលោកមេធាវី ពេលវេលាចែកឲ្យអស់ហើយ ។

តើអស់លោក លោកស្រីចៅក្រមមានសំណួរអ្វីត្រូវសួរដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះថែមទៀតដែរឬទេ?

អង្គជំនុំជម្រះសូមអរគុណចំពោះលោកស្រី ណាំ ម៉ុន ដែលលោកស្រីបានអញ្ជើញមកចូលរួមនៅក្នុងដំណើរការនីតិវិធីសវនាការដោយមានការអត់ធ្មត់ ហើយប្រឈមនឹងការលំបាកលំបិនជាច្រើន ហើយហេតុផលប្រឈមទៅនឹងការតាំងសំណួរជាច្រើនពីអង្គជំនុំជម្រះ និងភាគីនានា ហើយក្រៅពីនោះរឿងហេតុដែលកើតឡើងគឺមានអំឡុងពេលយូរហើយ បើធៀបជាមួយនឹងបច្ចុប្បន្ននេះជាងសាមសិបឆ្នាំ បើគិតពី៧៥នោះ គឺវែងជាងសាមសិបឆ្នាំទៀត គឺសាមសិបបួន សាមសិប្រាំឆ្នាំហើយ ។ អ៊ីចឹងហើយហេតុនាំឲ្យមានបញ្ហាខ្លះក្នុងការចងចាំមនុស្សមានកម្រិត ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយគឺអង្គជំនុំជម្រះថ្លែងអំណរគុណ ហើយដល់លោកស្រី ហើយដល់ពេលនេះ គឺការសួរដេញដោលចំពោះលោកស្រីដល់ពីបញ្ចប់ហើយ ។ អ៊ីចឹងអង្គជំនុំជម្រះអនុញ្ញាតឲ្យលោកស្រីវិលត្រឡប់ទៅកាន់លំនៅដ្ឋានវិញ ។

មន្ត្រីតុលាការសម្របសម្រួលគាត់ ដើម្បីឲ្យគាត់បានត្រឡប់ទៅវិញ ហើយក៏សូមអរគុណដែលលោកស្រីអង្គការផ្នែកខាងសុខភាពផ្លូវចិត្តដែលបានអញ្ជើញចូលរួម ហើយនិងសម្របសម្រួលឲ្យដល់ដើមបណ្ដឹងរដ្ឋប្បវេណីនេះបានមានសតិអារម្មណ៍ល្អ ហើយបានឆ្លើយនឹងសំណួរបានរហូតដល់ទីបញ្ចប់។ សូមអញ្ជើញទៅចុះ ។

ហើយជាបន្តទៀតនេះ អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំពីរនាទី រហូតដល់ម៉ោងបី ខ្វះដប់នាទី សូមអញ្ជើញភាគីមកចូលរួមដើម្បីដំណើរការបន្តនីតិវិធីសវនាការដេញដោលតទៀត ។

*[សវនាការសម្រាកពីម៉ោង១៤:៣៥នាទី ដល់ម៉ោង១៤:៥២នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោល ហើយជាកិច្ចបន្តនេះអង្គ ជំនុំជម្រះស្ដាប់សក្ខីកម្មរបស់សាក្សី KW-08 គឺឈ្មោះ ម៉ម ណៃ ហៅ ចាន់ ។

មន្ត្រីតុលាការអញ្ជើញសាក្សី ម៉ម ណៃ ហៅ ចាន់ ចូលមកកាន់បន្ទប់សវនាការ ។

*[សាក្សីចូលកាន់បន្ទប់សវនាការ]*

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក ម៉ម ណៃ តើលោកឈ្មោះ ម៉ម ណៃ អ៊ីចឹងជាការត្រឹមត្រូវទេ?

**ឆ៖** បាទ, ជាការត្រឹមត្រូវហើយលោកប្រធាន ។

**ស៖** លោកចាំមើលសញ្ញាភ្លើងបើសិនជាក្បាលមេក្រូវាមានភ្លើងសឹមលោកមានប្រសាសន៍បាន សំឡេងហ្នឹងស្រូបទៅអ្នកបកប្រែ បានបកប្រែ ហើយភាគីផ្សេងទៀតដែលបានចូលរួមក្នុងដំណើរការនីតិវិធីទាំងការ ដំណើរការទាំងស្តាប់នេះវាមានជនជាតិបរទេស វាមានបារាំងនិងអង់គ្លេសដែលគេអាចបកប្រែបាន ។ តើលោកមានឈ្មោះ ម៉ម ណៃ អ៊ីចឹងជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ជាការត្រឹមត្រូវ ។

**ស៖** មានឈ្មោះហៅក្រៅដែរឬទេ? លោកមានដែលមានប្រើឈ្មោះផ្សេងទៀតក្រៅពីឈ្មោះ ណៃ ដែរឬទេ?

**ឆ៖** ឈ្មោះក្រៅគឺ ចាន់ ។

**ស៖** លោក ម៉ម ណៃ ដល់ឆ្នាំនេះតើលោកមានអាយុប៉ុន្មានហើយ?

**ឆ៖** ខ្ញុំមានអាយុ ៧៦ឆ្នាំហើយ ។

**ស៖** សព្វថ្ងៃនេះលោកមានទីលំនៅ នៅទីកន្លែងណាដែរ?

**ឆ៖** សព្វថ្ងៃនេះ ខ្ញុំនៅភូមិចម្ការល្ហុង ឃុំតាស្តា ស្រុកសំពៅលូន ខេត្តបាត់ដំបង ។

**ស៖** សព្វថ្ងៃនេះលោកប្រកបមុខរបររកស៊ីអ្វីដែរ?

**ឆ៖** សព្វថ្ងៃនេះ ខ្ញុំចាស់ហើយខ្ញុំអត់មានធ្វើអីទេ ។

**ស៖** លោក ម៉ម ណៃ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការថា លោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធ ឬសហព័ន្ធជាមួយនឹងភាគីណាមួយនៃរឿងក្តីនេះទេ ។ ហើយថាលោកបានស្បថរួចហើយ ជាការពិតដែរទេ?

**ឆ៖** នេះជាការពិត ។

**ស៖** ក្នុងនាមលោកជាសាក្សីដែលអង្គជំនុំជម្រះអញ្ជើញចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ លោកមានករណីកិច្ចត្រូវនិយាយតែការណ៍ណាដែលពិតដែលលោកបានដឹង បានឮ បានឃើញជូនអង្គសវនាការ ។ ហើយក្នុងនាមលោកជាសាក្សីលោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការសុំឲ្យធ្វើអំណះអំណាងណាមួយឬច្រើនដែលនាំឲ្យដាក់បន្ទុក ដាក់ពិរុទ្ធភាពទៅលើខ្លួនលោកគឺសិទ្ធិមិន

ធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង មានន័យថាដោយសារតែចម្លើយ ឬអំណះអំណាងនោះនាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់ ។ តើលោកយល់អំពីសិទ្ធិនេះដែរឬទេ?

**ឆ៖** បាទ,យល់ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ សូមអរគុណដែលលោកបានជម្រាបដល់សាក្សីដែលគាត់មានសិទ្ធិនៅស្ងៀមមិននិយាយស្តី ។ ប៉ុន្តែ មេធាវីការពារក្តីមានការលើកឡើងចំពោះការព្រួយបារម្ភទៅលើចំណុចនេះ ហើយខ្ញុំសូមលើកឡើងទៅលើការព្រួយបារម្ភនេះ ។ ដូចដែលលោក លោកស្រីចៅក្រម ជ្រាប សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានស្នើសុំពាក្យសុំទាក់ទងទៅនឹងសហឧក្រិដ្ឋកម្មរួម ។ ហើយសំណើនេះគឺមានលេខ *Index* ERN00339212 រហូតដល់លេខ 00339227 នៅក្នុងវាក្យខណ្ឌទី៩ នៃពាក្យសុំនេះដែលយើងមានតែជាភាសាអង់គ្លេសទេ នៅពេលនេះវាបានបញ្ជាក់ថា សហព្រះរាជអាជ្ញាបានពិចារណាថា ឌុច គឺជាផ្នែកមួយសហឧក្រិដ្ឋកម្មរួមដែលរួមទាំងសមាជិករបស់គាត់ដែលធ្វើការនៅ ស-២១ ផងដែរ ។

ដូច្នេះ ចំណុចនេះវាបានបញ្ជាក់ និងបង្ហាញថា សាក្សីដែលមានវត្តមាននៅទីនេះ ដែលគាត់ជាកូនចៅរបស់ឌុច គាត់មានគ្រោះថ្នាក់ និងមានហានិភ័យប្រសិនបើអង្គជំនុំជម្រះទទួលយកពាក្យសុំរបស់សហព្រះរាជអាជ្ញា ។ បានន័យថា គាត់នឹងអាចប្រឈមនឹងការចោទប្រកាន់ដោយព្រះរាជអាជ្ញា ។ ទោះបីជាគាត់មានរក្សាសិទ្ធិនៅស្ងៀមក៏ដោយ ។

ដូច្នេះ ចំពោះខ្ញុំវាជាភារកិច្ចក្នុងការជម្រាបទៅដល់សាក្សី នៅក្នុងដំណាក់កាលនេះអំពីហានិភ័យ និងគ្រោះថ្នាក់ដែលគាត់អាចនឹងប្រឈម ។ ហើយនេះគឺជាភារកិច្ច ដែលថាធ្វើយ៉ាងណាអនុញ្ញាតឲ្យសាក្សីនេះ និយាយដោយផ្ទាល់ជាមួយនឹងមេធាវីរបស់គាត់ ដែលមេធាវី របស់គាត់នឹងធ្វើការពន្យល់ថាតើវាមានន័យយ៉ាងម៉េចចំពោះសហឧក្រិដ្ឋកម្មរួម ហើយមេធាវីនោះនឹងជម្រាបថា បើសិនជាអង្គជំនុំជម្រះទទួលពាក្យសុំរបស់សហព្រះរាជអាជ្ញាសាក្សីរូបនេះ នឹងអាចទទួលខុសត្រូវ នឹងទទួលរងនូវការចោទប្រកាន់មិនថា នៅក្នុងតុលាការនេះ ឬក៏នៅក្នុងតុលាការជាតិ ។

ដូច្នេះ មុនពេលដែលយើងបន្តនីតិវិធីរបស់យើង លោកប្រធានជាទីគោរព! ខ្ញុំសូមអនុញ្ញាតឲ្យ

លោកប្រធាន ជម្រាបសិទ្ធិទៅដល់សាក្សីរូបនេះ ហើយសូមអនុញ្ញាតឲ្យគាត់នេះនិយាយជាមួយមេធាវីគាត់ដោយផ្ទាល់ជាមុនសិន ។ លើកលែងតែខាងការិយាល័យសហព្រះរាជអាជ្ញាទាត់ចោលនូវពាក្យសុំរបស់គាត់ភ្លាមៗ ជាពិសេសពាក្យសុំទាក់ទងទៅនឹងសហកម្មឧក្រិដ្ឋកម្មរួម ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក អានីស អះម៉េត៖**

សូមគោរពលោក លោកស្រី ចៅក្រម ភាគីនិងមេធាវី! ពាក់ព័ន្ធទៅនឹងបញ្ហានេះ សហព្រះរាជអាជ្ញាបានអញ្ជើញសហចៅក្រមស៊ើបអង្កេតគឺមិនឲ្យធ្វើការចោទប្រកាន់សាក្សីរូបនេះនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញរបស់យើង ។ ចំណុចនេះគឺយើងធ្វើឡើងនៅតាមវិធាន២៨.៤ ដែលសាក្សីនេះត្រូវបានធ្វើការសម្ភាសន៍ដោយសហចៅក្រមស៊ើបអង្កេត ។ ហើយជំហររបស់សហព្រះរាជអាជ្ញាមិនមានការផ្លាស់ប្តូរនោះទេ ដោយយើងមិនគិតអំពីលទ្ធផលដែលចេញពីសេចក្តីសម្រេចរបស់អង្គសវនាការ ។ ហើយចំណុចនេះគឺវាទាក់ទងទៅនឹងថាបុគ្គលណាដែលត្រូវចោទប្រកាន់នៅ អ.វ.ត.ក ។ នៅពេលដែលខ្ញុំលើកចំណុចនេះ គឺខ្ញុំបានបញ្ជាក់ទៅដល់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតហើយ ថាមិនឲ្យធ្វើការចោទ ប្រកាន់សាក្សីដែលគាត់មកផ្តល់សាក្ខីកម្មនៅចំពោះមុខអង្គសវនាការរបស់យើង ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមានចំណុចលើកឡើងចំនួនពីរ ។ ជាបឋម នៅពេលសហព្រះរាជអាជ្ញាបានបញ្ជាក់ករណីនេះទៅកាន់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញាមិនទាន់បានដាក់ពាក្យសុំនោះនៅឡើយទេ ដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ ។ ពាក្យសុំនេះគឺវាមានលក្ខណៈច្បាស់លាស់ណាស់ ដោយសារតែវាបានថែងអំពីរាល់បុគ្គលិកក្រោមបង្គាប់របស់ស-២១ ។ ដូច្នេះ ហើយគឺការដែលគាត់ដាក់ពាក្យសុំគឺក្រោយពេលដែលគាត់បញ្ជាក់ចំណុចនេះទៅកាន់ចៅក្រមស៊ើបអង្កេត ។ ហើយទីពីរសហព្រះរាជអាជ្ញាបានលើកឡើងថា មិនធ្វើការចោទប្រកាន់សាក្សីនេះ នៅមុខអង្គសវនាការយើងនេះទេ តើលោកអាចបញ្ជាក់នៅទីនេះ នៅពេលនេះដែរឬទេ ថាសាក្សីនេះនឹងមិនធ្វើការចោទប្រកាន់នៅ

ចំពោះមុខតុលាការជាតិនោះទេ? តើលោកអាចធានាចំណុចបានដែរឬទេចំពោះសាក្សីរូបនេះ? ប្រសិនបើលោកមិនអាចធ្វើបាននោះទេ ខ្ញុំស្នើសុំថា ឲ្យសាក្សីរូបនេះធ្វើការប្រឹក្សានិងពិភាក្សាយោបល់ជាមួយនឹងមេធាវីរបស់គាត់ជាមុនសិន ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក វាលៀម ស្មីត៖**

យើងមិនជំទាស់ទៅនឹងការស្នើសុំឲ្យសាក្សីរូបនេះពិភាក្សាជាមួយមេធាវីរបស់គាត់ទេ ក្រោមវិធាន២៨ ប៉ុន្តែខ្ញុំសុំលើកឡើងថា សហព្រះរាជអាជ្ញានៅចំពោះៗអង្គសវនាការនេះ គឺវាមិនផ្អែកទៅលើសេចក្តីសម្រេចយ៉ាងណារបស់អង្គសវនាការទាក់ទងទៅនឹងសហកម្មឧក្រិដ្ឋកម្មរួមនោះទេ ។ សូមអរគុណ ។

**សួរដោយប្រធានអង្គជំនុំ៖**

លោក ម៉ម ណៃ យើងស្តាប់នូវចំណាប់អារម្មណ៍របស់មេធាវីការពារក្តី ហ្វ្រង់ស្វ័រ រូ បាននិយាយយ៉ាងជាក់លាក់ថាឲ្យអង្គជំនុំជម្រះហ្នឹងរៀបចំដើម្បីឲ្យលោកហ្នឹងបានជួបនឹងមេធាវីរបស់លោក ។

**ស៖** សំណួរសួរថា តើលោក ម៉ម ណៃ មានមេធាវីដែរទេឥឡូវនេះ ហើយមេធាវីរបស់លោកឈ្មោះអ្វីដែរ?

**ឆ៖** ខ្ញុំអត់ទាន់មានមេធាវីអីទេ ។ កាលពីមុននោះឃើញមេធាវីម្នាក់មកជួបនឹងខ្ញុំ មេធាវីនោះឈ្មោះលោកស្រី ចិន្តា ។

**ស៖** លោកជួបជាមួយនឹងមេធាវីអ្នកស្រី ចិន្តា ហ្នឹង ពីនៅក្នុងដំណាក់កាលណា នៅដំណាក់កាលចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬក៏នៅពេលក្រោយមកទៀត?

**ឆ៖** នៅពេលដែលតុលាការកោះហៅខ្ញុំពីលើកមុន ហើយអាក់ខានអត់បានធ្វើនោះ ។

**ស៖** ចុះដល់ពេលនេះលោកត្រូវការមេធាវីដើម្បីប្រឹក្សាជាមុន មុននឹងលោកផ្តល់សក្ខីកម្ម ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំចង់មានមេធាវីដែរ ក៏ប៉ុន្តែខ្ញុំមិនអាចរកលុយជូនមេធាវីបានទេ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដោយមានហេតុនៃការបង្ហើបអំពីបញ្ហានេះពីមេធាវីការពារក្តីអន្តរជាតិលោក ហ្វ្រង់ស្វ័រ

រូ ហើយពិតមែនតែមានការលើកឡើងនូវមតិមួយចំនួនរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ប៉ុន្តែការអះអាងនោះ គឺជាដំណាក់កាលមុននៃដំណើរការសវនាការ ហើយកាលពីមុននោះ មិនមានពាក្យសុំឱ្យអនុវត្តនូវទម្រង់នូវការទទួលខុសត្រូវបែបសហកម្មឧក្រិដ្ឋកម្មរួមទេ ។

ពាក្យសុំរបស់សហព្រះរាជអាជ្ញាប្តឹងសុំឱ្យអនុវត្តនូវទម្រង់នៃការទទួលខុសត្រូវ បែបសហកម្មឧក្រិដ្ឋកម្មរួមនោះបានបញ្ជូនមកដល់អង្គជំនុំជម្រះនៅក្នុងអំឡុងពេលនៃអង្គជំនុំជម្រះចាប់ផ្តើមទទួលសំណុំរឿងក្តីលេខ ០០១ នេះដើម្បីចាត់ការ ។ ហើយមកដល់ថ្ងៃនេះ សាក្សីឈ្មោះ ម៉ម ណៃ បានបង្ហាញច្បាស់លាស់ថា កាលពីអង្គជំនុំជម្រះអញ្ជើញគាត់មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះកាលពីពេលមុន ដែលបានអាក់ខានទៅវិញ ដោយសារពេលវេលានៃការពិភាក្សាដេញដោលចំពោះអ្នកជំនាញខាងអន្តរជាតិហ្នឹងវាមានរយៈពេលវែង ហើយអស់ពេលទៅ កាលនោះមានការគាំទ្រដោយមេធាវី អ្នកស្រីចិន្តា ។ ហើយនាពេលនេះលោក ម៉ម ណៃ មានសំណូមពរជាក់លាក់ថា គាត់ត្រូវការមេធាវីដើម្បីពិភាក្សាមុននឹងគាត់សម្រេច ចិត្តថាតើគាត់ធ្វើផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះឬយ៉ាងណានោះ ។

ដោយហេតុថានាពេលនេះ អង្គជំនុំជម្រះបានធ្វើការទាក់ទងជាមួយនឹងអង្គភាពដែលពាក់ព័ន្ធក្នុងការផ្តល់សេវាមេធាវីដល់សាក្សីមិនអាចដំណើរការបានទេ ។ ហេតុដូច្នេះ អង្គជំនុំជម្រះប្រកាសផ្អាកដំណើរការសវនាការស្តាប់សក្ខីកម្មចំពោះសាក្សីឈ្មោះ ម៉ម ណៃ ហៅ ចាន់ សម្រាប់រសៀលនេះត្រឹមនេះ ។ ហើយអង្គជំនុំជម្រះក៏មិនបានគ្រោងទុកនូវសាក្សីផ្សេងទៀតដែរ ។ ដូច្នេះ អង្គជំនុំជម្រះប្រកាសផ្អាកដំណើរការសវនាការសម្រាប់ថ្ងៃនេះតែត្រឹមនេះ ហើយអង្គសវនាការប្រកាសបន្តដំណើរការសវនាការនៅថ្ងៃស្អែកចាប់វេលាពីម៉ោងប្រាំបួនព្រឹកទៅ ។

មន្ត្រីតុលាការសូមអញ្ជើញសម្របសម្រួលលោក ម៉ម ណៃ ដើម្បីឱ្យលោកបានត្រឡប់ទៅកាន់កន្លែងសម្រាកសមរម្យ ហើយឱ្យនាំគាត់ត្រឡប់មកកាន់សាលសវនាការវិញនៅថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបួនព្រឹក ។

អ៊ំ ម៉ម ណៃ អញ្ជើញទៅចុះ អញ្ជើញត្រឡប់ទៅវិញចុះ ហើយចាំស្អែកសឹមអញ្ជើញមកម្តងទៀតណាអ៊ំ ហើយអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឱ្យនាំគាត់មកកាន់សាលសវនាការនៅព្រឹកថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបួន ។

*[សវនាការផ្អាកនៅម៉ោង១៥:១៨នាទី]*